សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# យន្តការនៃការដោះស្រាយជម្លោះអន្តរជាតិ រវាងរដ្ឋ និងរដ្ឋ

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៤ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ឈឺន សុខឡា**
**គង់ វិសាល**

សាស្ត្រាចារ្យណែនាំ
លោក **ជុំ ចាន់វិត្ថា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៤

ឆ្នាំចូលសិក្សា ២០១០
ឆ្នាំសរសេរសារណា ២០១៤

# អារម្ភកថា

ប្រមាណជាបួនឆ្នាំកន្លងមកនេះ គឺជាពេលវេលាដ៏មានតំលៃ និងជាឱកាសសម្រាប់ និស្សិតទាំងឡាយក៏ដូចរូបខ្ញុំទាំងពីរនាក់ ក្រេបយកចំណេះដឹង ដើម្បីធ្វើជាអាវុធពិសេសមួយនាពេលអនាគត។ មុននឹងបោះជំហានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ យើងខ្ញុំបាន ស្រាវជ្រាវ ដោយយកចិត្តទុកដាក់និងស្រាយចម្ងល់នានា ស្តីពី "យន្តការដោះស្រាយជម្លោះអន្តរជាតិរវាងរដ្ឋ និងរដ្ឋ"។

នៅក្នុងសង្គមអន្តរជាតិ តាំងពីបុរាណកាលរហូតដល់បច្ចុប្បន្ន យើងសង្កេតឃើញថា បញ្ហាជម្លោះតែងតែកើតមានឡើងជាញឹកញាប់ជៀសមិនរួច ជាពិសេស គឺជម្លោះអន្តរជាតិនេះតែម្តង។ ជម្លោះអន្តរជាតិជាជម្លោះដែលមានលក្ខណៈស្មុគស្មាញនិងពិបាកក្នុងការស្វែងរកដំណោះ ស្រាយ។ កត្តាទាំងនេះក៏ព្រោះតែ ប្រទេសនិមួយៗព្យាយាមប្រកាន់ជំហររៀងៗខ្លួន និងចង់ទាញយកផលប្រយោជន៍ ពីភាគីម្ខាងទៀត។ ដូច្នេះហើយ គោលបំណងនៅក្នុងការស្រាវជ្រាវនេះគឺដើម្បីស្រាយឲ្យចេញជាលទ្ធផលនៃការដោះស្រាយជម្លោះអន្តរជាតិ របស់រដ្ឋនីមួយៗ ប្រកបដោយសន្តិភាព និងជៀសឲ្យផុតនូវការទាមទារយកឈ្នះរៀងៗខ្លួន។ ប្រធានបទនេះផ្តោតសំខាន់ គឺធ្វើយ៉ាងណា ជម្រុញឲ្យរដ្ឋ ដែលជាភាគីនៃជម្លោះធ្វើការដោះស្រាយជម្លោះរបស់ពួកគេទៅតាមនីតិវិធីច្បាប់ជាធរមាន ដើម្បីទទួលបានសន្តិសុខសុវត្ថិភាព ស្ថេរភាព និងការអភិវឌ្ឍជានិរន្តន៍ ដែលជាចំណុចប្រសើរបំផុតក្នុងសង្គមអន្តរជាតិ។

ការរៀបចំឯកសារនេះឡើង ពិតជានៅមានចំណុចខ្វះខាត ដែលកើតមានឡើងដោយអចេតនា ទាំង មួយចំនួនជាក់ជាមិនខាន។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ឯកសារនេះនឹងចូលរួមចំណែកយ៉ាងខ្លាំងក្នុងការសិក្សា ទោះបីមានទំហំតិច ឬច្រើនក៏ដោយ។

យើងខ្ញុំសូមស្វាគមន៍រាល់មតិរិះគន់ តិះទៀន ពីគ្រប់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវទាំងអស់ក្នុងន័យស្ថាបនា កែលម្អ បំពេញបន្ថែម ដើម្បីធ្វើឲ្យឯកសារមួយនេះកាន់តែមានភាពល្អប្រសើរជាងនេះទៅទៀត និងផ្តល់ផលប្រយោជន៍ដល់សង្គមជាតិទាំងមូល។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ **ឈឺន សុខឡា** និង **គង់ វិសាល** ជានិស្សិតផ្នែកច្បាប់ ឆ្នាំទី៤ សិក្សានៅសាកលវិទ្យាល័យភូមិន្ទ នីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ លោកអ្នកមានគុណទាំងពីរជាទីគោរព និងជាទីស្រលាញ់នៃកូន ដែលបានលះបង់ទាំងកម្លាំងកាយ និងកម្លាំងចិត្ត ទំនុកបម្រុងកូនគ្រប់បែបយ៉ាង ដោយមិនគិតពីការនឿយហត់ រហូតដល់កូនបានបញ្ចប់ការសិក្សានៅថ្នាក់ទី១២ប្រកបដោយភាពជោគជ័យ ព្រមទាំងបានជំរុញលើកទឹកចិត្តអោយកូនបានបន្តរការសិក្សា រហូតដល់ថ្នាក់ឧត្តមសិក្សានៅរាជធានីភ្នំពេញនេះ ។

ហើយក៏សូមសំដែងនូវការគោរព និងដឹងគុណដ៏ខ្ពង់ខ្ពស់ផងដែរចំពោះថ្នាក់ដឹកនាំ និងសាស្ត្រាចារ្យ ដែលបានបង្ហាត់បង្រៀននៅ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលចូលរួមចំនែកផលិត នូវបណ្តាញធនធានមនុស្សដ៏មានសារៈសំខាន់នៅក្នុងការអភិវឌ្ឍជាតិ ដែលធ្វើឲ្យយើងខ្ញុំបានក្រេបជញ្ជក់នូវចំណេះដឹងប្រកប ដោយក្តីរីករាយបំផុត ។

- ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំសម្រួលដល់ការសិក្សារបស់ពួកយើងខ្ញុំតាមរយៈការរៀបចំទីកន្លែងសម្រាប់សិក្សា។
- លោកស្រី **ព្រឹទ្ធបុរស** នៃមហាវិទ្យាល័យនីតិសាស្ត្រ ដែលបានរៀបចំកម្មវិធីសិក្សាបានល្អសម្រាប់និស្សិតទាំងអស់។
- ជាពិសេស សូមថ្លែងអំណរគុណយ៉ាងអនេកចំពោះ សាស្ត្រាចារ្យ **ជុំ ចាន់វិន្ធា** ដែលបានធ្វើការដឹកនាំ ណែនាំទាក់ទងនិងការសរសេរសារណានេះឡើង ជាពិសេសលោកបានចំណាយពេលកែសម្រួលនូវសរណាយើងខ្ញុំឲ្យកាន់តែប្រសើរឡើង។
- លោក សាស្ត្រាចារ្យ **ខាត់ ធី** លោកស្រី សាស្ត្រាចារ្យ **សុខ ចិន្តា** និងលោកស្រី សាស្ត្រាចារ្យ **សេង វណ្ណា** ដែលជាគណៈគ្រប់គ្រង បណ្ណាល័យនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានផ្តល់នូវឯកសារ និងដំបូន្មានល្អៗដល់ពួកខ្ញុំ។
- លោក គ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យទាំងអស់ដែលបានបង្ហាត់បង្រៀន អប់រំណែនាំផ្តល់ឱវាទល្អ តាំងពីបឋមសិក្សា រហូតដល់ថ្នាក់បញ្ចប់បិញ្ញាបត្រ។
- ជាចុងក្រោយ សូមអរគុណដល់មិត្តភក្តិទាំងអស់គ្នា ដែលបានចូលរួមផ្តល់យោបល់ក៏ដូចជាផ្តល់នូវឯកសារផ្សេងៗ ដែលទាក់ទងទៅនឹងប្រធានបទដែលយើងបានធ្វើការស្រាវជ្រាវនាពេលកន្លងមក។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់ សូមសម្តែងសេចក្តីដឹងគុណ និងចងចាំជានិច្ច ចំពោះគុណដ៏ជ្រាលជ្រៅរបស់អ្នកទាំងអស់គ្នា ហើយយើងខ្ញុំសូមជូនពរលោកអ្នកមានគុណទាំអស់ ឲ្យជួបតែសេចក្តីសុខ សុភមង្គល សុខភាពល្អ អាយុយឺនយូរ និងសូមឲ្យមាននូវជ័យជំនះលើគ្រប់ភារ កិច្ចទាំងអស់។

# មាតិកា

**សេចក្តីថ្លែងអំណរគុណ**

**អារម្ភកថា**

**តារាងសម្គាល់អក្សរកាត់** **ទំព័រ**

**សេចក្តីផ្តើម**....................1

**ជំពូកទី១៖ ទិដ្ឋភាពទូទៅនៃដំណោះស្រាយស្តីពីជម្លោះអន្តរជាតិ**....................៣

**ផ្នែកទី១៖ ប្រវត្តិនៃការដោះស្រាយជម្លោះអន្តរជាតិ**....................៣

កថាខណ្ឌទី១ ៖ ការកកើតរដ្ឋ....................៣

១.១. ការធ្វើអបគមន៍....................៤

១.២. ការប្រមូលផ្តុំបណ្តារដ្ឋ....................៤

១.៣.ការរួចផុតពីអាណានិគម....................៤

១.៤. ការបំបែករដ្ឋ....................៤

កថាខណ្ឌទី២៖ សញ្ញាណនៃការដោះស្រាយវិវាទអន្តរជាតិ....................៥

**ផ្នែកទី២៖ ស្ថានភាពដោះស្រាយជម្លោះនាពេលបច្ចុប្បន្ន**....................៦

កថាខណ្ឌទី១៖ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ....................៦

១ ១. ការដោះស្រាយជម្លោះដោយសន្តិវិធី....................៧

១.២. សេរីភាពក្នុងការស្វែងរកវិធីដោះស្រាយជម្លោះដោយសន្តិវិធី....................៨

កថាខណ្ឌទី២៖ ដំណោះស្រាយតាមផ្លូវតុលាការ....................៨

**ជំពូកទី២៖ យន្តការនៃការដំណោះស្រាយជម្លោះអន្តរជាតិ**....................១០

**ផ្នែកទី១៖ ដំណោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការ**....................១០

កថាខណ្ឌទី១៖ ការដោះស្រាយជម្លោះអន្តរជាតិតាមការចរចា....................១១

១.១. មូលដ្ឋាននៃការចរចា....................១២

១.២. អាជ្ញាធរមានសមត្ថកិច្ចក្នុងការចរចា....................១៤

១.៣. នីតិវិធីនៃការចរចា....................១៦

១.៣.១. ដំណាក់កាលត្រៀម....................១៦

១.៣.២. ការប្រព្រឹត្តទៅនៃការចរចា....................១៦

១.៣.៣. គម្រោងនៃការចរចា....................១៧

១.៣.៤. ការប្រតិបត្តិចរចារផ្សះផ្សា ............................................ ១៨
១.៤. គុណសម្បត្តិ និងគុណវិបត្តិនៃការចរចា ............................................ ១៨
១.៤.១. គុណសម្បត្តិ ............................................ ១៨
១.៤.២. គុណវិបត្តិ ............................................ ១៩
កថាខណ្ឌទី២៖ ការសម្រុះសម្រួល និងសន្ធានកម្ម (Good Offices and Mediation) ......... ២០
២.១. ការសម្រុះសម្រួល (Good Offices) ............................................ ២១
២.២. សន្ធានកម្ម (Mediation) ............................................ ២២
កថាខណ្ឌទី៣៖ ការអង្កេត (Inquiry) ............................................ ២៤
៣.១. សញ្ញាណនៃការអង្កេត ............................................ ២៤
៣.២. ដំណើរការនៃការអង្កេត ............................................ ២៤
កថាខណ្ឌទី៤៖ ការផ្សះផ្សា (Conciliation) ............................................ ២៦
៤.១. សញ្ញាណនៃការផ្សះផ្សា ............................................ ២៥
៤.២. នីតិវិធី និងដំណើរការផ្សះផ្សា ............................................ ២៦
**ផ្នែកទី២៖ ដំណោះស្រាយជម្លោះអន្តរជាតិក្នុងប្រព័ន្ធតុលាការ ............................................ ២៨**
កថាខណ្ឌទី១៖ តុលាការអចិន្ត្រៃយ៍អាជ្ញាកណ្តាល (PCA) ............................................ ២៨
១.១. សញ្ញាណនៃការបង្កើត ............................................ ២៨
១.២. សមាជិកអាជ្ញាកណ្តាល ............................................ ២៨
១.៣. រចនាសម្ព័ន្ធ ............................................ ២៩
១.៣.១. ក្រុមប្រឹក្សារដ្ឋបាល ............................................ ២៩
១.៣.២. អគ្គលេខាធិការ ............................................ ៣០
១.៣.៣. ការិយាល័យអន្តរជាតិ ............................................ ៣០
កថាខណ្ឌទី២៖ តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ (PCIJ) ............................................ ៣០
២.១. សញ្ញាណនៃការបង្កើត ............................................ ៣០
២.២. សមាសភាពចៅក្រម ............................................ ៣១
២.៣. នីតិវិធី ............................................ ៣១
កថាខណ្ឌទី៣៖ តុលាការយុត្តិធម៌អន្តរជាតិ(ICJ) ............................................ ៣២
៣.១. សញ្ញាណនៃការបង្កើត ............................................ ៣២
៣.២. សមាសភាពចៅក្រម ............................................ ៣៤

៣.២.១. ចៅក្រមនៃតុលាការ ........ ៣៤

៣.២.២. ចៅក្រមបណ្ដោះអាសន្ន (Ad hoc judges) ........ ៣៥

៣.២.៣. វិសមិតភាព ........ ៣៥

៣.៣. ដែនសមត្ថកិច្ចនៅក្នុងករណីវិវាទ ........ ៣៦

៣.៤. នីតិវិធីនៃបណ្ដឹង........ ៣៦

៣.៤.១. នីតិវិធីជាលាយលក្ខអក្សរ ........ ៣៧

៣.៤.២. នីតិវិធីដោយផ្ទាល់មាត់ ........ ៣៧

៣.៤.៣. ការប្ដឹងទាស់លើកដំបូង ........ ៣៧

៣.៤.៤. ការមិនចូលខ្លួនមកតុលាការ ........ ៣៨

៣.៤.៥. វិធានការបណ្ដោះអាសន្ន ........ ៣៨

៣.៥. វិធីសាស្ត្រដោះស្រាយរឿងក្ដី........ ៣៨

៣.៥.១. សេចក្ដីសម្រេច........ ៣៩

៣.៦. ការបកស្រាយសាលក្រម ........ ៣៩

**ជំពូកទី៣៖ ករណីសិក្សាស្ដីពីដំណោះស្រាយវិវាទអន្តរជាតិ ........ ៤០**

**ផ្នែកទី១៖ ករណីសិក្សាស្ដីពីដំណោះស្រាយវិវាទអន្តរជាតិ តាមប្រព័ន្ធតុលាការ ...... ៤០**

កថាខណ្ឌទី១៖ វិវាទព្រំដែនរវាង បូគីណាហ្វាសសូ និង នីហ្សេរ ដែល

ដោះស្រាយដោយតុលាការយុត្តិធម៌អន្តរជាតិ ........ ៤០

១.១. សញ្ញាណនៃវិវាទ........ ៤០

១.២. គូភាគីក្នុងរឿងក្ដី........ ៤០

១.២.១. ប្រទេស បូគីណា ហ្វាសសូ (Bukina Faso) ........ ៤០

១.២.២. ប្រទេស នីហ្សេរ (Niger) ........ ៤១

១.៣. សេចក្ដីប្រកាសរួមរបស់គូភាគី ........ ៤១

១.៤. ការទាមទាររបស់ភាគីក្នុងរឿងក្ដី ........ ៤១

១.៤.១. ការទាមទាររបស់ ប្រទេសបូគីណា ហ្វាសសូ (Burkina Faso) ........ ៤១

១.៤.២. ការទាមទាររបស់ប្រទេស នីហ្សេរ (Niger) ........ ៤៤

១.៥. ដំណើរការរឿងក្ដី ........ ៤៥

១.៦. សមាសភាពចៅក្រមកាត់ក្ដី . ........ ៤៥

១.៧. សេចក្ដីសម្រេចរបស់តុលាការ........ ៤៥

សេចក្តីសន្និដ្ឋាន....................................................................................................................៤៨
អនុសាសន៍ ..........................................................................................................................៥០
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ មនុស្សមិនអាចរស់នៅតែម្នាក់ឯងបានឡើយ គឺតែងមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក។ ការទាក់ទងគ្នានេះ ច្រើនជួបភាពមិនចុះសម្រុងគ្នា ដែលធ្វើឲ្យកើតមានឡើងនូវជម្លោះ ដោយភាគីខ្លះចង់កេងយកចំណេញ ឬឈ្លៀតឱកាសទាញយកផលប្រយោជន៍ពីភាគីម្ខាងទៀត។ យ៉ាងណាមិញ នៅក្នុងឆាកអន្តរជាតិ ក៏មិនខុសពីសង្គមជាតិ និងគ្រួសារប៉ុន្មានដែរ បញ្ហាជម្លោះរមែងកើតឡើងជៀសមិនរួច គ្រាន់តែជម្លោះខ្លះមានទំហំធំ ឬតូច ឬមានលក្ខណៈធ្ងន់ធ្ងរ ឬធូរស្រាលប៉ុណ្ណោះ។ ហេតុនេះហើយ ទើបនៅក្នុងឆាកអន្តរជាតិតែងមានបញ្ហាជម្លោះកើតឡើងមិនចេះចប់ ដូចជាសង្គ្រាមលោកលើកទី១ សង្គ្រាមលោកលើកទី២ សង្គ្រាមត្រជាក់ និងបញ្ហាជម្លោះតាមព្រំដែនគោក ឬព្រំដែនទឹកជាដើម (ករណី កម្ពុជា-ថៃ ស្តីពីបញ្ហាប្រាសាទព្រះវិហារ និងបញ្ហាសមុទ្រចិនខាងត្បូង រវាងប្រទេសចិន វៀតណាម ហ្វីលីពីន ម៉ាឡេស៊ី ប្រ៊ុយណេដារុយហ្សាឡឹមជាដើម)។ ជាការពិតណាស់ ជម្លោះទាំងនេះបានធ្វើឲ្យប៉ះពាល់ដល់សង្គមអន្តរជាតិទាំងមូល ជាពិសេសបញ្ហាជីវភាពរបស់ប្រជាជន។ ក្នុងការទ្រទ្រង់ស្ថានការជម្លោះទាំងនេះ គឺមានតែអង្គការអន្តរជាតិទេ ដែលដើរតួយ៉ាងសំខាន់ក្នុងការជួយដល់ការស្វែងរកដំណោះស្រាយ ជូនរដ្ឋជម្លោះ។ ទោះបីជាយ៉ាងណាក៏ដោយ ការស្រាវជ្រាវនេះគឺផ្តោតសំខាន់ទៅលើយន្តការនៃការដោះស្រាយជម្លោះអន្តរជាតិរវាងរដ្ឋនិងរដ្ឋ។ តើមាននីតិវិធីបែបណាខ្លះក្នុងការដោះស្រាយជម្លោះអន្តរជាតិ? តើនរណាជាអាជ្ញាធរមានសមត្ថកិច្ចក្នុងការដោះស្រាយជម្លោះអន្តរជាតិនេះ?

ជម្លោះអន្តរជាតិ ត្រូវបានចាត់ទុកជាបញ្ហាសំខាន់មួយ ដែលប្រទេសទាំងឡាយនៅលើពិភពលោកយកចិត្តទុកដាក់ ព្រមទាំងស្វះស្វែងរកដំណោះស្រាយ ឬពឹងពាក់ប្រទេសដ៏ទៃឲ្យជួយអន្តរាគមន៍ដើម្បីបញ្ចប់ជម្លោះ។ កាលណាមានជម្លោះកើតឡើងលើប្រទេសណាមួយ គឺធ្វើឲ្យប្រទេសនោះបាត់បង់ផលប្រយោជន៍ជាច្រើនដូចជា វិស័យសេដ្ឋកិច្ច ទេសចរណ៍ និងវិស័យនយោបាយជាដើម។ ផ្ទុយទៅវិញ ប្រសិនបើជម្លោះបានកើតឡើងហើយនោះ គឺមានតែធ្វើការដោះស្រាយតាមផ្លូវច្បាប់តែទើបជាយន្តការមួយចាកផុតពីការប្រើប្រាស់អាវុធ។ នៅក្នុងយន្តការដោះស្រាយជម្លោះអន្តរជាតិនេះដែរ គឺមានយន្តការពីរប្រភេទ ដែលប្រទេសនានានៅលើពិភពលោកច្រើនយកមកដោះស្រាយ រួមមានដូចជា ការដោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការ និងការដោះស្រាយជម្លោះអន្តរជាតិក្នុងប្រព័ន្ធតុលាការ។

ការដោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការ គឺជាវិធីសាស្ត្រមួយដែលប្រទេសជាច្រើនបានយកមកប្រើប្រាស់ហើយទទួលបានជោគជ័យ។ ការដោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការមានច្រើនបែប ដែលភាគីជម្លោះអាចជ្រើសរើសយកមកដោះស្រាយមានដូចជា ការចរចា ការសម្រុះសម្រួលនិងសន្ធានកម្ម ការអង្កេត និងការផ្សះផ្សា។ នៅក្នុងដំណោះស្រាយទាំងនេះ គេ

ឃើញមានចែងនៅក្នុងសេចក្តីប្រកាសម៉ានីល ស្តីពីការដោះស្រាយជម្លោះអន្តរជាតិដោយសន្តិវិធីនាឆ្នាំ១៩៨២ និងមានចែងនៅក្នុងមាត្រា៣៣ ធម្មនុញ្ញនៃសហប្រជាជាតិជាដើម។ ចំពោះការដោះស្រាយជម្លោះដោយសន្តិវិធីទាំងនេះ គឺមានគោលបំណងធ្វើយ៉ាងណាឲ្យរដ្ឋទាំងឡាយធ្វើការដោះស្រាយជម្លោះដោយយុត្តិធម៌ សន្តិភាព និងសន្តិសុខ។ ការដោះស្រាយបែបនេះផ្តល់នូវគុណសម្បត្តិជាច្រើនដូចជា ភាពឆាប់រហ័ស ភាពឯកជន ភាពបត់បែន និងចំណេញដល់ហិរញ្ញវត្ថុផងដែរ។

រីឯការការដោះស្រាយជម្លោះអន្តរជាតិក្នុងប្រព័ន្ធតុលាការវិញ ក៏ជានីតិវិធីមួយដែលធ្វើការដោះស្រាយទៅលើបញ្ហាជម្លោះអន្តរជាតិទាំងឡាយដែលកើតមានឡើងផងដែរ។ ភាគីជម្លោះអាចធ្វើការជ្រើសរើសការដោះស្រាយក្រៅប្រព័ន្ធតុលាការក៏បានដែរ ប៉ុន្តែប្រសិនបើការដោះស្រាយជម្លោះនេះមិនអាចទៅរួចនោះ គឺមានវិធីតែមួយគត់សម្រាប់ដោះស្រាយ គឺការដោះស្រាយជម្លោះអន្តរជាតិក្នុងប្រព័ន្ធតុលាការ។ ការដោះស្រាយជម្លោះអន្តរជាតិក្នុងប្រព័ន្ធតុលាការ រួមមានដូចជាតាមតុលាការអចិន្ត្រៃយ៍អាជ្ញាកណ្តាល(PCA) តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ(PCIJ) និងតុលាការយុត្តិធម៌អន្តរជាតិ(ICJ)ជាដើម។ ចំណុចពិសេសនៃការការដោះស្រាយជម្លោះអន្តរជាតិក្នុងប្រព័ន្ធតុលាការ គឺតុលាការមានឆន្ទានុសិទ្ធិក្នុងការសម្រេចដោយផ្អែកលើវិធានច្បាប់អន្តរជាតិ និងចាប់បង្ខំឲ្យភាគីជម្លោះត្រូវតែធ្វើការដោះស្រាយជម្លោះ ហើយនៅពេលដែលតុលាការសម្រេចសេចក្តីគឺចាប់បង្ខំឲ្យគូភាគីអនុវត្តសេចក្តីសម្រេចនេះតែម្តង។ ចំណែកឯសេចក្តីសម្រេចក្នុងការដោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការ គឺពុំមានលក្ខណៈចាប់បង្ខំឲ្យគូភាគីអនុវត្តឡើយ។ នៅក្នុងកិច្ចការស្រាវជ្រាវនេះ យើងខ្ញុំបានបែងចែកជាបីជំពូកដោយៈ

ជំពូកទី១៖ ស្តីពីទិដ្ឋភាពទូទៅនៃដំណោះស្រាយស្តីពីជម្លោះអន្តរជាតិ ដែលនៅក្នុងនោះចែកជាពីរផ្នែកគឺផ្នែកទី១៖ និយាយរៀបរាប់អំពីប្រវត្តិនៃការដោះស្រាយជម្លោះកន្លងមក និងផ្នែកទី២៖ ការដោះស្រាយជម្លោះនាពេលបច្ចុប្បន្ន។

ជំពូកទី២៖ ស្តីពីយន្តការដោះស្រាយជម្លោះរវាងរដ្ឋនិងរដ្ឋ ដែលនៅក្នុងនោះចែកជាពីរផ្នែកគឺផ្នែកទី១៖ រៀបរាប់អំពីការដោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការ និង ផ្នែកទី២៖ ការដោះស្រាយជម្លោះអន្តរជាតិក្នុងប្រព័ន្ធតុលាការ។

ជំពូកទី៣៖ ស្តីពីករណីសិក្សាដំណោះស្រាយជម្លោះអន្តរជាតិ ដោយលើកយកឧទាហរណ៍ជាក់ស្តែងមួយចំនួនទាក់ទងនឹងជម្លោះដែលកើតឡើងកន្លងមក។ ដើម្បីឲ្យកាន់តែយល់ច្បាស់និងស៊ីជម្រៅអំពីប្រធានបទនេះ យើងខ្ញុំនឹងសិក្សាលម្អិតអំពីជំពូកនីមួយៗបន្ថែមទៀត។

# ជំពូកទី១ ៖ ទិដ្ឋភាពទូទៅនៃដំណោះស្រាយស្តីពីជម្លោះអន្តរជាតិ

## ផ្នែកទី១ ៖ ប្រវត្តិនៃការដោះស្រាយជម្លោះអន្តរជាតិ

នៅលើពិភពលោកយើងនេះ ដោយមានការវិវត្តន៍និងរីកចម្រើនផ្នែកវប្បធម៌ អរិយធម៌ របស់មនុស្សជាតិ បានធ្វើអោយមនុស្សយើង ដែលពីមុនធ្លាប់រស់នៅជា បក្ស ជាពួក ជាក្រុម ឬកុលសម្ព័ន្ធ ឥឡូវនេះបានធ្វើការផ្លាស់ប្តូរមករស់នៅ តាមបែបជាបណ្តុំមនុស្សមួយក្រុមធំ ហើយមានការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកដែលគេឲ្យឈ្មោះថាសង្គមជាតិ។ នៅក្នុងសង្គមមនុស្សនេះផងដែរ ចាំបាច់ត្រូវតែមានប្រពៃណី ទំនៀមទម្លាប់ ច្បាប់ ដែលជាវិធានសម្រាប់ធ្វើការគ្រប់គ្រងដើម្បីជានាឲ្យប្រជាពលរដ្ឋរស់នៅត្រឹមត្រូវនិងសមរម្យ។ ការវិវត្តន៍នៃសង្គមនេះហើយបានធ្វើឲ្យមនុស្សទាមទារនូវការដឹកនាំគ្រប់គ្រងទឹកដីរហូតដល់ការបង្កើតបានជារដ្ឋ ដូចជារដ្ឋបុរាណក្រិច រដ្ឋស្ប៉ាតា បុរីអាតែន និងរដ្ឋរ៉ូម។

សង្គមមនុស្សបានវិវត្តន៍ទៅជារដ្ឋមួយ ដែលជាអង្គស្របច្បាប់មានដែនដី ប្រជាជនរស់នៅ រដ្ឋបាលគ្រប់គ្រង ឬរដ្ឋាភិបាល មានអធិបតេយ្យ និងមានការទទួលស្គាល់ពីរដ្ឋដ៏ទៃទៀត។

ការកកើតរដ្ឋឯករាជ្យដំបូងបញ្ជាក់ឲ្យឃើញថា ការធ្វើទំនាក់ទំនងរវាងរដ្ឋ និងរដ្ឋ គឺមានតាំងពីសម័យបុរាណក្រិចមកម្ល៉េះ។ ទោះជានៅសម័យដែលបុរីអាតែន មានទំនាក់ទំនងជាមួយរដ្ឋស្ប៉ាតាយ៉ាងណាក៏ដោយ ក៏រដ្ឋទាំងពីរនេះពុំមានទំនាក់ទំនងល្អប្រសើរឡើយ។ គេឃើញក្នុងសម័យនោះការធ្វើទំនាក់ទំនង រវាងរដ្ឋមានលើវិស័យ ពាណិជ្ជកម្ម វប្បធម៌ អរិយធម៌ សេដ្ឋកិច្ច និងនយោបាយ។ រីឯការធ្វើទំនាក់ទំនងរវាង រដ្ឋបុរាណក្រិច រ៉ូម៉ាំង ចិន និងឥណ្ឌា មានប្រភពវប្បធម៌ អរិយធម៌ ចំណាស់ជាងគេ ហើយបានធ្វើឲ្យប្រទេសនានានៅលើពិភពលោកយកគម្រាប់តាម។

### កថាខណ្ឌទី១ ៖ ការកកើតរដ្ឋ

រដ្ឋមួយអាចកកើតមានឡើង តាមរយៈការបង្កើតជាអង្គការនយោបាយ របស់ខ្លួននៅលើដែនដីមួយដែលគ្មានម្ចាស់ (Terra nullius) ដោយប្រើវិធីនៃការកាន់កាប់ជាក់ស្តែង ឬដោយគ្រាន់តែដោតទង់ជាតិរបស់ខ្លួនមុនគេ និងធ្វើសកម្មភាពមួយចំនួនដែលតំណាងឲ្យអធិបតេយ្យរបស់រដ្ឋលើដែនដីនោះ។ ប៉ុន្តែនាពេលបច្ចុប្បន្ននេះទឹកដីបែបនេះពុំមានសេសសល់ទៀតឡើយ ហេតុនេះរដ្ឋបង្កើតថ្មី អាចធ្វើទៅបានតាមរយៈការធ្វើអបគមន៍ ឬការប្រមូលផ្តុំគ្នានៃបណ្តាលរដ្ឋជាច្រើនមកជារដ្ឋតែមួយ ឬការរួចផុតពីអាណានិគម និងតាមរយៈការបំបែករដ្ឋចេញពីរដ្ឋណាមួយដែលមានស្រាប់។

## ១.១. ការធ្វើអបគមន៍

អបគមន៍មានន័យថា ប្រជាជនចំណែកណាមួយដែលរស់នៅលើទឹកដីណាមួយមានស្រាប់ បានធ្វើការទាមទារបង្កើតរដ្ឋថ្មីមួយដែលមានឯករាជ្យភាពពីមុននោះ។ អំពើនេះវាតែងតែធ្វើអោយមានផលប៉ះពាល់ដល់គោលការណ៍នៃបូរណភាពដែនដីរបស់រដ្ឋ ដូច្នេះវាមិនអាចអោយគេទទួលយល់ព្រមបានឡើយ។ ជាក់ស្តែងដូចជាការប៉ុនប៉ងធ្វើអបគមន៍នៃ ខេត្តកាតង់ហ្គា ដែលជាតំបន់មានរ៉ែត្បូងច្រើន ចេញពីប្រទេសកុងហ្គោនាឆ្នាំ១៩៦០ និងខេត្តប៊ីយ៉ាហ្វ្រា ចេញពីប្រទេស នីហ្សេរីយ៉ា (១៩៦៧-១៩៦៩) ត្រូវទទួលបរាជ័យ ដោយសារក្រុមប្រឹក្សាសន្តិសុខបានចេញនូវដំណោះស្រាយមិនទទួលស្គាល់អបគមន៍អស់ទាំងនោះ។ ក៏ប៉ុន្តែអបគមន៍ គឺជាកិច្ចការផ្ទៃក្នុងរបស់រដ្ឋ លើកលែងតែមានជម្លោះយោធា ដែលមានលក្ខណៈអន្តរជាតិ ទើបអាចមានអន្តរាគមន៍ពីខាងក្រៅ ជាពិសេសមានលក្ខណៈនយោបាយសុទ្ធសាធ។ កត្តានេះហើយទើបមានអបគមន៍មួយចំនួន បានបង្កអោយមានការបង្កើតរដ្ឋ។ ឧទាហរណ៍: បង់ក្លាដែស(Bangladesh) នៅឆ្នាំ ១៩៧០។

## ១.២. ការប្រមូលផ្តុំបណ្តារដ្ឋ

រដ្ឋមួយដែលកើតចេញពីរដ្ឋឯករាជ្យជាច្រើន បានសម្រេចប្រមូលផ្តុំគ្នាធ្វើជារដ្ឋតែមួយឲ្យឈ្មោះថារដ្ឋសហព័ន្ធ។ ជាក់ស្តែងដូចជាសម្ព័ន្ធរដ្ឋ ដែលបាននាំគ្នាបង្កើតជាសហរដ្ឋអាមេរិចនាឆ្នាំ ១៧៨៧ និងរដ្ឋសម្ព័ន្ធមួយទៀត ដែលបានក្លាយទៅជារដ្ឋសហព័ន្ធអាឡឺម៉ង់នាឆ្នាំ ១៨៦៦។

## ១.៣. ការរួចផុតពីអាណានិគម

ជាប្រភពដើមនៃការកកើតរដ្ឋឯករាជ្យថ្មីៗ នៅសតវត្សទី ១៩ និង២០។ នៅពេលនោះហើយដែលគោលការណ៍សញ្ជាតិ និង បន្ទាប់មកគោលការណ៍នៃសិទ្ធិស្វ័យសម្រេច របស់ប្រជាជន ត្រូវបានប្រកាសនៅក្នុងធម្មនុញ្ញនៃសហប្រជាជាតិ មាត្រា ១-២ និងមាត្រា ៥៥។ គោលការណ៍ទាំងនេះជំរុញអោយប្រជាជនដែលស្ថិតនៅក្រោមការត្រួតត្រាជិះជាន់ និងកេងប្រវ័ញ្ចពីបរទេស អាចរំដោះខ្លួន ហើយបង្កើតបានជារដ្ឋឯករាជ្យ។ ជាក់ស្តែងករណីទីម័រខាងកើតជាដើម។

## ១.៤. ការបំបែករដ្ឋ

ការបំបែករដ្ឋ គឺជារដ្ឋមួយដែលមានពីមុនមក បានបែកចេញពីគ្នា ហើយរលាយបាត់ ដោយមានការកកើតជារដ្ឋឯករាជ្យថ្មីជាច្រើននៅលើទឹកដីរបស់រដ្ឋចាស់នោះ។ ឧទាហរណ៍៖ អតីតរដ្ឋឆេកូស្លូវាគី បានក្លាយទៅជារដ្ឋថ្មី ២ គឺ សាធារណៈរដ្ឋឆេក និងប្រទេសស្លូវាគី។

## កថាខណ្ឌទី២ ៖ សញ្ញាណនៃការដោះស្រាយវិវាទអន្តរជាតិ

ការបង្កើតតុលាការមួយឡើង ក្នុងគោលបំណងជាតំណាងឲ្យមានការអភិវឌ្ឍដ៏យូរអង្វែង ហើយជាវិធីសាស្ត្រមួយដ៏ល្អបំផុតសម្រាប់ដោះស្រាយជម្លោះអន្តរជាតិដោយសន្តិវិធី ដែលប្រភពទាំងនេះមានតាំងពីយូរណាស់មកហើយ។

ជាងនេះទៅទៀតមាត្រា ៣៣ ធម្មនុញ្ញនៃសហប្រជាជាតិ បានចែងពីវិធីសាស្ត្រសម្រាប់ដោះស្រាយជម្លោះអន្តរជាតិដោយសន្តិវិធីជាច្រើនដូចជា៖ ការចរចា ការចុះអង្កេត សន្ធានកម្ម ការផ្សះផ្សា មជ្ឈត្តវិនិច្ឆ័យ យុត្តាធិការតុលាការ តាមរយៈភ្នាក់ងារតំបន់ ឬតាមរយៈកិច្ចព្រមព្រៀងណាមួយ ហើយការសម្រុះសម្រួលក៏ត្រូវបានដាក់បញ្ចូលក្នុងនីតិវិធីទាំងនេះដែរ។ ក្នុងចំណោមវិធីសាស្ត្រទាំងនេះ តម្រូវឲ្យមានការអន្តរាគមន៍ពីតតិយភាគីជាមិនខាន។ ឧទាហរណ៍៖ ការដោះស្រាយជម្លោះដោយការប្រើប្រាស់ សន្ធានកម្ម ចាំបាច់ត្រូវតែមានការចូលអន្តរាគមន៍ពីភាគីទីបី។ បន្ថែមពីនេះទៅទៀត មជ្ឈត្តវិនិច្ឆ័យក៏ជានីតិវិធីមួយដែលល្អផងដែរ ដែលភាគីជម្លោះទាំងពីរសម្រេចប្រគល់សិទ្ធិទៅឲ្យភាគីអព្យាក្រឹតក្នុងការដោះស្រាយ ហើយការដោះស្រាយបែបនេះតែងសម្រេចបាន។ ជាការពិតការដោះស្រាយចុងក្រោយគឺធ្វើឡើង តាមរយៈការប្រើប្រាស់ស្ថាប័នតុលាការ ហើយមានតែតុលាការយុត្តិធម៌អន្តរជាតិ (ICJ) ជាអាជ្ញាធរមានសមត្ថកិច្ចប៉ុន្តែលើកលែងតែករណីរឿងក្តីទាំងឡាយណាដែលភាគីជម្លោះ បានកំណត់ស្ថាប័នមានសមត្ថកិច្ចដោះស្រាយជាមុន។

ទោះបីជាយ៉ាងណាក៏ដោយ ប្រវត្តិនៃការដោះស្រាយជម្លោះអន្តរជាតិ បានកំណត់កាលបរិច្ឆេទត្រឹមសន្ធិសញ្ញាចាយ(Jay Treaty) នៅក្នុងឆ្នាំ ១៧៩៤ រវាង សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស។ សន្ធិសញ្ញា មិត្តភាព សន្តិភាព ពាណិជ្ជកម្ម នាវាចរណ៍ បង្កើតឡើងដោយគណៈកម្មការចម្រុះបីរូប ដែលមានសមាសភាពចេញពីសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស ដែលគណៈកម្មការនេះនឹងធ្វើការដោះស្រាយទៅលើសំណួរជាច្រើន ដែលភាគីទាំងពីរមិនទាន់បានព្រមព្រៀងគ្នាតាមរយៈការចរចា។ ប៉ុន្មានឆ្នាំក្រោយមក វិវាទនេះនៅតែមិនអាចដោះស្រាយរួច រហូតដល់មានការស្នើរសុំឲ្យមានការអន្តរាគមន៍ពីប្រទេសនៅក្នុងតំបន់អឺរ៉ុប។

មជ្ឈត្តវិនិច្ឆ័យ Alamaba រវាងសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស ត្រូវបានចាប់ផ្តើមហើយបានដំណើរការបន្តបន្ទាប់។ នៅក្នុងសន្ធិសញ្ញា វ៉ាស៊ីនតោន ១៨៧១ សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស បានប្រគល់ជម្លោះនេះទៅ ឲ្យភាគីអព្យាក្រឹតមួយជាអ្នកដោះស្រាយ ក្នុងកំឡុងពេលសង្គ្រាមផ្ទៃក្នុងរបស់សហរដ្ឋអាមេរិក។ ប្រមុខដឹកនាំប្រទេសទាំងពីរ បានសម្រេចជ្រើសយកភាគីអព្យាក្រឹតមួយដែលមានសមាជិកប្រាំប្រទេស ដូចជា សហរដ្ឋអាមេរិក(The United States of America), ចក្រភពអង់គ្លេស(United Kingdom), ប្រេស៊ីល(Brazil), អ៊ីតាលី(Italy), និងប្រទេសស្វីស

(Switzerland)។ បន្ទាប់មកគណៈកម្មការថ្មីមួយនេះ បានឲ្យចក្រភពអង់គ្លេស សងសំណងតាមការកំណត់របស់គណៈកម្មការ។

ដំណើរការនេះបានបង្ហាញពីប្រសិទ្ធិភាពនៃមជ្ឈត្តវិនិច្ឆ័យ ក្នុងការដោះស្រាយជម្លោះអន្តរជាតិ ហើយប៉ុន្មានឆ្នាំក្រោយមកនេះ នៅក្នុងសតវត្សទី១៩ គឺមានការបង្កើតឲ្យមានយន្តការដោះស្រាយជម្លោះអន្តរជាតិដូចជា៖

- ការដាក់បញ្ចូលនីតិវិធីមជ្ឈត្តវិនិច្ឆ័យនៅ ក្នុងសន្ធិសញ្ញានានា ក្នុងការដោះស្រាយជម្លោះរវាងរដ្ឋ និងរដ្ឋ
- ការដោះស្រាយជម្លោះត្រូវមានការចូលរួមពីតតិយរដ្ឋ
- បង្កើតឲ្យមាននីតិអន្តរជាតិរួមមួយនៃមជ្ឈត្តវិនិច្ឆ័យ ដើម្បីងាយស្រួលដល់ប្រទេសទាំងឡាយក្នុងការដោះស្រាយជម្លោះ
- ការបង្កើតឲ្យមានអាជ្ញាកណ្តាលអចិន្ត្រៃយ៍អន្តរជាតិមួយ ដើម្បីជៀសវាងកុំឲ្យមានការបង្កើតអាជ្ញាកណ្តាលពិសេស(ad hoc) ក្នុងការដោះស្រាយជម្លោះអន្តរជាតិ។

## ផ្នែកទី២ ៖ ស្ថានភាពដោះស្រាយជម្លោះនាពេលបច្ចុប្បន្ន

### កថាខណ្ឌទី១ ៖ ការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ

រដ្ឋមួយចំនួនបានប្រើវិធីដោះស្រាយជម្លោះផ្សេងៗ ដែលជាដំណើរការក្រៅប្រព័ន្ធតុលាការដូចជាអាជ្ញាកណ្តាល និងការសម្រុះសម្រួល ដើម្បីដោះស្រាយជម្លោះនិងការប៉ះទង្គិចគ្នាទៅវិញទៅមកនៅក្នុងទំនាក់ទំនងជាអន្តរជាតិ។ ការស្វែងរកនូវដំណោះស្រាយក្រៅប្រព័ន្ធតុលាការគឺបានផ្តល់នូវភាពងាយស្រួលច្រើន ដល់បណ្តារដ្ឋទាំងអស់ ព្រោះវាចំណាយពេលវេលាតិច ហើយមិនមាននីតិវិធីសាំញ៉ាំច្រើន ជាពិសេសគូភាគីអាចទទួលបាននូវដំណោះស្រាយដ៏សមស្របមួយ ដែលគ្មានអ្នកចាញ់ និងគ្មានអ្នកឈ្នះ។ នាពេលបច្ចុប្បន្ននេះ ជម្លោះជាច្រើនបានកើតឡើងជាបន្តបន្ទាប់ដោយសារតែការដណ្តើមទឹកដីគ្នា និងការដណ្តើមផលប្រយោជន៍គ្នាជាដើម ដែលធ្វើឲ្យពិភពលោកកំពុងមានការជ្រួលច្របល់ និងស្វែងរកនូវដំណោះស្រាយដ៏ល្អសម្រាប់គ្រប់គូភាគីវិវាទ។ ទោះជាការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ វាមានភាពងាយស្រួលក៏ពិតមែន ប៉ុន្តែវាក៏មានផលវិបាករបស់វាដែរ។ ការសម្រេចសេចក្តីក្រៅប្រព័ន្ធតុលាការពុំមានអនុភាពចាប់បង្ខំទេ ហើយក៏គ្មានប្រសិទ្ធិភាពយូរដែរ ដែលជាហេតុធ្វើអោយជម្លោះនោះនៅតែកើតឡើងម្តងហើយម្តងទៀត រហូតឈានដល់ដំណាក់កាលដោះស្រាយតាមផ្លូវតុលាការដដែល។ ជាទូទៅ រដ្ឋតូចៗរមែងចង់បានការដោះស្រាយតាមផ្លូវតុលាការជាជាងការដោះស្រាយក្រៅប្រព័ន្ធតុលាការ ដោយសារគេយល់ថាឥទ្ធិពលអំណាចនៃប្រទេសធំៗ អាចនឹងជះឥទ្ធិពលទៅលើសកម្មភាពសម្របសម្រួលពីសំណាក់រដ្ឋផ្សេងៗទៀត។

តួយ៉ាងដូចជាជម្លោះព្រំដែន រវាងប្រទេសកម្ពុជា-ថៃ និងជម្លោះសមុទ្រចិនខាងត្បូងរវាងមហាអំណាចអាស៊ីចិន និងប្រទេសផ្សេងៗទៀតក្នុងតំបន់អាស៊ីអាគ្នេយ៍។ ប្រទេសថៃ និងប្រទេសចិនសុទ្ធតែចង់ពិភាក្សាស្វែងរកដំណោះស្រាយដោយសន្តិវិធីក្រៅប្រព័ន្ធតុលាការ ចំណែកឯប្រទេសផ្សេងទៀត ដែលមានដូចជាកម្ពុជា វៀតណាម ម៉ាឡេស៊ី និងហ្វីលីពីនជាដើមនោះ ចង់ទាមទារឲ្យមានការដោះស្រាយតាមផ្លូវតុលាការជាង ព្រោះខ្លួនអាចនឹងទទួលបាននូវយុត្តិធម៌។ តែទោះជាយ៉ាងណា ការដោះស្រាយវិវាទនាពេលបច្ចុប្បន្នគឺសំដៅលើគោលការណ៍រួមមួយគឺ ការដោះស្រាយដោយសន្តិវិធី។

## ១.១. ការដោះស្រាយជម្លោះដោយសន្តិវិធី

ធម្មនុញ្ញនៃសហប្រជាជាតិ ហាមដាច់ខាតមិនឲ្យរដ្ឋទាំងឡាយប្រើកម្លាំងទ័ពក្នុងការដោះស្រាយជម្លោះឡើយ តែគេអាចរិះរកនូវវិធីផ្សេងៗដើម្បីដោះស្រាយជម្លោះដោយសន្តិវិធី។ ទោះជាយ៉ាងណាក៏ដោយ ក៏រដ្ឋទាំងនោះមិនត្រូវបានគេបង្ខិតបង្ខំឲ្យជ្រើសរើសយកនូវវិធីដោះស្រាយជម្លោះដោយសន្តិវិធីទាំងនោះឡើយ។ កាតព្វកិច្ចនេះត្រូវបានអះអាងបញ្ជាក់ដោយមាត្រា ២ កថាខណ្ឌ៣ និងមាត្រា ៣៣ ធម្មនុញ្ញនៃសហប្រជាជាតិ។

គោលការណ៍ខាងលើក៏មានចែងផងដែរនៅក្នុង សេចក្តីប្រកាសម៉ានីល ថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ១៩៨២ ស្តីពីការដោះស្រាយវិវាទដោយសន្តិវិធី។ សេចក្តីប្រកាសនេះ បានអំពាវនាវឲ្យរដ្ឋទាំងអស់មានសេរីភាព ក្នុងការជ្រើសរើសបែបបទនៃការដោះស្រាយវិវាទទៅតាមការចង់បានរបស់ខ្លួន ហើយបែបបទទាំងនោះត្រូវទទួលស្គាល់ដោយអង្គការសហប្រជាជាតិ។ ប៉ុន្តែការដោះស្រាយជម្លោះដោយសន្តិវិធីរវាងរដ្ឋនិងរដ្ឋនេះ បានក្លាយជាគោលការណ៍អន្តរជាតិជាសកលតាំងពីឆ្នាំ ១៨៩៩ មកម្ល៉េះ តាមរយៈអនុសញ្ញាទីក្រុងឡាអេ។ ជាទូទៅ ការដោះស្រាយជម្លោះរវាងរដ្ឋនិងរដ្ឋដោយសន្តិវិធីតែងតែដំណើរការទៅតាមដំណាក់កាលរបស់វា។

នៅក្នុងសេចក្តីប្រកាសរបស់ មហាសន្និបាតសហប្រជាជាតិ ស្តីពីសិទ្ធិរស់នៅក្នុងសន្តិភាពរបស់ប្រជាជន ក្នុងដំណោះស្រាយលេខ ៣១/៩ កាលពីថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ១៩៨៤ បានអះអាងពីការហាមឃាត់ រាល់ការប្រើប្រាស់កម្លាំងទ័ពមកដោះស្រាយជម្លោះ។ ធម្មនុញ្ញនៃសហប្រជាជាតិទទួលស្គាល់ការប្រើប្រាស់កម្លាំងទ័ពតែក្នុងករណីមួយប៉ុណ្ណោះ គឺនៅក្នុងករណីសកម្មភាពយោធាដោយបង្ខំ ដើម្បីការពារខ្លួនស្របច្បាប់ជាឯកត្តជន ឬជាសមូហភាព ឬក៏ជាសកម្មភាពដោយបង្ខំនោះគឺត្រូវរៀបចំដោយអង្គការតំបន់។

## ១.២. សេរីភាពក្នុងការស្វែងរកវិធីដោះស្រាយជម្លោះដោយសន្តិវិធី

លក្ខណៈដាច់ខាតនៃការដោះស្រាយជម្លោះដោយសន្តិវិធីនេះ ក៏មានបញ្ជាក់ផងដែរនៅក្នុងសេចក្តីប្រកាសទាក់ទងទងទៅនឹងគោលការណ៍នៃច្បាប់អន្តរជាតិ ស្តីពីទំនាក់ទំនងជាមិត្តភាព និងសហប្រតិបត្តិការ ដែលអនុម័តដោយមហាសន្និបាតនៃសហប្រជាជាតិ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៧០។ រដ្ឋភាគច្រើនដោះស្រាយជម្លោះទៅតាមអនុសញ្ញាពហុភាគី។

ឧទាហរណ៍៖ អនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៨៩៩ និង១៩០៧ និងកតិកាសញ្ញា Bogota ថ្ងៃទី ៣០ ខែមេសាឆ្នាំ១៩៤៨ សើរើឡើងវិញដោយពីធីសារ Buenos Aires ឆ្នាំ១៩៦៤នៅអាមេរិកឡាទីន។

ការជ្រើសរើសដំណោះស្រាយជម្លោះដោយសន្តិវិធី រដ្ឋស្ម័គ្រចិត្តជ្រើសរើសយកវិធីនយោបាយ ជាជាងយកវិធីគតិយុត្តមកដោះស្រាយ ដើម្បីរក្សាអធិបតេយ្យរបស់ខ្លួន។ តាមធម្មតា រាល់ជម្លោះទាំងអស់មានលក្ខណៈនយោបាយផង និងលក្ខណៈគតិយុត្តផង។ នៅក្នុងធម្មនុញ្ញនៃសហប្រជាជាតិ ក៏មានចែងផងដែរថា គ្មានបទបញ្ញត្តិណាមួយ នៃធម្មនុញ្ញបច្ចុប្បន្នរបស់ខ្លួន ហាមឃាត់មិនអោយសមាជិកទាំងឡាយ នៃអង្គការសហប្រជាជាតិ ប្រគល់ការដោះស្រាយ នៃការខ្វែងគំនិតយោបល់របស់ខ្លួន ទៅតុលាការដទៃទៀត ដោយសំអាងទៅកិច្ចព្រមព្រៀងដែលមានរួចមកហើយ ឬដែលនឹងអាចសំរេចបានទៅអនាគតនោះទេ។[1]

## កថាខណ្ឌទី ២៖ ដំណោះស្រាយតាមផ្លូវតុលាការ

ជាធម្មតានៅពេលដែលមានជម្លោះ គេតែងស្វែងរកនូវដំណោះស្រាយក្រៅប្រព័ន្ធតុលាការអោយអស់ពីលទ្ធភាពសិន បើយន្តការនោះវាគ្មានប្រសិទ្ធភាពទេ ទើបគេស្វែងរកនូវការអន្តរាគមន៍ពីសំណាក់អំណាចតុលាការ។ កាលពីឆ្នាំ ១៨៩៩ រដ្ឋមានយន្តការតុលាការអចិន្ត្រៃយ៍អាជ្ញាកណ្តាល (PCA) ប៉ុន្តែក្រោយពីសង្គ្រាមលើកទី១បញ្ចប់ទៅ យន្តការថ្មីមួយទៀត គឺតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ(PCIJ) ត្រូវបានបង្កើតឡើង ដែលបន្តយុត្តាធិការរហូតដល់ឆ្នាំ១៩៤៦។ ចាប់ពីឆ្នាំ ១៩៤៦ មក គឺក្រោយលោកលើកទី២ យន្តការដែលមានប្រសិទ្ធិភាពបំផុតសម្រាប់ដោះស្រាយនូវវិវាទអន្តរជាតិនោះគឺ តុលាការយុត្តិធម៌អន្តរជាតិ (ICJ) ដែលមានទីតាំងស្ថិតនៅក្នុងទីក្រុងឡាអេប្រទេសហូឡង់។ រដ្ឋនានា បានដាក់ជម្លោះរបស់ខ្លួនទៅក្នុងតុលាការយុត្តិធម៌អន្តរជាតិជាបន្តបន្ទាប់ ហើយការដោះស្រាយមានប្រសិទ្ធិភាពជាក់ស្តែង បើទោះបីជានីតិវិធី មានភាពយូរបន្តិចក្តី។ ការកើតឡើងនៃជម្លោះបន្តបន្ទាប់ គឺមូលហេតុបណ្តាលមកពីបច្ចុប្បន្ននេះ បច្ចេកវិទ្យាកាន់តែទំនើប ការដណ្តើមផលប្រយោជន៍គ្នា ការប្រកួតប្រជែងនូវមនោគមវិជ្ជានយោបាយ គឺសុទ្ធតែជាមូលហេតុចម្បងនៃជម្លោះដែលកើតមានឡើងនាពេលបច្ចុប្បន្ននេះ។ យ៉ាងណាក្តី ប្រទេសមហាអំណាចមួយចំនួន ក៏

[1] មាត្រា ៩៥ ធម្មនុញ្ញនៃសហប្រជាជាតិ

មិនចង់ជ្រើសរើសយកយុត្តាធិការតាមផ្លូវតុលាការដែរ ដោយសារចង់ប្រើអំណាចរបស់ខ្លួន ដើម្បីទាញយកផលប្រយោជន៍ច្រើនពីបណ្តារដ្ឋតូចៗ ដែលមានតួរយ៉ាងដូចជាប្រទេសចិនជាដើម ដែលកំពុងតែមានជម្លោះក្នុងសមុទ្រចិនខាងត្បូងជាឧទាហរណ៍ស្រាប់។ បច្ចុប្បន្ននេះ មានរឿងក្តីចំនួន ១៣ មកពីបណ្តារដ្ឋផ្សេងៗនៅលើពិភពលោក កំពុងដំណើរការនៅក្នុងតុលាការយុត្តិធម៌អន្តជាតិ។[2] ដូចនេះហើយ យើងឃើញថានាពេលបច្ចុប្បន្ននេះ យន្តការដោះស្រាយជម្លោះតាមផ្លូវតុលាការមានប្រសិទ្ធិភាពបំផុត គឺមានតែតុលាការយុត្តិធម៌អន្តរជាតិនេះហើយ ព្រោះថាវាជាស្ថាប័នកំពូលមួយក្នុងចំណោមស្ថាប័នផ្សេងទៀតរបស់អង្គការសហប្រជាជាតិ ដែលមានរដ្ឋជាច្រើនទទួលស្គាល់។ ហើយសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ គឺមានអនុភាពចាប់បង្ខំ ប្រសិនបើរដ្ឋផ្សេងៗមិនទទួលស្គាល់នូវសេចក្តីសម្រេចនេះទេ ក្រុមប្រឹក្សាសន្តិសុខគឺជាអ្នកចាប់បង្ខំអោយអនុវត្តនូវសេចក្តីសម្រេចនេះ។

[2] http://www.icj-cij.org (ចូលទស្សនាថ្ងៃទី ៩ ខែមិថុនា ២០១៤)

# ជំពូកទី២៖ យន្តការនៃការដំណោះស្រាយជម្លោះអន្តរជាតិ

## ផ្នែកទី១៖ ដំណោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការ

ជម្លោះ ជាបញ្ហាមួយដែលអន្តរជាតិមិនអាចជៀសវាងបាននៅក្នុងជីវភាពរស់នៅ។ ជម្លោះអន្តរជាតិអាចកើតឡើង នៅពេលមនុស្សមានអន្តរកម្មជាមួយគ្នា ដែលភាគច្រើនកើតឡើងរវាងប្រទេសទាំងឡាយនៅលើពិភពលោក។

ការដោះស្រាយជម្លោះអន្តរជាតិតាមផ្លូវច្បាប់ ជាយន្តការមួយដែលប្រទេសទាំងអស់នៅលើពិភពលោកបានយកមកអនុវត្តន៏។យ៉ាងហោចណាស់ ជម្លោះអន្តរជាតិត្រូវបានគេរកឃើញថា មានដំណោះស្រាយជម្លោះចំនួនប្រាំ ដែលប្រទេសទាំងឡាយ នៅលើពិភពលោកនិយមយកមកប្រើប្រាស់រួមមានដូចជា៖ការចរចារ ការសម្រុះសម្រួលនិងសន្ធានកម្ម ការអង្កេត ការផ្សះផ្សារ និងការដោះស្រាយតាមប្រព័ន្ធតុលាការ។ ក្នុងចំនោមយន្តការទាំងប្រាំ ខាងលើ មានតែយន្តការបួនប៉ុណ្ណោះដែលជាយន្តការដោះស្រាយក្រៅប្រព័ន្ធតុលាការ។[3]

ប្រភេទទាំងអស់នៃដំណោះស្រាយជម្លោះតាមផ្លូវច្បាប់ លើកលែងតែការចរចាចេញសុទ្ធតែប្រើភាគីទីបីអព្យាក្រឹតម្នាក់ ឬភាគីអព្យាក្រឹតអោយជួយដោះស្រាយជម្លោះរបស់គេ។ ភាគីអព្យាក្រឹតអនុវត្តវិធានខ្លះៗនៅក្នុងអន្តរកម្ម ដែលត្រូវប្រើដោះស្រាយជម្លោះ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពហើយមានភាពត្រឹមត្រូវនិង យុត្តិធម៌។ ភាគីអព្យាក្រឹត ជួបជាមួយភាគីស្ថិតនៅក្នុងជម្លោះដើម្បីរកអោយឃើញថា តើជម្លោះអំពីអ្វីហើយភាគីអព្យាក្រឹតអាច លើកសំណើអំពីមតិរបស់ខ្លួនស្តីពីជម្លោះនិង អាចធ្វើសេចក្តីសម្រេចថាតើស្ថានភាពរបស់ភាគីណាដែលត្រឹមត្រូវ។ នៅក្នុងប្រភេទដំណោះស្រាយជម្លោះនីមួយៗដែលទាក់ទងភាគីអព្យាក្រឹត ការសំខាន់គឺភាគីអព្យាក្រឹតត្រូវតែមិនលំអៀង។ ប្រសិនបើភាគីអព្យាក្រឹត លំអៀងទៅរកភាគីណាមួយដោយសារហេតុផលអ្វីក្រៅពីមូលហេតុនៃការទាមទាររបស់ភាគីសាមី ពេលនោះភាគីអព្យាក្រឹតពិតជាមិន "អព្យាក្រឹត" ទេ។ ជម្លោះអន្តរជាតិនោះមិនទំនង ជាអាចត្រូវបានដោះស្រាយដោយត្រឹមត្រូវទាល់តែសោះ ហើយទំនុកចិត្តទៅលើទម្រង់ដោះស្រាយជម្លោះអន្តរជាតិប្រភេទនេះនឹងត្រូវចុះថយ។

គេអាចនិយាយថា វិធីដោះស្រាយជម្លោះអន្តរជាតិតាមផ្លូវច្បាប់ស្ថិតនៅលើខ្សែមួយ គ្មានដើមគ្មានទីបញ្ចប់ ហើយអំណាចរបស់ភាគីអព្យាក្រឹតចេះតែកើនឡើងកាលបើគេចេះតែធ្វើចលនាទៅមុខលើខ្សែនោះ។ នៅក្នុងការចរចាមិនអាចមានភាគីអព្យាក្រឹតទេ។ មានតែភាគីជម្លោះប៉ុណ្ណោះ

[3]មូលនិធិអាស៊ី. ២០០១. *ដំណោះស្រាយស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ*. ភ្នំពេញ៖ រោងពុម្ពអន្តរជាតិ

ដែលចូលរួមក្នុងដំណើរការព្យាយាមដោះស្រាយជម្លោះរបស់ពួកគេ។ នៅក្នុងទម្រង់នៃសន្ធានកម្មភាគច្រើនដែលគេអាចហៅផងដែរបានថាការផ្សះផ្សា ភាគីអព្យាក្រឹតជួបជាមួយភាគីជម្លោះ ហើយដាក់អោយអនុវត្តវិធានជាមូលដ្ឋានស្នើរជូនមតិអំពីចំណុចខ្លាំង ស្តីពីការលើកហេតុផលមកសំអាងរបស់ភាគីនីមួយៗ ហើយស្នើរឡើងនូវដំណោះស្រាយដែលអាចធ្វើទៅកើត។ នៅក្នុងមជ្ឍត្តវិនិច្ឆ័យវិញ ភាគីទីបីដាក់អោយអនុវត្តវិធានជាមូលដ្ឋាន ហើយអាចស្នើរជូនមតិនិងដំណោះស្រាយប៉ុន្តែភាគីអព្យាក្រឹតធ្វើសកម្មភាពច្រើនជាងមុន ហើយជាក់ស្តែងពិតជាបានធ្វើសេចក្តីសម្រេចអំពីជម្លោះអន្តរជាតិនោះ។ ប្រសិនបើភាគីជ្រើសយកមជ្ឍត្តវិនិច្ឆ័យដែលមិនបាច់ប្រតិបត្តិតាម ពួកគេមិនបាច់យល់ព្រមទទួលយកសេចក្តីសម្រេចរបស់មជ្ឍត្តករសោះឡើយ ហើយពួកគេនៅតែអាចឡើងតុលាការបានដដែល។ ក៏ប៉ុន្តែប្រសិនបើភាគីជ្រើសរើសយកមជ្ឍត្តវិនិច្ឆ័យដែលប្រតិបត្តិតាម ពួកគេត្រូវព្រមទទួលយកសេចក្តីសម្រេចរបស់មជ្ឍត្តវិនិច្ឆ័យរបស់មជ្ឍត្តករ ដែលជាទូទៅអាចដាក់អោយអនុវត្តតាមបាននៅតុលាការ។ ហើយនៅក្នុងដំណោះស្រាយជម្លោះអន្តរជាតិតាមប្រព័ន្ធតុលាការ ចៅក្រមជាអ្នកដាក់អោយអនុវត្តវិធានជាមូលដ្ឋាន អាចស្នើរជូនមតិ និងដំណោះស្រាយហើយធ្វើសេចក្តីសម្រេចស្តីពីជម្លោះដែលភាគីត្រូវប្រតិបត្តិតាម។

ដើម្បីអោយកាន់តែយល់ច្បាស់ ពីការដោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការគឺមាននីតិវិធីជាច្រើនដូចជា ការចរចា ការសម្រុះសម្រួលនិងសន្ធានកម្ម ការអង្កេត និងការផ្សះផ្សា។

## កថាខណ្ឌទី១៖ ការដោះស្រាយជម្លោះអន្តរជាតិតាមការចរចា

ជម្លោះមួយត្រូវបានអោយនិយមន័យយ៉ាងប្រាកដប្រជាមួយ ដែលជាការមិនព្រមព្រៀងគ្នាទាក់ទងនឹងបញ្ហាអង្គហេតុនៃច្បាប់ ឬនយោបាយនៅពេលការលើកឡើង ឬការអះអាងរបស់ភាគីណាមួយត្រូវបានបដិសេធចោល ការលើកឡើងប្រឆាំងតទល់គ្នា ឬត្រូវបានបដិសេធចោលដោយភាគីម្ខាងទៀត។ បើសិនយើងធ្វើការគិតពិចារណាអោយបានវែងឆ្ងាយ ជម្លោះអន្តរជាតិអាចនៅតែបន្តដរាបណាវាពាក់ព័ន្ធនឹងបញ្ហារដ្ឋាភិបាល ស្ថាប័នផ្សេងតួអង្គយុត្តាធិការដែលស្ថិតនៅផ្នែកផ្សេងៗនៅលើពិភពលោកដែលយើងមិនអាចគេចរួច។ ជាការពិតណាស់ ជម្លោះគឺផ្នែកមួយដែលជៀសមិនរួចនៅក្នុងទំនាក់ទំនងអន្តរជាតិ ដូចជម្លោះរវាងបុគ្គលឯកជន ដែលមិនអាចជៀសរួចនៅក្នុងទំនាក់ទំនងក្នុងស្រុកដែរ។ ដូចគ្នានេះដែរ រដ្ឋនីមួយៗតែងចង់បានដូចគ្នានូវអ្វីមួយដែលស្ថានភាពនោះបំពេញមិនគ្រប់គ្រាន់សម្រាប់គេ។ លើសពីនេះទៅទៀត មនុស្សទាំងអស់តែងមានភាពមិនចុះសម្រុងនិងគ្នាក្នុងការប្រើប្រាស់ដីធ្លី លុយកាក់ជាដើម។ ដូចគ្នានេះដែរ រដ្ឋនីមួយៗតែងមានជម្លោះ

កើតឡើងដោយការមិនចុះសម្រុងគ្នាក្នុងការប្រើប្រាស់ព្រំប្រទល់ដូចជា ដែនដីគោក ទន្លេ សមុទ្រ និងភ្នំជាដើម។

ការចរចាប្រាកដជាវិធីមួយក្នុងចំណោមវិធីសាស្ត្រនៃការសហប្រតិបត្តិការអន្តរជាតិ ដ៏ចាស់មួយ ដែលបង្កប់អត្ថន័យបំផុត។ សម្រាប់ជម្រើសរបស់រដ្ឋទាំងឡាយ ដែលមានជម្លោះជាមួយគ្នាត្រូវគេផ្តល់អាទិភាពនូវការចរចា ជាមធ្យោបាយមួយដ៏មានសន្តិភាព ដូចពាក្យបុរាណខ្មែរមួយបានពោលថា "**អត្តាហិ អត្តនោនាថោ**" មានន័យថា ខ្លួនទីពឹងខ្លួន គឺថាមុនរដ្ឋដែលមានជម្លោះរត់ទៅពឹងរដ្ឋដ៏ទៃ ឬអង្គការអន្តរជាតិផ្សេង ខ្លួនត្រូវខិតខំប្រឹងធ្វើការដោះស្រាយតាមការចរចាអោយអស់លទ្ធភាពសិន តាមរយៈតំណាងរដ្ឋាភិបាលរៀងៗខ្លួន។ ជាសក្ខីភាព ការដោះស្រាយជម្លោះដោយសន្តិវិធីតាមការចរចាតាមផ្លូវការទូតត្រូវបានគេចែងក្នុងសន្ធិសញ្ញាអន្តរជាតិជាច្រើន។

## ១.១. មូលដ្ឋាននៃការចរចា

ជាក់ស្តែងណាស់ មូលដ្ឋាននៃការចរចាគឺសំដៅទៅដល់មូលដ្ឋានចម្បងមុនឈានទៅដល់ការចរចាផ្លូវការដូចជាភាគីអាចសញ្ជឹងគិតជាមុន ថាតើគូភាគីត្រូវចរចាលើចំណុចណាខ្លះ ជាបឋម ហើយចំនុចទាំងនោះ មានចរចានៅក្នុងសន្ធិសញ្ញាអន្តរជាតិណាខ្លះ។ មូលដ្ឋាននៃការចរចាចេញពីទំនៀមទំលាប់អន្តរជាតិនិងសន្ធិសញ្ញាមួយចំនួនផង។មាត្រា៨៤ នៃអនុសញ្ញាទីក្រុងវីយែន ចុះថ្ងៃទី១៥ខែមិនាឆ្នាំ១៩៧៥ បានបើកសិទ្ធិអោយអង្គការអន្តរជាតិសម្រុះសម្រួលចរចារវាង រដ្ឋនិងរដ្ឋ។[4] ភាគីអាចធ្វើការចរចាតាមវិធីសាស្ត្រពីរយ៉ាង៖ទីមួយគឺវិធីសាស្ត្រចរចាបែប**ឈ្នះ-ចាញ់**(win-lose) និងទី២ វិធីសាស្ត្រចរចាបែប **ឈ្នះ-ឈ្នះ**(win-win)។[5]

ជាដំបូងក្នុងដំណាក់ការចចារបែប ឈ្នះ-ចាញ់ភាគីវិវាទសន្មត់ថាមានធនធាន ដែលមានចំនួនជាក់លាក់មួយដែលពួកគេត្រូវបែងចែករវាងគ្នា និងគ្នា។ ប្រសិនបើភាគីម្ខាងទទួលបានកាន់តែច្រើន ភាគីម្ខាងទៀតទទួលបានកាន់តែតិច។ ភាគីនីមួយៗបានកំនត់ជំហររបស់ខ្លួនក្នុងការទទួលយក និងបោះបង់ ប៉ុន្តែការចចាបែប ឈ្នះ-ចាញ់ ភាគីវិវាទនីមួយៗមិនគិតអ្វីទាំងអស់គឺធ្វើយ៉ាងណាយកឈ្នះភាគីម្ខាងទៀតឲ្យបាន។

តាមការសិក្សាយើងអាចលើកយកសេណារីយ៉ូមួយ ដែលរដ្ឋភាគីម្ខាងបានអះអាងថា ខ្លួនបានខាតបង់ទឹកប្រាក់ចំនួន ៥០.០០០.០០០ (ហាសិបលានដុល្លាអាមេរិច) ដោយសារតែរដ្ឋមួយ

[4]មាត្រា៨៤ នៃអនុសញ្ញាទីក្រុងវីយែន ឆ្នាំ១៩៧៥

[5]Roy J.Lewicki, Bruce Barry, David M. Saunders, *សៀវភៅ Essential of Negotiation*, Four Edition 2007

ទៀត។ នៅពេលពួកគេទាំងពីរធ្វើការចរចា ពួកគេប្រាកដជាប្រកាន់ជំហររៀងៗខ្លួនដើម្បីត្រៀមនិងខាតបង់។ ភាគីទាំងពីរនិងព្យាយាមស្វះស្វែងរកមធ្យោបាយដើម្បីបញ្ចុះបញ្ចូលគ្នាទៅវិញទៅមកក្នុងគោលបំណងទាញយកប្រយោជន៍ពីរដ្ឋម្ខាងទៀតឲ្យបាន។ ការទាមទាយកប្រយោជន៍រៀងៗខ្លួននេះហៅថា "**ការចរចាបែបឈ្នះចាញ់**"។

ចំនែកឯការចរចាបែប ឈ្នះ-ឈ្នះវិញ ភាគីទាំងពីរមានលក្ខណៈសហការគ្នាក្នុងការចរចាដើម្បីសម្រេចឲ្យបានលទ្ធផលផ្លែផ្កាទាំងសងខាង។ គេត្រូវមានឆន្ទៈទុកចិត្តគ្នាទៅវិញទៅមកក្នុងការដោះស្រាយជម្លោះ។ ភាគីនៃវិវាទត្រូវធ្វើការសម្បទាននូវផលប្រយោជន៍ឲ្យគ្នាទៅវិញទៅមក ដើម្បីឲ្យការចរចាទទួលបានជោគជ័យទាំងសងខាង។ បន្ទាប់ពីភាគីបានចរចាដោយប្រកាន់យកការចរចាខាងលើ ពួកគេនឹងរីករាយក្នុងការទទួលយកលទ្ធផលដែលសម្រេចឡើង។

ជាងនេះទៅទៀតនៅពេលភាគីកំពុង មានជម្លោះនឹងគ្នា ដាច់ខាតរដ្ឋទាំងសងខាងត្រូវមានកាតព្វកិច្ចបង្ខំ ឲ្យមានការចរចាកើតឡើង ពីព្រោះនេះគឺជាកម្រិតអប្បបរមាដែលភាគីត្រូវធ្វើឡើងដើម្បីដោះស្រាយជម្លោះរបស់ខ្លួន ដោយសន្តិវិធី។ បែបនេះការចរចាដោយផ្ទាល់រវាងរដ្ឋ ដែលកំពុងមានជម្លោះបង្កើតបានជាបច្ចេកទេសនៃច្បាប់រួម ពោលគឺវាត្រូវបាន គេអនុវត្តនូវរាល់កាលៈទេសៈទាំងអស់ទោះបីគ្មានអត្ថបទបញ្ជាក់ក៏ដោយ។ ការចរចាក៏ជាធាតុផ្សំនៃការសន្យា ដ៏ទូលាយមួយរបស់រដ្ឋ វាគឺជានិវិធីដំបូងហើយចាំបាច់មុនផ្ដើមនីតិវិធីស្មុគស្មាញករណីដូចជាមុនពេលធ្វើការដោះស្រាយជម្លោះអន្តរជាតិតាមផ្លូវតុលាការ គេតែងបង្ខំឲ្យភាគីជម្លោះធ្វើការចរចាជាមុនសិន។

ចំណែកឯករណី Mavrommatis Palestine Concession (Greece vs United Kingdom) ឆ្នាំ ១៩២៤តុលាការ(PCIJ) បានធ្វើការសម្របសម្រួលឲ្យភាគីរដ្ឋនៅក្នុងជម្លោះគោរពឲ្យបាននូវការទាមទារ ក្នុងការដោះស្រាយជម្លោះដោយសន្តិវិធីតាមបែបចរចា។[6] នៅក្នុងកិច្ចព្រមព្រៀងឧបតោភាគីដែលធ្វើឡើងដោយសហរដ្ឋអាមេរិច ក្នុងគោលបំណងបញ្ចៀស ជម្លោះយុត្តាធិការដើម្បីមានការគោរពនិងប្រតិបត្តិតាមច្បាប់។[7] ការពិតត្រូវបានបង្ហាញតាមរយៈការចរចា នៅពេលដែលគូភាគីមានឆន្ទៈ ឬមានកាតព្វកិច្ចពិភាក្សាទៅលើបញ្ហាជម្លោះ ដោយប្រើយន្តការតាមបែបចរចា។

ការចរចា ក៏តម្រូវឲ្យមានការចូលរួមពីភាគីច្រើន វាអាស្រ័យទៅលើចំនួនភាគីក្នុងជម្លោះ។ នៅក្នុងពេលថ្មីៗនេះការចូលរួមក្នុងការចរចា តែងកំណត់យកកន្លែងមួយសំរាប់ធ្វើការចរចានោះគឺ

[6] The Settlement of dispute in International Law
[7] The texts of agreements as printed as followed by US-Australia 1982

អង្គការសហប្រជាជាតិ ដែលមានការអន្តរាគមន៍ពីអគ្គលេខាធិការដ្ឋាន(Secretary General)អង្គការសហប្រជាជាតិជាភាគីទីបី ដើម្បីធ្វើការចរចា។

កាតព្វកិច្ចបង្ខំ ឲ្យចរចាមិនដែលមានទម្រង់ច្បាស់លាស់ឡើយ ប៉ុន្តែគេអាចចែកជាកម្រិត។ នៅក្នុងកម្រិតអប្បបរមា កាតព្វកិច្ចបង្ខំឲ្យចរចាដែលជាកតព្វកិច្ចគ្មានលក្ខខណ្ឌមិនត្រឹមតែបង្ខំឲ្យភាគីចាប់ផ្តើមចរចាប៉ុណ្ណោះទេ តែត្រូវបង្ខំឲ្យភាគីបន្តការចរចាហូតទាល់តែ ធ្វើយ៉ាងណាសម្រេចជាផ្លែផ្កាបាន ពោលគឺ សម្រេចមានការព្រមព្រៀងរវាងភាគីពាក់ព័ន្ធ។ ប្រសិនបើមានការបរាជ័យក្នុងការចរចា តតិយភាគីណាមួយត្រូវធ្វើការផ្ទៀងផ្ទាត់ថា តើភាគីបានគោរពកាតព្វកិច្ចដោយស្មោះត្រង់ហើយឬនៅ ដើម្បីចៀសវាងកុំឲ្យមានការចោទប្រកាន់គ្នាទៅវិញទៅមក។ នៅកម្រិតអតិបរមាវិញ ការសន្យាចូលចរចាឬអន្តរាគមន៍ពីតតិយភាគីបង្កើតបានជាកាតព្វកិច្ចមានលក្ខខណ្ឌ ពោលគឺភាគីមិនអាចមានគំនិតអាក្រក់ ឬធ្វើឲ្យខូចប្រយោជន៍ដល់ការចរចាទេ តែភាគីត្រូវធានាធ្វើយ៉ាងណាដើម្បីធ្វើឲ្យការចរចាដំណើរការបានល្អស្របតាមគោលការណ៍ច្បាប់។[8]

### ១.២. អាជ្ញាធរមានសមត្ថកិច្ចក្នុងការចរចា

យោងតាមអនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញាឆ្នាំ១៩៦៩ ពាក្យថា "ភាគី" សំដៅដល់រដ្ឋដែលទទួលស្គាល់សន្ធិសញ្ញា ហើយសន្ធិសញ្ញានោះបានចូលជាធរមាន។ ដូច្នេះពាក្យថា "ភាគីចរចា" មានន័យថារដ្ឋដែលបានចូលរួមតាក់តែង និងយល់ព្រមលើអត្ថបទនៃសន្ធិសញ្ញា។[9] តើនរណាខ្លះអាចជាភាគីចរចានៅក្នុងជម្លោះអន្តរជាតិមួយ? ការដោះស្រាយជម្លោះក្នុងស្រុកមួយ ជាទូទៅគេច្រើនឲ្យរូបវន្តបុគ្គលនៃជម្លោះផ្ទាល់ ឬមេធាវីតំណាងសម្រាប់ធ្វើការចរចា។[10] មិនខុសអ្វីពីជម្លោះអន្តរជាតិនោះទេ គឺរដ្ឋភាគីនៃជម្លោះជាអ្នកចរចាដោយគ្រាន់តែថា រដ្ឋមិនអាចទៅចរចាទេ ព្រោះរដ្ឋគ្រាន់តែជាឈ្មោះអរូបីតំណាងឲ្យប្រជាជនមួយក្រុម ដែលរស់នៅលើទឹកដីមួយក្រោមការគ្រប់គ្រងរបស់ថ្នាក់ដឹកនាំនយោបាយប៉ុណ្ណោះ។ ដូច្នេះហើយទើបគេទាមទាឲ្យមានអ្នកតំណាងមួយដើម្បីធ្វើកិច្ចចរចា ឥស្សរភាពនៃអ្នកចរចាមានភាពប្លែកៗពីគ្នា គឺមានតាំងពី ប្រមុខរដ្ឋ ឬប្រមុខរដ្ឋាភិបាល ប្រធានាធិបតី នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស រហូតដល់ភ្នាក់ងារជំនាញសាធារណៈ ដូច

[8] PCIJ រឿងក្តី ចរាចរណ៍ផ្លូវដែករវាង ប្រទេសទុយអានីល និងប៉ូឡូញ ១៥. ១០.១៩៣១

[9]មាត្រា២ អនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា ឆ្នាំ១៩៦៩

[10]មាត្រា២ អនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា ឆ្នាំ១៩៦៩

ជាឯអគ្គរដ្ឋទូតនិង អ្នកការទូត។ ចំពោះជម្លោះមួយចំនួន រដ្ឋតែងតែជ្រើសរើសបុណ្ណទូតឲ្យធ្វើការចរចាណាមួយជាកំណត់។[11]

ប្រមុខរដ្ឋសំដៅជាពិសេស គឺប្រទេសដែលមានព្រះមហាក្សត្រសោយរាជ្យ ហើយទ្រង់ជាប្រមុខរដ្ឋនៃរដ្ឋមួយ។ ឧទាហរណ៍៖ ព្រះបាទនរោត្តមសីហមុនី នៃព្រះរាជាណាចក្រកម្ពុជា ព្រះមហាក្សត្រី Elizabeth នៃប្រទេសអង់គ្លេសជាដើម។ ចំណែកឯប្រមុខរដ្ឋាភិបាលវិញ ជាក់ស្តែងណាស់សំដៅលើថ្នាក់ដឹកនាំគោលនយោបាយក្បាលម៉ាស៊ីនរបស់ប្រទេស ដែលជានាយករដ្ឋមន្ត្រី ឬប្រធានាធិបតី។

រដ្ឋមន្ត្រីក្រសួងការបរទេស គឺជាគណៈរដ្ឋមន្ត្រី ក្នុងការជួយដល់គោលនយោបាយការបរទេសនៃរដ្ឋអធិបតេយ្យមួយ។ រដ្ឋមន្ត្រីការបរទេសភាគច្រើន គេតែងចាត់ទុកមានឋានៈខ្ពស់បន្ទាប់ពីរដ្ឋាភិបាល(អាចបន្ទាប់ពីនាយករដ្ឋមន្ត្រី ឬប្រធានាធិបតី)។ ដូចជានៅឥណ្ឌា រដ្ឋមន្ត្រីក្រសួងការបរទេស សំដៅរដ្ឋមន្ត្រីកិច្ចការផ្ទៃក្រៅ។[12] នៅថ្ងៃទី៤ កុម្ភៈ ២០១១ កម្ពុជា-ថៃ បានបើកកិច្ចប្រជុំស្តីពីគណៈកម្មការចម្រុះសហប្រតិបត្តិការទ្វេភាគីលើកទី៧ ដែលកិច្ចប្រជុំនិងត្រូវផ្តោតលើសហប្រតិបត្តិការរវាងប្រទេសទាំងពីរស្តីពីដំណោះស្រាយព្រំដែន។ កិច្ចប្រជុំគណៈកម្មការចម្រុះលើកទី៧នេះភាគីកម្ពុជាដឹកនាំដោយលោកឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង រដ្ឋមន្ត្រីក្រសួងការបរទេស រីឯភាគីថៃដឹកនាំដោយលោក កាស៊ិត ភីរម្យ៉ា រដ្ឋមន្ត្រីការបរទេសថៃ ព្រមទាំងមន្ត្រីសំខាន់ៗក្រសួងការបរទេស នៃប្រទេសទាំងពីរផងដែរ។

ចំណែកឯ អ្នកទទួលបានសិទ្ធិប្រទាន ក៏អាចជាអ្នកតំណាងនៅក្នុងការចរចានៃជម្លោះផងដែរ។ ពាក្យថា "សិទ្ធិប្រទាន" មានន័យថា ជាឯកសារដែលចេញពីអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋក្នុងការតែងតាំងបុគ្គលណាម្នាក់ ឬមួយក្រុមដែលតំណាងឲ្យរដ្ឋនៅក្នុងការចរចា អនុម័ត ឬ បញ្ជាក់ភាពត្រឹមត្រូវរបស់អត្ថបទ នៃសន្ធិសញ្ញា សំរាប់បង្ហាញនូវការយល់ព្រមទទួលស្គាល់សន្ធិសញ្ញា ឬបំពេញកិច្ចផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងសន្ធិសញ្ញា។ ដូច្នេះ អ្នកទទួលបានសិទ្ធិប្រទានគឺសំដៅទៅលើអ្នកដែលទទួលបានឯកសារ ដែលចេញពីរអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋ ក្នុងការតែងតាំងជាតំណាងពេញកាតព្វកិច្ចនៃការចរចា ឬយើងអាចនិយាយបានថា អ្នកទទួលបានសិទ្ធិប្រទានសំដៅលើបុណ្ណទូត ដែលវចនានុក្រមច្បាប់មានន័យថា បុគ្គលដែលទទួលបានអំណាចពីរដ្ឋាភិបាល

[11]មាត្រា៣ អនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់ទំនាក់ទនងការទូត ឆ្នាំ ១៩៦១

[12]External Affair Retrieved from http://en.wikipedia.org/wiki/Foreign_ Minister(ចូលទស្សនាថ្ងៃទី ២៥ ឧសភា ២០១៤)

ក្នុងកិច្ចចរចាណាមួយដើម្បីបំពេញបេសសកម្ម។[13] បុគ្គលដែល ទទួលបានសិទ្ធិប្រទាន ឬបុណ្ណទូត អាចជាមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ជាដើម។ ទាហរណ៍៖ លោកឧបនាយករមន្ត្រី សុខ អាន បានទទួលសិទ្ធិក្នុងការចរចា និងចូលរួមប្រជុំលើកទី៣៥ នៃគណៈកម្មការបេតិភណ្ឌពិភពលោករបស់អង្គការយ៉ូណេស្កូ នាទីក្រុងប៉ារីសប្រទេសបារាំង ថ្ងៃទី២៦ និង២៧ ខែវិច្ឆិកា ឆ្នាំ២០១១។

### ១.៣. នីតិវិធីនៃការចរចា

ផ្អែកតាម Harold Saunders "យន្តការសន្តិភាព" (Peace Process) រួមមានបួនចំណុច ខុសគ្នាដូចជា៖ ការកំណត់បញ្ហា (ដំណាក់ការត្រៀម) ការប្រព្រឹត្តទៅនៃការចរចា ការបង្កើតគម្រោងចរចា និងការប្រតិបត្តិចរចាផ្សះផ្សា។ដើម្បីឲ្យកាន់តែស៊ីជម្រៅទៅលើចំណុចទាំងបួនខាងលើ យើងនឹងសិក្សាលម្អិតនូវចំណុចមួយៗដូចខាងក្រោម៖[14]

#### ១.៣.១. ដំណាក់កាលត្រៀម

ដំណាក់កាលនេះជាដំណាក់កាលកំណត់នូវបញ្ហា រួមមានការកំណត់ពីគន្លឹះ ធាតុផ្សំនៃជម្លោះ និងការឈានទៅរកទំនាក់ទំនងហេតុនិងផល ព្រមទាំងទំហំនៃបញ្ហាដែលគេស្វែងរកអង្គហេតុ វិភាគច្បាប់ ស្វែងយល់ពីផលប្រយជន៍ និងគោលដៅនៃភាគីជម្លោះ។ ក្នុងការសិក្សាគេទាមទារឲ្យផ្តល់នូវចម្លើយជាក់លាក់មួយឲ្យស្របនឹងបញ្ហាដែលបានកំណត់។ ដូចគ្នានេះដែរ ក្នុងជីវិតនយោបាយគេទាមទារនូវចម្លើយជាក់លាក់មួយ ថាតើត្រូវណែនាំ និងដោះស្រាយយ៉ាងណា? ភាពប្រកួតប្រជែង ក្នុងចំណុចទី១ នេះគឺសម្រាប់ចរចាក្នុងការបង្កើនការយល់ដឹងអំពីកម្រិតខុសៗគ្នានៅក្នុងជម្លោះនៃសហាគមន៍មួយ និងភាពខុសគ្នារវាងសហាគមន៍មួយនិងសហាគមន៍មួយទៀត។ ភាគីជម្លោះកម្រនឹងដើរស្របគ្នា ក្នុងការពង្រឹងការចរចា ហើយវានិងអាចជះឥទ្ធិពលដល់ភាគីម្ខាងទៀត។ជាលទ្ធផល ការបង្កើតឲ្យមានយុត្តសាស្ត្រចរចា ពីការប្រកួតប្រប្រជែង និងជម្លោះទស្សនៈគឺមានសារៈសំខាន់មុនស្ថានភាពទាំងឡាយកើតឡើង ដើម្បីឲ្យការចរចាមួយមានប្រសិទ្ធភាព។

#### ១.៣.២. ការប្រព្រឹត្តទៅនៃការចរចា

ក្នុងដំណាក់កាលទីពីរនេះ ការប្រព្រឹត្តទៅនៃការចរចាក្នុងការរកដំណោះស្រាយ ឬគេអាចគេអាចនិយាយបានថា មុនដំណើរការប្រព្រឹត្តទៅ "Recommitment Phrase" ។ វាពាក់ព័ន្ធនិងការបង្កើតឲ្យមានយន្តការនៃការចរចា ហើយកាលណាមានការលេចចេញនូវស្ថានភាពអត់ឱន ដើម្បីឲ្យ

---

[13]មាត្រា២ អនុសញ្ញាទីក្រុងវីយ៉ែន ស្តីពីច្បាប់សន្ធិសញ្ញា ឆ្នាំ១៩៦៩

[14]Harold Saunders, Prenegotion and Circum-negotiation :Arenas Peace Process,(Washington D.C:United State Institute of Peace Press, 1996

មានការផ្លាស់ប្តូរ រដ្ឋនីមួយៗតែងមានគំនិតនិងល្បិចកលមិនសូវចង់ធ្វើការចរចា ដោយស្មោះត្រង់ទេ។ ក្នុងការចរចាដំណាក់កាលនេះ ការផ្តើមគំនិតចរចាជាផ្លូវការ ត្រូវតែធ្វើការបញ្ចុះបញ្ចូលភាគីជម្លោះថា ផលប្រយោជន៍សំខាន់របស់ពួកគេអាចទទួលយកបានដោយពេញចិត្ត តាមរយៈការចរចានិងផ្សះផ្សា ដែលវាឆ្លើយតបនឹងសំណួរ ដែលបានចោទសួរថា តើគួរតែមានការចរចាដែរឬទេ? តើការចរចាទាំងនេះត្រូវធ្វើឡើងនៅពេលណា? នៅកន្លែងណា? ដោយរបៀបណា? ផ្អែកលើគំនិតរបស់លោក Sauders ការបង្កើតឲ្យមានយន្តការចរចា គឺជាបេះដូងនៃនីតិវិធីចរចា ប្រសិនបើគ្មានការរៀបចំនិងប្រព្រឹត្តទៅនេះទេ នោះការចរចាមិនអាចចាប់ផ្តើមបានឡើយ។ Sauders ក៏បានធ្វើការណែនាំថា មុនពេលការចរចាកើតឡើង ថ្នាក់ដឹកនាំត្រូវធ្វើការវិនិច្ឆ័យលើគន្លឹះបួនចំណុចដូចជា៖

- ស្ថានភាពបច្ចុប្បន្នមិនបន្តបម្រើផលប្រយោជន៍ភាគីម្ខាងទៀត
- ត្រូវមានការផ្សះផ្សាដោយយុត្តិធម៌បំផុត បើអាចធ្វើបាន
- ត្រូវគិតថាភាគីម្ខាងទៀតនឹងព្រមព្រៀងនូវចំណុចដែលយើងផ្សះផ្សា
- តុល្យភាពនៃកម្លាំងនឹងត្រូវអនុញ្ញាតផ្សះផ្សាដោយយុត្តិធម៌។

ដូច្នេះនៅពេលកិច្ចការចរចាចូលរួមធម្មតា ហើយបានធ្វើតាមការព្រមព្រៀងទៅតាមនីតិវិធីប្រាកដជាឈានរកដំណោះស្រាយបានជាមិនខាន។

### ១.៣.៣. គម្រោងនៃការចរចា

ចំពោះនីតិវិធីនៃ ការចរចារដោយការប្រមូលពត៌មាន គឺចូលរួមក្នុងការបង្កើតឲ្យមានគម្រោងនៃការចរចា។ នៅក្នុងដំណាក់កាលនេះ គឺសង្កត់ធ្ងន់ទៅលើការបង្កើតឲ្យមានតំណាងប្រទេសសម្រាប់ចរចា យន្តការនៃការព្រមព្រៀង និងការបង្កើតឲ្យមានការ ទទួលយកដោយពិតប្រាកដនូវគោលការណ៍ និងយុទ្ធសាស្ត្រដើម្បីដាក់ចូលក្នុងកិច្ចប្រជុំពិភាក្សាចរចា។

នៅពេលថ្លែងជាទូទៅ គេបង្កើតគោលដៅស្របមួយ ដោយមិនត្រូវការជំនួយពីខាងក្រៅប៉ុន្តែនៅពេល ដែលជម្លោះស្ថិតនៅក្នុងភាពមិនស្របគ្នាខ្លាំង ជាធម្មតាតតិយជនចាំបាច់ត្រូវបង្កើតមជ្ឈដ្ឋានព្រមព្រៀងមួយដែលមានតុល្យភាព និងយកជាការបាន។ ចំណុចដែលលំបាកជាងគេនៅក្នុងដំណាក់កាលទី ៣ នោះគឺសេចក្តីសម្រេចចុងក្រោយរបស់អ្នកចូលរួម អាចទទួលយកបាននៅតុចរចា។

### ១.៣.៤. ការប្រតិបត្តិចរចាផ្សះផ្សា

រដ្ឋជាភាគីត្រូវព្យាយាមសម្រេចឲ្យបាននូវការទទួលយក នូវដំណោះស្រាយដ៏សមស្របមួយដែលសមហេតុផលតាមរយៈការចរចា។ ក្នុងដំណាក់កាលនេះ ភាគីទាំងសងខាង អាចធ្វើការចរចាដោយខ្លួនឯងផ្ទាល់ ឬ ពឹងពាក់ភាគីទី៣ ឲ្យជួយជាសក្ខីភាពក្នុងការជជែកពិភាក្សា និង ជួយសម្រួលក្នុងការ ស្វែងរកដំណោះស្រាយនាំឲ្យមានការទទួលបានផលប្រយោជន៍ទាំងសងខាងក្នុងជំលោះ។ ការប្រមើមើល ពីកម្រិតនៃភាពជោគជ័យនៅក្នុងការចរចា គឺត្រូវពឹងផ្អែកទៅលើបញ្ហាអន្តរជាតិដែលត្រូវបានគេដឹងឮ។ ប្រសិនបើវិវាទមានការភាន់ច្រឡំ ពេលនោះ ប្រធានបទនៃការចរចា ក្លាយទៅជាធម្មតា។

ទោះបីជានៅក្នុងដំណាក់កាលចរចាផ្សះផ្សា ជាដំណាក់កាលនៃការបញ្ចប់កិច្ចចរចាដោយគ្មានការភាន់ច្រឡំ ឬ យល់ខុស ក៏យើងមិនអាចសន្និដ្ឋានបានថា ការចរចាទទួលបានជោគជ័យនោះដែរ។ មូលហេតុដោយសារតែមានភាគីម្ខាងមិនទាន់ឆ្លើយតប ឬ អនុវត្តទៅតាមអ្វីដែលខ្លួនបានសន្យា។ ប៉ុន្តែប្រសិនបើវិវាទនោះត្រូវបានគេសន្មត់ថា ជាគោលដៅនៃការចរចា មិនចុះសម្រុងនឹងគ្នា នោះការចរចាកាន់តែលំបាក។

## ១.៤. គុណសម្បត្តិ និងគុណវិបត្តិនៃការចរចា

### ១.៤.១. គុណសម្បត្តិ

បើប្រៀបធៀបជាមួយវិធីសាស្ត្រដ៏ទៃទៀត ការចរចាមានអត្ថប្រយោជន៍ជាច្រើនដូចជា៖

- ហិរញ្ញវត្ថុ៖ ការចរចា ចំណាយអស់ប្រាក់តិចជាងវិធីសាស្ត្រដោះស្រាយជម្លោះផ្សេងទៀត។ នេះជាចំណែកមួយដែលនាំឲ្យការចរចាមានប្រជាប្រិយភាព។ វាមិនមានប្រាក់ប្រដាប់ក្តី ឬ ថ្លៃចំណាយផ្សេងៗ ដូចការប្តឹងទៅតុលាការឡើយ។[15]
- ភាពឯកជន ៖ ការចរចាអាចដំណើរការជាឯកជនទាំងស្រុង ដោយគ្រាន់តែធ្វើឡើងរវាងរដ្ឋភាគី និងភាគី ឬតំណាងរបស់ពួកគេតែប៉ុណ្ណោះ។ គ្មានការចូលរួមពីតុលាការ គ្មានអ្នកសារពត៌មាន និងគ្មានការចូលរួមពីអ្នកដ៏ទៃ។ ប៉ុន្តែទោះជាមានវត្តមានភាគីទី៣ក្តី ក៏សេចក្តីលម្អិតនៃជម្លោះនឹងនៅតែជាលក្ខណៈឯកជនដដែល ដែលប្រការនេះអាចមានសារៈសំខាន់យ៉ាងខ្លាំងសម្រាប់រដ្ឋ និងទំនាក់ទំនងរបស់ពួកគេ។[16]

---

[15]មូលនិធិអាស៊ី. ២០០១. *ដំណោះស្រាយស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ.* ភ្នំពេញ៖ រោងពុម្ពអន្តរជាតិ ទំព័រ៣០

[16]មូលនិធិអាស៊ី. ២០០១. *ដំណោះស្រាយស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ.* ភ្នំពេញ៖ រោងពុម្ពអន្តរជាតិ ទំព័រ៣៥

- ភាពបត់បែន ៖ ការចរចាមានភាពបត់បែនទាំងក្នុងដំណើរការ និងលទ្ធភាព។ ទីមួយដំណើរការនៃការចរចាអាចមានភាពបត់បែនយ៉ាងខ្លាំង ពីព្រោះដូចរៀបរាប់ខាងលើ ដំណើរការអាចធ្វើឡើងក្រៅផ្លូវការ ឬជាផ្លូវការ។ ទីពីរ លទ្ធផលនៃការចរចាអាចមានលក្ខណៈបត់បែនខ្លាំងដោយសារភាគីជម្លោះផ្ទាល់ជាអ្នកឈានដល់ការសម្រុះសម្រួល ពួកគេអាចព្រមព្រៀងគ្នាលើដំណោះស្រាយផ្សេងៗជាច្រើន។
- ភាពឆាប់រហ័ស ៖ ការចរចាមានសក្តានុពលក្នុងការដោះស្រាយបញ្ហាបានយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព។ ភាគីមិនបាច់ត្រូវរង់ចាំចៅក្រម មជ្ឈត្តករ ឬសន្ធានការី ដើម្បីសវនការ និងសម្រេចលើរឿងក្តីនោះឡើយ។ បញ្ហាអាចត្រូវបានដោះស្រាយភ្លាមៗឲ្យតែមានការស្រុះស្រួលគ្នា។[17]
- ការរក្សាទំនាក់ទំនងជាបន្ត ៖ ការចរចាផ្តល់លទ្ធភាពដល់ភាគីជម្លោះ ក្នុងការរិះរកការស្រុះស្រួលមួយ ដែលអាចរក្សាទំនាក់ទំនងដែលពួកគេមាន។ ឧទាហរណ៍៖ កម្ពុជា និងថៃ មានជម្លោះពាក់ព័ន្ធនឹងជម្លោះព្រំដែន ហើយពួកគេអាចចរចាលើការព្រមព្រៀងណាមួយ និងមានលទ្ធភាពរក្សាទំនាក់ទំនងនោះ ដើម្បីឲ្យភាគីទាំងពីរនៅរក្សាការងាររបស់ខ្លួនដដែល។

### ១.៤.២. គុណវិបត្តិ

- **ការពន្យាពេល** ៖ ក្នុងការចរចា ភាគីម្ខាងអាចពន្យាពេលដំណើរការប្រសិនបើខ្លួនចង់។ នៅក្នុងស្ថានភាពចរចាមួយ គ្មានវិធីអ្វីអាចបង្ខំភាគីណាមួយឲ្យពន្លឿនសកម្មភាពបានឡើយ។ ជាលទ្ធភាពមួយដែលភាគីល្មើសមិនទាន់ប្រាកដប្រជាអំពីការស្រុះស្រួលផង ហើយបានប្រើប្រាស់ការចរចា ជាវិធីសម្រាប់ពន្យាបញ្ហា ឬគេចវេសពីបណ្តឹងតុលាការ។
- **ការអនុវត្តដំណោះស្រាយ** ៖ បន្ទាប់ពីការចរចារួច ភាគីជម្លោះអាចឯកភាពគ្នាលើកិច្ចព្រមព្រៀងស្រុះស្រួលមួយដែលត្រូវធ្វើឡើងជាលាយលក្ខអក្សរ និងមានការចុះហត្ថលេខា។ ប៉ុន្តែមួយរយៈក្រោយមក រដ្ឋភាគីណាមួយមិនគោរពតាមលក្ខខណ្ឌនៃការព្រមព្រៀង នាំឲ្យមានការប្តឹងទៅតុលាការ ដើម្បីឲ្យអង្គតុលាការចាត់វិធានការលើភាគីនោះ។
- ***ភាគីម្ខាងមានអំណាចខ្លាំងពេក*** ៖ មានកាលៈទេសៈមួយចំនួនដែលភាគីមានវិសមិតភាពនឹងគ្នាក្នុងអំណាចចរចា ជាហេតុនាំឲ្យភាគីម្ខាងមានសិទ្ធិត្រួតត្រាហួសពេក។ បើភាគីម្ខាងមានអំណាចខ្លាំជាងទាំងនយោបាយ និងសេដ្ឋកិច្ច នោះគេអាចមានអំណាចមួយដែលមានឥទ្ធិពលលើភាគីម្ខាងទៀត ដែលអាចដាក់សម្ពាធនៅពេលចរចា។ ជាលទ្ធផលភាគីដែលមានអំណាចខ្សោយអាចទទួលយក ដំណោះស្រាយមិនសមស្របមួយ។

យោងតាមការបកស្រាយខាងលើ យើងសង្កេតឃើញថាការចរចាជាវិធីសាស្ត្រសន្តិវិធីមួយដែលភាគីនៃជម្លោះនីមួយៗយកមកប្រើប្រាស់ជាដំណាក់កាលដំបូង។ ការចរចាមិនមែនជាប្រធាន

[17]មូលនិធិអាស៊ី. ២០០១. *ដំណោះស្រាយស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ*. ភ្នំពេញ៖ រោងពុម្ពអន្តរជាតិ ទំព័រ២៣

បទមួយនៃការជ្រើសរើសដោយសេរីនោះទេ ប៉ុន្តែអ្វីដែលសំខាន់គឺភាគីជម្លោះផ្ទាល់ជាអ្នកកំណត់នូវបញ្ហានៃការដោះស្រាយជម្លោះ។ ការចរចា អាចមានប្រសិទ្ធិភាព ឬ គ្មានប្រសិទ្ធិភាពអាស្រ័យលើភាគីជម្លោះ ថាតើពួកគេពិតជាមានឆន្ទៈក្នុងការចរចាដែរ ឬទេ? ជាងនេះទៅទៀត ការដោះស្រាយជម្លោះតាមការចរចានេះ កើតឡើងជាញឹកញាប់នៅក្នុងសង្គមអន្តរជាតិ ដោយសារគេសង្កេតឃើញមានគុណសម្បត្តិច្រើនជាងគុណវិបត្តិ។ ប្រសិនបើ ភាគីទាំងសងខាងមិនអាចសម្រុះសម្រួលគ្នាបានតាមការចេចាទេនោះ យើងអាចមាននីតិវិធីផ្សេងទៀតក្នុងការជួយឲ្យភាគីស្វែងរកដំណោះស្រាយដោយសន្តិវិធី ពោលគឺទាមទាឲ្យមានការអន្តរាគមន៍ពីតតិយភាគី ឬស្ថាប័នតុលាការ។

### កថាខណ្ឌទី២ ៖ ការសម្រុះសម្រួល និងសន្ធានកម្ម (Good Offices and Mediation)

ការសម្រុះសម្រួលនិងសន្ធានកម្មមានប្រភពចេញពីទំនៀមទំលាប់អន្តរជាតិ វិធីទាំងពីរនេះត្រូវបានចែងក្នុងអនុសញ្ញាទីក្រុងឡាអេ ស្តីពីការដោះស្រាយជម្លោះដោយសន្តិវិធី នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ១៨៩៩ និងថ្ងៃទី១៨ តុលា ឆ្នាំ ១៩០៧។[18]

ពាក្យថា "ការសម្រុះសម្រួល" មានន័យថា ជារាល់សកម្មភាពទាំងឡាយណា ដែលមានទំនោទៅរកការចរចារវាងរដ្ឋជម្លោះនៅក្នុងជីវិតរស់នៅ។[19] ផ្អែកតាមសៀវភៅច្បាប់ការទូត របស់លោក នួន សុធិមន្ត ២០០៤ បានឲ្យនិយមន័យ "ការសម្រុះសម្រួល" សំដៅលើការប្រើប្រាស់ភ្នាក់ងារ ឬអង្គការណាមួយដែលមិនលំអៀង ដែលជឿទុកចិត្តដោយភាគីជម្លោះទាំងពីរ ក្នុងការសម្រុះសម្រួលផ្សះផ្សា តាមរយៈការជំរុញឲ្យមានការទាក់ទងគ្នា ការធ្វើឲ្យជ្រះស្រឡះនូវបញ្ហានានា និងការប្រមូលនូវហេតុការនានា។

រីឯពាក្យថា "សន្ធានកម្ម (Mediation)" ត្រូវបានគេឲ្យនិយមន័យប្រហាក់ប្រហែលគ្នាច្រើន។ បើយោងតាម UNTERM សន្ធានកម្ម គឺជាការការដោះស្រាយជម្លោះដោយផ្ទាល់រវាងភាគីនៅលើចំនុចជាមូលដ្ឋានមួយដែលមានការស្នើរដោយសន្ធានការី។[20]

ការម្រុះសម្រួល និងសន្ធានកម្ម ជាផ្នែកមួយនៃការដោះស្រាយជម្លោះដោយសន្តិវិធី ដោយមានការអន្តរាគមន៍ពីតតិយភាគី ឬជាការចូលរួមពីភាគីទីបី ក្នុងការស្វែងរកដំណោះស្រាយជម្លោះ។ ភាគីនៃជម្លោះជាអ្នកកំណត់យកភាគីទីបី និងជាអ្នកបង្កើតវិធានជាមូលដ្ឋានទូទៅ ឬស្វែងរកចំណុចគោលណាមួយយកមកដោះស្រាយជម្លោះឲ្យកាន់តែមានប្រសិទ្ធិភាព។ ចំពោះភាគីទីបីដែលជាអ្នកចូលខ្លួនមកសម្របសម្រួលនៃកិច្ចការចរចាអាចជា៖ រដ្ឋ អង្គការតំបន់ អង្គការអន្តរជាតិ ឬអាចជាអ្នកនយោបាយជាន់ខ្ពស់តាមរយៈការអញ្ជើញពីភាគីជម្លោះ។

---

[18]អនុបណ្ឌិត នួន សុធិមន្ត, *ច្បាប់ការទូត*, ឆ្នាំ២០០៤

[19] http://unterm.un.org/dgaacs/unterm.nsf(ចូលទស្សនាថ្ងៃទី ២៨ ឧសភា ២០១៤)

[20] http://unterm.un.org/dgaacs/unterm.nsf(ចូលទស្សនាថ្ងៃទី ២៨ ឧសភា ២០១៤)

### ២.១. ការសម្រុះសម្រួល(Good Offices)

ការម្រុះសម្រួល ក៏ជាការផ្តល់ឲ្យមានការទាក់ទងគ្នាយ៉ាងជិតស្និតបំផុត ជាមួយការចរចា ហើយបានចែងក្នុងអនុសញ្ញាទីក្រុងឡាអេ ស្តីពីការដោះស្រាយជម្លោះដោយសន្តិវិធីឆ្នាំ១៩០៧[21] និងសេចក្តីថ្លែងការម៉ានីល (Manila Declaration) ឆ្នាំ១៩៨២ដែរ។[22]

ភាគីទីបី ជាអ្នកដែលផ្តល់ទីកន្លែង អ្នកបកប្រែ សេវាលេខាធិការ និងរាល់តំរូវការនានា(រដ្ឋ ឬ អគ្គលេខាធិការអង្គការសហប្រជាជាតិ ឬអង្គការអន្តរជាតិ ឬបុគ្គលអន្តរជាតិនានាដែលមានឈ្មោះល្បី) បានអនុវត្តការងាររបស់ខ្លួន ដើម្បីនាំភាគីជម្លោះឲ្យទាក់ទងគ្នា និងអាចធ្វើការប្រជុំទៀតផង។ ភាគីទីបី នៅក្នុងពេលនេះគ្រាន់តែជាអ្នកសម្រុះសម្រួល ឬធ្វើការបញ្ចុះបញ្ចូលភាគីជម្លោះឲ្យស្វែងរកចុះនុចរួមមួយ។ ម្យ៉ាងទៀតការម្រុះសម្រួលគ្រាន់តែជាសកម្មភាពរបស់ភាគីទីបី ដែលជាអ្នកពាំនាំនូវពត៌មាន ឬអាចជាអ្នកចាប់ផ្តើម ឬជាកិច្ចការបន្តពីការចរចា ដោយឡែកគឺពុំមានការចូលរួមពីភាគីទីបីក្នុងកិច្ចពិភាក្សាពីបញ្ហាជម្លោះឡើយ។[23] ជំនួបរវាងភាគីជម្លោះទាំងពីរ ត្រូវតែធ្វើការពិភាក្សា ឬធ្វើការចរចាដោយផ្ទាល់ ដោយគ្មានសកម្មភាពលូកដៃពីភាគីទីបីដែលជាអ្នកផ្តល់ការសម្រុះសម្រួលនោះឡើយ ទោះជាយ៉ាងណាក៏ដោយ វាតម្រូវឲ្យមានកិច្ចព្រមព្រៀងទ្វេភាគីមួយកើតឡើងផងដែរ បន្ទាប់ពីជំនួប ដើម្បីបន្តកិច្ចចរចានាពេលក្រោយ។[24]

ភារកិច្ចរបស់ភាគីទីបី ដែលជាអ្នកសម្រុះសម្រួល គឺគ្រាន់តែជួយបញ្ចុះបញ្ចូលភាគីជម្លោះឲ្យងាកមករកតុចរចាតែប៉ុណ្ណោះ ដូចនេះភារកិច្ចនេះត្រូវបានបញ្ចប់ នៅពេលដែលភាគីជម្លោះអង្គុយនៅតុចរចា។

ឧទាហរណ៍ ៖ ការធ្វើការសម្រុះសម្រួល ដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ នៅអំឡុងសង្គ្រាមហ្វកឡែន(Falkland) នាឆ្នាំ ១៩៨២ រវាងប្រទេស ចក្រភពអង់គ្លេស(United Kingdom) និង ប្រទេសអាហ្សង់ទីន(Argentina)។

ឧទាហរណ៍ ៖ អង្គការសហប្រជាជាតិបានប្រើការសម្រុះសម្រួល នៅក្នុងប្រទេសឥណ្ឌូណេស៊ី ឆ្នាំ ១៩៤៧ ប្រទេស ប៉ាលេស្ទីន ឆ្នាំ ១៩៦៦ ប្រទេស អាហ្គានីស្ថាន ឆ្នាំ១៩៨៨។

ក្នុងការជួយធ្វើអន្តរាគមន៍នៃមហាអំណាចទីបីដែលយល់ថា ត្រូវជួយធ្វើជាអាជ្ញាកណ្តាល ដើម្បីបញ្ចប់ជម្លោះរដ្ឋទាំងពីរ ឬក៏អញ្ជើញដោយរដ្ឋមួយជាភាគីជម្លោះ។ ជាគោលការណ៍ តតិយរដ្ឋមិនរួមក្នុងការចរចាដោផ្ទាល់ទេ គឺមានតែរដ្ឋក្នុងភាគីជម្លោះទេដែលមានសិទ្ធិ។ ភារកិច្ចរបស់តតិយរដ្ឋនេះត្រូវបានបញ្ចប់នៅពេលរដ្ឋភាគីជម្លោះនេះស្រុះស្រួលគ្នាចរចា។ នៅក្នុងឆ្នាំ១៩៥៦ សហរដ្ឋ

[21]មាត្រា ២,៣ នៃអនុសញ្ញាទីក្រុងឡាអេ ស្តីពីការដោះស្រាយជម្លោះដោយសន្តិវិធី

[22]ប្រការ ៥ សេចក្តីថ្លែងការម៉ានីល ថ្ងៃទី១៥ វិច្ឆិការ ១៩៨២

[23] The Settlement of dispute in International Law, page 27

[24]មាត្រា៥ នៃ American Treaty on Pacific Settlement (PACT OF BOGOTA)

អាមេរិក បានជួយក្នុងជម្លោះព្រំដែនរវាងបារាំងតំណាងឲ្យផលប្រយជន៍កម្ពុជានៅក្រោមអាណាព្យាបាលជាមួយនិងប្រទេសថៃ។[25]

### ២.២. សន្ធានកម្ម (Mediation)

នៅក្នុងសន្ធានកម្ម ភាគីអព្យាក្រឹត មិនធ្វើសេចក្តីសម្រេចសម្រាប់ភាគីជម្លោះនោះទេ។ ក៏ប៉ុន្តែជារឿយៗភាគីអព្យាក្រឹតជួបជាមួយភាគី ទាំងជួបម្នាក់ម្តងដាច់ដោយឡែកពីគ្នា និងជួបរួមគ្នាដើម្បីជួយពួកគេឲ្យបានឈាន ដល់កិច្ចព្រមព្រៀងមួយ។ សន្ធានការី លើកទឹកចិត្តដល់ភាគីឲ្យនិយាយពីជម្លោះរបស់ពួកគេ។ សន្ធានការី ព្យាយាមជួយភាគីនីមួយៗផងដែរ ដើម្បីពិនិត្យឲ្យបានច្បាស់លាស់ថាតើរឿងជម្លោះដែលពួកគេលើកឡើងនោះ សមនឹងលទ្ធផលយ៉ាងណា ប្រសិនបើជម្លោះត្រូវបានបញ្ជូនទៅមជ្ឈត្តវិនិច្ឆ័យ ឬតុលាការ។ ជាញឹកញាប់សន្ធានការីរំពឹងទុកថា នឹងដាក់ជូនសំណើររបស់ពួកគេដោយផ្ទាល់ពីជម្លោះនោះ។ ភាគីអាចយល់ព្រមទទួលយកសេចក្តីស្នើរយោ បល់ទាំងនេះ ឬក៏សេចក្តីស្នើរយោបល់ទាំងនេះអាចបង្កើតបានជាមូលដ្ឋានសម្រាប់ការពិភាក្សាបន្ថែមទៀត ដែលនាំឲ្យមានដំណោះស្រាយមួយ។ ដោយសារតែតួនាទីរបស់សន្ធានការី អាចមានសារៈប្រយោជន៍ សន្ធានការីគួរតែឆ្លងកាត់បទពិសោធន៍ច្រើនជាមួយនឹងប្រភេទនៃជម្លោះ ដែលភាគីទាំងពីរនោះមាននឹងគ្នា ជាពិសេសនៅពេលដែលជម្លោះនោះជាជម្លោះដ៏ស្មុគស្មាញ។[26]

សន្ធានកម្ម គឺជាទម្រង់ពិសេសមួយនៃដំណោះស្រាយជម្លោះអន្តរជាតិដោយសន្តិវិធី ហើយគេបានអនុវត្តច្រើនដែរនៅក្នុងឆាកអន្តរជាតិ ជាពិសេសចំពោះភាគីពាក់ព័ន្ធ មានភាគីទីបីដែលបានចូលរួមក្នុងការចរចាអន្តរជាតិ។ ភាគីទីបី អាចជារដ្ឋ ឬអង្គការអន្តរជាតិ ឬបុគ្គលជាទីគោរពដូចជាអ្នកនយោបាយ អ្នកច្បាប់ អ្នកវិទ្យាសស្ត្រ ក៏អាចចូលក្នុងសកម្មភាពនេះបានដែរ ដោយមានការជឿជាក់និងយល់ព្រមពីភាគីជម្លោះ។ វត្តមាននៃអន្តរាគមន៍នេះមិនត្រឹមតែជួយរៀប ចំលក្ខខណ្ឌនៃការបើកកិច្ចចរចាប៉ុណ្ណោះទេ តែក៏ជាយន្តការធានាការគោរពលទ្ធផលនៃកិច្ចចរចាផងដែរ។

គេគិតថាសន្ធានកម្មមាន ប្រាំដំណាក់កាលជាមូលដ្ឋានដូចតទៅ៖

១. ការជួបគ្នាលើកដំបូងរវាងសន្ធានការី ហើយនិងភាគីទាំងពីរ

២. ការចូលរួមរបស់សន្ធានការីនៅក្នុងជម្លោះ និងការកំណត់វិធានជាមូលដ្ឋាន សម្រាប់ជាប្រទីបនាំផ្លូវនៃដំណើរការ

៣. ការប្រមូលពត៌មានអំពីជម្លោះ ការកំណត់អត្តសញ្ញាណនៃបញ្ហាដែលត្រូវដោះស្រាយ និងការយល់ព្រមចំពោះរបៀបវារៈ

[25] សាស្ត្រាចារ្យ អនុបណ្ឌិត នួន សុធិមន្ត. ២០០៤. *ច្បាប់ការទូត*. ភ្នំពេញ៖ បណ្ណាគារអង្គរធំ

[26] មូលនិធិអាស៊ី. ២០០១. *ដំណោះស្រាយស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ*. ភ្នំពេញ៖ រោងពុម្ពអន្តរជាតិ ទំព័រ៨

៤. បង្កើតជម្រើសសម្រាប់ដោះស្រាយបញ្ហាដែលត្រូវដោះស្រាយ

៥. ធ្វើការវាយតម្លៃលើជម្រើសនៃដំណោះស្រាយ ហើយប្រៀបធៀបជម្រើស ទាំងនោះទៅនឹងលទ្ធផលនៃការដោះស្រាយជម្លោះដ៏ទៃទៀតរបស់ភាគី ដូចជាជម្លោះរដ្ឋប្បវេណីនៅតុលាការជាដើម

៦. ធ្វើឲ្យមានកិច្ចព្រមព្រៀងពេញលេញ ឬ មួយផ្នែកលើបញ្ហានៃជម្លោះ ឬសម្រេចថាមិនអាចមានកិច្ចព្រមព្រៀងឡើយ។

ការនាំផ្លូវភាគីនៅក្នុងដំណាក់កាលទាំងនេះ សន្ធានការីអាចមើលឃើញជម្រើសដែលអាចបង្កើតឱកាសសំរាប់ការដោះស្រាយជម្លោះអន្តរជាតិ ហើយនិងគ្រោះថ្នាក់ ដែលអាចរាំងស្កាត់ដំណោះស្រាយជម្លោះ។ សន្ធានការីអាចទាញយកប្រយោជន៍ពីឱកាស ហើយជៀសវាងនូវគ្រោះថ្នាក់ដោយ៖

- ធ្វើជាអ្នកដឹកនាំការពិភាក្សាអព្យាក្រឹតម្នាក់ និងធានាថាភាគីទាំងអស់មានឱកាសនិយាយទៅរកគ្នា ឲ្យយល់ពីគំនិតរៀងខ្លួន
- បន្ធូរបន្ថយការប៉ះទង្គិចផ្លូវអារម្មណ៍របស់ភាគី
- ទាក់ទាញទំនុកចិត្តរបស់ភាគី ដើម្បីឲ្យពួកគេហ៊ានផ្តល់ពត៌មានសម្ងាត់ស្តីពីផលប្រយោជន៍ និងផែនការរបស់ពួកគេដល់សន្ធានការី
- ជួបជាមួយភាគីនីមួយៗ ដោយឡែកៗពីគ្នា ដើម្បីធ្វើឲ្យមានការពិភាក្សាដោយចំហ ហើយអនុញ្ញាតឲ្យមានច្រកចេញសម្រាប់ការរាំងស្ទះ ហើយបន្ទាប់មកធ្វើការទាក់ទងគ្នាទៅវិញទៅមកអំពីពត៌មានមួយចំនួនជាញឹកញាប់ ដោយបកស្រាយពាក្យពេចន៍ទាំងនោះ ពីអវិជ្ជមានទៅវិជ្ជមាន
- ធ្វើជា "អ្នកទទួលរងកំហុស" កាលបើមានអ្វីខុសនៅក្នុងសន្ធានកម្ម
- ជួយភាគីឲ្យផ្តោតទៅលើស្ថានភាពរបស់ពួកគេ ដើម្បីឲ្យភាគីនីមួយអាចមើលឃើញយ៉ាងច្បាស់លាស់ នៅចំណុចខ្លាំង និងចំណុចខ្សោយ នៃជម្លោះរបស់ពួកគេ ហើយនិង
- ជួយកំណត់អត្តសញ្ញាណ នៃផលប្រយោជន៍រយៈពេលវែងរបស់ភាគី និងលើកនូវដំណោះស្រាយស្តីពីជម្លោះ ដែលឆ្លុះបញ្ចាំងឲ្យឃើញនូវផលប្រយោជន៍ទាំងនោះ។[27]

ការធ្វើសន្ធានកម្ម ត្រូវប្រគល់ទៅឲ្យតំណាងរដ្ឋាភិបាលនៃតតិយរដ្ឋ ឬទៅឲ្យឥស្សរជនឯករាជ្យ ឬទៅឲ្យតំណាងអង្គការក្រៅរដ្ឋាភិបាលហើយ ជាពិសេសអ្នកទាំងនោះមិនបានជ្រៀតចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋទេ។ ការអន្តរាគមន៍ដោយប្រើប្រាស់សន្ធានកម្ម អាចជាបុគ្គល ឬសមូហភាព គឺ

[27]មូលនិធិអាស៊ី. ២០០១. *ដំណោះស្រាយស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ*. ភ្នំពេញ៖ រោងពុម្ពអន្តរជាតិ ទំព័រ ៩

រដ្ឋភាគីជម្លោះជាអ្នកជ្រើសរើស។ រដ្ឋភាគីជម្លោះក៏អាចបដិសេធការប្រើប្រាស់សន្ទានកម្ម ឬនីតិវិធីណាមួយក៏បាន។[28]

ម្យ៉ាងទៀតសន្ទានកម្មក៏ត្រូវបានអនុវត្តក្នុងជម្លោះលាយឡំគ្នាច្រើនដូចជា៖ ជម្លោះដែលកើតឡើងជាក់ស្តែង ពិតប្រាកដ ជម្លោះឯកជន។[29]

ឧទាហរណ៍ ៖ ការដោះស្រាយជម្លោះព្រំដែន រវាងប្រទេសឥណ្ឌា និង ប្រទេសប៉ាគីស្ថានឆ្នាំ ១៩៥៥ ក៏ត្រូវបានរដ្ឋទាំងពីរ ព្រមព្រៀងជ្រើសយកការដោះស្រាយដោយសន្តិវិធី គឺការប្រើប្រាស់សន្ទានកម្មដោយមានការអន្តរាគមន៍ពីប្រទេសអង់គ្លេស។

ឧទាហរណ៍ ៖ ១៩៧៨ Pape Jean Paul II បានដើរតួរជាអ្នកសម្រុះសម្រួលទំនាស់រវាងប្រទេសស៊ីលី(Chile) និងប្រទេសអាហ្សង់ទីន(Argentina) ឲ្យជៀសផុតពីការប្រឈមមុខដាក់គ្នាទាក់ទងនិងអធិបតេយ្យ លើទឹកដីព្រែកជីក Beagle "Canal De Beagle" ប្រទេសទាំងពីរបានព្រមព្រៀងគ្នាដោយចុះហត្ថលេខាលើសន្ធិសញ្ញាមួយគឺ "VATICAN" ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ១៩៨៤ ដោយបញ្ចប់សង្គ្រាម តែទោះជាយ៉ាងណាក៏ដោយរហូតដល់ ថ្ងៃទី២១ ខែតុលា ឆ្នាំ ១៩៩៤ ទើបជម្លោះនេះបានដោះស្រាយចប់ជាស្ថាពរ។[30]

## កថាខណ្ឌទី៣ ៖ ការអង្កេត (Inquiry)

### ៣.១. សញ្ញាណនៃការអង្កេត

ការអង្កេត ឬការស្រាវជ្រាវមានទិសដៅស្វែងរកមូលហេតុដែលនាំឲ្យមានវិវាទ។ យោងតាមធម្មនុញ្ញនៃសហប្រជាតិមាត្រា ៣៣ "ភាគីជម្លោះត្រូវរកដំណោះស្រាយជាបឋមតាមរយៈ ចរចា សន្ទានកម្ម ការសម្រុះសម្រួល ការអង្កេត ការផ្សះផ្សា មជ្ឈត្តវិនិច្ឆ័យ តាមតុលាការ ឬតាមរយៈអង្គការតំបន់ ឬអង្គការអន្តរជាតិ ឬសន្ធិសញ្ញាតំបន់ ឬតាមគោលបាយសន្តិវិធីដ៏ទៃទៀត"។

នៅក្នុងជម្លោះអន្តរជាតិ ភាគីនៃកិច្ចព្រមព្រៀងដែលមិនអាចឈានទៅរកកិច្ចព្រមព្រៀងណាមួយដោយការទូត ភាគីនៃជម្លោះនោះអាចឡើងតាមរយៈការអង្កេតអន្តរជាតិ ដើម្បីសម្របសម្រួលក្នុងការស្វែងរកដំណោះស្រាយដ៏សមស្របមួយ នៃជម្លោះតាមរយៈការស្វែងរកការពិត ឬការអង្កេត។

### ៣.២. ដំណើរការនៃការអង្កេត

ជាធម្មតានៅក្នុងជម្លោះអន្តរជាតិមួយ តែងកើតមានឡើងដោយការមិនគោរពភាពសុច្ចរិត និងកើតឡើងដោយការខ្វែងយោបល់គ្នា ឬគម្លាតទៅលើការពិត ហើយភាគីទាំងពីរមិនអាចមានលទ្ធភាពដោះស្រាយតាមរយៈផ្លូវទូតឡើយ។ នៅពេលកាលៈទេសៈមិនផ្តល់ឲ្យធ្វើការដោះស្រាយដោយខ្លួនឯង គឺមានតែធ្វើការដោះស្រាយតាមរយៈគណៈកម្មការអង្កេតអន្តរជាតិ (International

[28] សាស្ត្រាចារ្យ អនុបណ្ឌិត នួន សុធិមន្ត. ២០០៤. *ច្បាប់ការទូត*. ភ្នំពេញ៖ បណ្ណាគារអង្គរធំ

[29] The Settlement of dispute in International Law, page 29

[30] Dispute between Argentina and chile concerning the beagle channel 18 February 1997

Commissions of Inquiry or ICI) ដោយគណៈកម្មការនេះនឹងស្វែងរកដំណោះស្រាយជម្លោះទាំងនេះ តាមរយៈការស្វែងរកការពិត ឬការចុះអង្កេតដោយផ្ទាល់តែម្តង។

ចំពោះគណៈកម្មការអង្កេតអន្តរជាតិ ត្រូវបានជ្រើសដោយកិច្ចព្រមព្រៀងពិសេសមួយរវាងភាគីជម្លោះ។ មហាសន្និបាតដែលធ្វើឡើងដោយគណៈកម្មការអង្កេតអន្តរជាតិ និងត្រូវបង្កើតឡើងដើម្បីកំណត់អំពីរបៀបវារៈ ដែលគណៈកម្មការអង្កេតនឹងផ្តល់អំណាចជូនសមាជិកគណៈកម្មការ។ គណៈកម្មការអង្កេតអន្តរជាតិ និងប្រើប្រាស់ភាសាដូចធ្លាប់ប្រើពីមុន រីឯកាលបរិច្ឆេទវិញ គឺធ្វើការកំនត់ឲ្យភាគីជម្លោះលាតត្រដាងនូវការពិត ហើយនិងលក្ខខណ្ឌទាំងឡាយណាដែលខ្លួនបានព្រមព្រៀងគ្នាពីមុន។

គណៈកម្មការអង្កេតអន្តរជាតិ ដាក់កាតព្វកិច្ចជូនភាគីជម្លោះនូវពេលវេលាដែលរដ្ឋនីមួយៗត្រូវតែធ្វើការទាក់ទងជាមួយគណៈកម្មការអង្កេត និងជាមួយភាគីជម្លោះផ្សេងទៀតដើម្បីស្វែងរកការពិត។ ក្នុងករណីចាំបាច់ គណៈកម្មការអង្កេត តម្រូវឲ្យភាគីជម្លោះប្រមូលនូវរាល់លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ឬឯកសារពាក់ព័ន្ធនិងជម្លោះ ឬភស្តុតាងនានាដែលគិតថាមានប្រយោជន៍នឹងត្រូវប្រគល់ជូនគណៈកម្មការដើម្បីពិនិត្យនិងអង្កេត។ បន្ទាប់ពីប្រមូលបានភស្តុតាងមួយចំនួនហើយ គណៈកម្មាការនឹងចុះស្រាវជ្រាវដល់ទីកន្លែងកើតហេតុ ឬទីកន្លែងដែលពាក់ព័ន្ធ ហើយការចុះអង្កេតនេះ ភាគីត្រូវចូលរួមសហការផងដែរ។

រាល់ការស្រាវជ្រាវ ដែលចុះដល់ទីកន្លែងជម្លោះត្រូវធ្វើឡើងចំពោះមុខដោយបន្ទាន់ ហើយមានការផ្តល់យោបល់ពីភាគីផងដែ។ បន្ទាប់ពីគណៈកម្មការរកឃើញភស្តុតាងហើយ គណៈកម្មការនឹងធ្វើរបាយការណ៍មួយ ដែលត្រូវសម្រេចដោយសម្លេងភាគច្រើននៃគណៈកម្មការ។ បន្ទាប់មកគណៈកម្មការត្រូវថតចម្លងជូនភាគីជម្លោះម្នាក់មួយច្បាប់ទុកជាផ្លូវការ។ ដោយឡែករបាយការណ៍នេះពុំមានលក្ខណៈចាប់បង្ខំឡើយ។[31]

ឧទាហរណ៍៖ ជម្លោះរវាង រុស្ស៊ី(Russia) និង ចក្រភពអង់គ្លេស(United Kingdom) គឺត្រូវបានដោះស្រាយដោយគណៈកម្មការមួយឈ្មោះថា Dogger Bank ហើយរបាយការណ៍នៃគណៈកម្មការនេះ ត្រូវបានប្រទេសទាំងពីរទទួលយកដោយរីករាយ។[32]

ឧទាហរណ៍ ៖ ការដោះស្រាយជម្លោះដោយគណៈកម្មការ Ad Hoc រវាងចក្រភពអង់គ្លេស (United Kingdom) និង ដាណឺម៉ាក(Denmark) ពីរឿងកប៉ាល់ Red crusader។[33]

[31] Hague Convention on the Pacific Settlement of Dispute, 1907
[32] The Settlement of dispute in International Law, Page 25
[33] The Settlement of dispute in International Law, Page 26

## កថាខណ្ឌទី៤ ៖ ការផ្សះផ្សា( Conciliation )

### ៤.១.សញ្ញាណនៃការផ្សះផ្សា

ការផ្សះផ្សាត្រូវបានគេឲ្យនិយមន័យថា ជាវិធីក្នុងការដោះស្រាយជម្លោះអន្តរជាតិមួយ ដែលក្នុងនោះគណៈកម្មការត្រូវបានបង្កើតឡើងដោយ ភាគីនៃជម្លោះ តាមរយៈគណៈកម្មការអចិន្ត្រៃយ៍ ឬ គណៈកម្មការបណ្តោះអាសន្ន (Ad Hoc Commission) ដើម្បីធ្វើការដោះស្រាយជម្លោះដោយការត្រួតពិនិត្យ ដោយការគ្មានលំអៀងទៅលើជម្លោះ និងស្វែងរកដំណោះស្រាយដ៏សមរម្យមួយ ដែលអាចទទួលយកបានពីភាគីជម្លោះ ឬការផ្តល់ឲ្យភាគីនៃជម្លោះជាមួយនិងទស្សនៈក្នុងការដោះស្រាយដូចជាការជួយជ្រោមជ្រែង បើសិនជាភាគីដាក់សំណើរ។ ក្រៅពីនេះ យោងតាមសៀវភៅសិក្សា ការផ្សះផ្សាសំដៅដល់ទម្រង់នៃការដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ ដែលនាំឲ្យជម្លោះមួយត្រូវបានពិនិត្យពិច័យដោយអង្គការ ឬភាគីទីបីឲ្យចូលរួមស្តាប់ក្នុងការស្វែងរកដំណោះស្រាយមួយ ហើយធ្វើការចេញនូវដំណោះស្រាយដែលជាសេចក្តីសម្រេចមួយ ប៉ុន្តែមានលក្ខណៈមិនដាច់ខាតពុំចាប់ង្ខំ។

ការផ្សះផ្សា ជាដំណើរការដោះស្រាយជម្លោះផ្សេងមួយទៀត ដែលទាក់ទងនឹងការរក្សាចំណងមិត្តភាពវិជ្ជមានរវាងភាគីជម្លោះ។ ទោះជាយ៉ាងណាក៏ដោយវាមានលក្ខណៈខុសពីសន្ទានកម្មនិងមជ្ឈត្តវិនិច្ឆ័យច្រើន។ ជួនកាលការផ្សះផ្សា ជាវិធីសាស្ត្រមួយដែលគេតែងឃើញប្រើញឹកញាប់នៅក្នុងច្បាប់ស៊ីវិលក្នុងប្រទេសជាច្រើនដូចជាប្រទេសអ៊ីតាលីជាដើម ហើយវាមាននីតិវិធីច្រើនជាងសន្ទានកម្ម។ អ្នកផ្សះផ្សា(Conciliator) គឺជាអ្នកដែលត្រូវបានភាគីជ្រើសយកក្នុងនាមជាអ្នកបង្កើតឲ្យមានការចរចា និងដឹកនាំភាគីទៅរកកិច្ចព្រមព្រៀងមួយដោយសន្តិវិធី។ នៅក្នុងការផ្សះផ្សា អ្នកផ្សះផ្សាដើរតួផ្ទាល់ក្នុងការផ្សះផ្សាដើម្បីស្វែងរកដំណោះស្រាយនៃជម្លោះ ហើយធ្វើការណែនាំភាគីឲ្យជ្រើសយកការដោះស្រាយជម្លោះដោយសន្តិវិធីជាដំណោះស្រាយចម្បង។[34]

### ៤.២. នីតិវិធី និងដំណើរការផ្សះផ្សា

ការផ្សះផ្សា ជាវិធីសាស្ត្រមួយនៃការដោះស្រាយជម្លោះដែលរាប់បញ្ចូលទាំងការអង្កេត និងសន្ទានកម្ម។ ជម្លោះនឹងត្រូវបានដោះស្រាយដោយគណៈកម្មការមួយ ដែលគណៈកម្មការនេះមានភារកិច្ចស្វែងរកការពិត ហើយធ្វើការដោះស្រាយ ប៉ុន្តែមិនដំណើរការតាមប្រព័ន្ធតុលាការឡើយ។ បន្ទាប់ពីគណៈកម្មការរកឃើញតម្រុយខ្លះៗដែលពាក់ព័ន្ធនឹងជម្លោះ គណៈកម្មការនេះនឹងធ្វើការស្នើរដល់ភាគីជម្លោះឲ្យស្វែងរកដំណោះស្រាយរួមមួយ ដោយឡែកគឺពុំមានការចាប់បង្ខំដល់គូរភាគីឡើយ។ វាមានសារៈសំខាន់ណាស់នៅពេលដែលកម្មវត្ថុនៃជម្លោះត្រូវបានភាគីទាំងសងខាងចង់ស្វែងរកដំណោះស្រាយទាំងអស់គ្នា។[35]

---

[34] http://www.mediate.com/articles/sgubinia2.cfm(ចូលទស្សនាថ្ងៃទី ២៧ ឧសភា ២០១៤)

[35] The Settlement of dispute in International Law, page 29

បន្ទាប់ពីការដាក់ពាក្យស្នើរសុំរបស់ភាគីជម្លោះ ឲ្យមានការអន្តរាគមន៍ពីគណៈកម្មការដើម្បីធ្វើការផ្សះផ្សា គណៈកម្មការនេះនឹងត្រូវបង្កើតឡើងក្នុងរយៈពេល ៦ខែ[36]។ គណៈកម្មាការនេះមានសមាសភាពចំនួនប្រាំរូប។ ភាគីនីមួយៗត្រូវជ្រើសយកគណៈកម្មការមួយរូបពីប្រទេសខ្លួន ឬមានសញ្ជាតិខ្លួន។ រីឯគណៈកម្មការចំនួនបីរូបទៀត នឹងត្រូវជ្រើសដោយមានការព្រមព្រៀងពីភាគីទីបីដែលមានឥទ្ធិពល ហើយគណៈកម្មការទាំងបីនេះ ត្រូវតែមានសញ្ជាតិផ្សេង មិនរស់នៅ ឬបម្រើការងារលើទឹកដីនៃភាគីជម្លោះ។ ភាគីអព្យាក្រឹតទីបីនេះ នឹងត្រូវចាត់តាំងធ្វើជាប្រធាននៃគណៈកម្មការនេះ។ គណៈកម្មការនឹងត្រូវជ្រើសតាំងសម្រាប់អាណត្តិបីឆ្នាំ ហើយនឹងត្រូវបានបញ្ចប់នៅពេលដែលជម្លោះបានបញ្ចប់ តែក៏អាចបន្តបានក្នុងករណីប្រទេសជម្លោះផ្សេងទៀតជ្រើសយកម្តងទៀត។ ក្នុងករណីពិសេស ដែលភាគីជម្លោះមិនទាន់បានជ្រើសរើសគណៈកម្មការសម្រាប់ការដោះស្រាយ គណៈកម្មការពិសេសត្រូវបង្កើតឡើងសម្រាប់តែរយៈពេល ៣ ខែ។[37]

ការងារផ្សះផ្សារបស់គណៈកម្មការមិនត្រូវបានធ្វើជាសាធារណៈទេ បើសិនជាភាគីមិនអនុញ្ញាត។ ជាងនេះទៅទៀត បើសិនជាភាគីមិនអាចឈានទៅដល់ការព្រមព្រៀងនោះទេ គណៈកម្មការអាចធ្វើនីតិវិធីផ្ទាល់ខ្លួន ដែលនឹងត្រូវផ្តល់ឲ្យភាគីនៅពេលវិនិច្ឆ័យ ហើយគណៈកម្មការក៏មានសិទ្ធិស្នើរឲ្យមានការពន្យល់ផ្ទាល់មាត់ដល់ភ្នាក់ងារ ឬទីប្រឹក្សានៃរដ្ឋាភិបាលរបស់ប្រទេសទាំងពីរ។

សរុបសេចក្តីមក ការដោះស្រាយជម្លោះដោយសន្តិវិធី គឺមានច្រើនដំណាក់កាល ដែលនៅក្នុងចំណុចនេះ ការផ្សះផ្សាជាយន្តការដោះស្រាយជម្លោះដោយមានការចូលរួមពីភាគីទីបីជាគណៈកម្មការអព្យាក្រឹត។ គណៈកម្មការនេះត្រូវតែជម្រុញឲ្យមានការព្រមព្រៀងសន្តិភាពមួយកើតឡើងពីភាគីទាំងពីរ ដោយបញ្ចប់នូវជម្លោះតាមរយៈកិច្ចព្រមព្រៀងទ្វេភាគី ឬពហុភាគី តែពុំមានការចាប់បង្ខំឲ្យគូរភាគីអនុវត្តឡើយ។

ឧទាហរណ៍ ៖ ការបញ្ចប់ជម្លោះព្រំដែន រវាងអាមេរិកឡាទីន(Latin America) និងតំបន់ខារីបីន (Caribbean) តាមរយៈការប្រើប្រាស់ "ការផ្សះផ្សា"។

ឧទាហរណ៍ ៖ ការបញ្ចប់ជម្លោះរវាងប្រទេសបារាំង(France) និងប្រទេសស្វីស(Switzerland) ដោយព្រមព្រៀងបញ្ចប់ជម្លោះនាថ្ងៃទី ៦ ខែមេសា ឆ្នាំ១៩២៥។

[36]មាត្រា ១០, ១១, ១២ នៃ General Act of Conciliation, Arbitration and Judicial Settlement. May 21, 1929

# ផ្នែកទី២៖ ដំណោះស្រាយជម្លោះអន្តរជាតិក្នុងប្រព័ន្ធតុលាការ

## កថាខណ្ឌទី១៖ តុលាការអចិន្ត្រៃយ៍អាជ្ញាកណ្តាល(PCA)

### ១.១. សញ្ញាណនៃការបង្កើត

តុលាការអចិន្ត្រៃយ៍អាជ្ញាកណ្តាល(PCA) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៨៩៩ ជាផ្នែកមួយនៅក្នុងសកម្មភាពនៃសន្និសីទសន្តិភាពទីក្រុងឡាអេលើកទី១ ដែលធ្វើអោយតុលាការនេះក្លាយជាស្ថាប័នចំណាស់ជាងគេបំផុតសម្រាប់ដោះស្រាយវិវាទអន្តរជាតិ។

ការបង្កើតតុលាការអចិន្ត្រៃយ៍ជាអាជ្ញាកណ្តាល គឺយោងទៅតាមមាត្រា ២០ ដល់មាត្រា ២៩ នៃសន្ធិសញ្ញាទីក្រុងឡាអេឆ្នាំ១៨៩៩ ស្តីពីដំណោះស្រាយវិវាទអន្តរជាតិដោយសន្តិវិធី ដែលជាលទ្ធផលនៃសន្និសីទសន្តិភាពទីក្រុងឡាអេលើកទី១។ នៅក្នុងសន្និសីទសន្តិភាពទីក្រុងឡាអេលើកទី២ សន្ធិសញ្ញាមុនត្រូវបានកែសម្រួលដោយ សន្ធិសញ្ញាឆ្នាំ ១៩០៧ ស្តីពីដំណោះស្រាយវិវាទអន្តរជាតិដោយសន្តិវិធី។ សន្និសីទនេះបានប្រារព្ធធ្វើឡើង ដោយមានការផ្តើមគំនិតពីអធិរាជ Nicolas II នៃប្រទេសរុស្ស៊ី។ ភាពជោគជ័យធំបំផុតនៃសន្និសីទនេះ គឺការបង្កើតបាននូវតុលាការអចិន្ត្រៃយ៍អាជ្ញាកណ្តាល ដែលជាយន្តការសកលដំបូងបំផុតសម្រាប់ដោះស្រាយវិវាទរវាងរដ្ឋ និងរដ្ឋ។

បច្ចុប្បន្នមានរដ្ឋចំនួន ១១៥ ជាសមាជិកនៃតុលាការអចិន្ត្រៃយ៍អាជ្ញាកណ្តាល ដោយរដ្ឋខ្លះបានចូលជាភាគីនៃសន្ធិសញ្ញា ១ ក្នុងចំណោមសន្ធិសញ្ញាទាំង ២ ហើយរដ្ឋខ្លះទៀតបានចូលជាភាគីនៃសន្ធិសញ្ញាទាំងពីរ។ ក្នុងចំណោមប្រទេសទាំង ១០ ជាសមាជិកសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) មានប្រទេសចំនួន ៧ ជាភាគីនៃសន្ធិសញ្ញាទាំងពីរដែលក្នុងនោះរួមមាន ប្រទេសកម្ពុជា ប្រទេសថៃ ប្រទេសវៀតណាម ប្រទេសឡាវ ប្រទេសភីលីពីន ប្រទេសសិង្ហបុរី និងប្រទេសម៉ាឡេស៊ី។[38]

ប្រទេសកម្ពុជាបានចូលជាភាគីនៃ សន្ធិសញ្ញាទីក្រុងឡាអេឆ្នាំ ១៨៩៩ និងសន្ធិសញ្ញាឆ្នាំ ១៩០៧ ស្តីពីដំណោះស្រាយវិវាទអន្តរជាតិដោយសន្តិវិធីនៅក្នុងពេលជាមួយគ្នា គឺនៅថ្ងៃទី០៧ ខែមករា ឆ្នាំ ១៩៥៦។

### ១.២. សមាជិកអាជ្ញាកណ្តាល

សមាជិកនៃតុលាការអចិន្ត្រៃយ៍អាជ្ញាកណ្តាល ត្រូវបានតែងតាំង ដោយរដ្ឋទាំងឡាយជាសមាជិក។ សមាជិកនីមួយៗអាចធ្វើការតែងតាំងអាជ្ញាកណ្តាលរហូតដល់ ៤ រូប ដែលត្រូវបានគេទទួលស្គាល់ថាមានសមត្ថភាពនៅក្នុងនីតិអន្តរជាតិ ហើយមានសីលធម៌ និងកេរ្តិ៍ឈ្មោះខ្ពស់បំផុត ដើម្បី

[38]http://www.pca-cpa.org/showpage.asp?pag_id=1038 (ចូលទស្សនាថ្ងៃទី ១០ មិថុនា ២០១៤)

ទទួលនូវកាតព្វកិច្ចជាសមាជិក ក្រុមអាជ្ញាកណ្តាលនៅក្នុងតុលាការ។ សមាជិកអាជ្ញាកណ្តាលត្រូវបានតែងតាំងសម្រាប់អាណត្តិ ៦ ឆ្នាំ ហើយអាចត្រូវបានតែងតាំងសារជាថ្មីទៀត។

រហូតមកដល់ពេលបច្ចុប្បន្ននេះ មានប្រទេសចំនួនត្រឹមតែ ៧៣ ប៉ុណ្ណោះដែលមានបេក្ខភាពអាជ្ញាកណ្តាលពីប្រទេសរបស់ខ្លួន នៅក្នុងតុលាការអចិន្ត្រៃយ៍អាជ្ញាកណ្តាល។[39] ដោយក្នុងនោះប្រទេសខ្លះបានតែងតាំងសមាជិក ១ រូប ខ្លះ ២ រូប និងប្រទេសខ្លះទៀតបានតែងតាំងសមាជិក ៣ រូប ប៉ុន្តែភាគច្រើនគឺបានតែងតាំង ៤ រូប។ ក្រលេកមកមើលក្នុងតំបន់អាស៊ានវិញ ក្នុងចំណោមប្រទេសជាភាគីទាំង ៧ របស់សន្ធិសញ្ញាទីក្រុងឡាអេស្តីពីដំណោះស្រាយវិវាទអន្តរជាតិដោយសន្តិវិធី មានប្រទេស៦ ដែលមានសមាជិកអាជ្ញាកណ្តាលនៅក្នុងតុលាការអចិន្ត្រៃយ៍ជាអាជ្ញាកណ្តាល ដែលក្នុងនោះមានតែប្រទេសកម្ពុជាមួយគត់ ដែលពុំមានតែងតាំងអាជ្ញាកណ្តាលពីប្រទេសរបស់ខ្លួន។

### ១.៣. រចនាសម្ព័ន្ធ

តុលាការអចិន្ត្រៃយ៍ជាអាជ្ញាកណ្តាល ចែកចេញជាបីស្ថាប័នធំៗគឺ ក្រុមប្រឹក្សារដ្ឋបាលដែលត្រួតពិនិត្យគោលនយោបាយនិងថវិការបស់ខ្លួន អគ្គលេខាធិការ និងការិយាល័យអន្តរជាតិ។

#### ១.៣.១. ក្រុមប្រឹក្សារដ្ឋបាល

ក្រុមប្រឹក្សារដ្ឋបាល គឺស្ថិតនៅក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការបរទេស នៃប្រទេសហូឡង់។ ស្ថាប័ននេះធ្វើការពិគ្រោះយោបល់ជាមួយអគ្គលេខាធិការ ដើម្បីធ្វើសេចក្តីព្រាងគោលនយោបាយរបស់ស្ថាប័ន។ វាផ្តល់នូវការណែនាំជាទូទៅលើការងាររបស់តុលាការ ឃ្លាំមើលរដ្ឋបាល ហើយនិងថវិការបស់ខ្លួន ព្រមទាំងត្រួតពិនិត្យលើការចំណាយនានា។ ក្រុមប្រឹក្សារដ្ឋបាលប្រតិបត្តិនៅក្រោមវិធាននៃនីតិវិធីរបស់ក្រុមប្រឹក្សារដ្ឋបាលតុលាការអចិន្ត្រៃយ៍អាជ្ញាកណ្តាល។

ថវិការបស់តុលាការ ត្រូវបានផ្តល់ដោយការរួមវិភាគទានពីរដ្ឋជាសមាជិក។ អគ្គលេខាធិការធ្វើរបាយការណ៍ប្រចាំឆ្នាំ ទៅក្រុមប្រឹក្សារដ្ឋបាល អំពីសកម្មភាពរបស់តុលាការ និងការចំណាយរបស់ខ្លួន។ ក្រុមប្រឹក្សារដ្ឋបាលរ៉ាប់រងការត្រួតពិនិត្យហិរញ្ញវត្ថុរបស់ការិយាល័យអន្តរជាតិ ចំពោះមុខគណៈកម្មាធិការហិរញ្ញវត្ថុមួយ ដែលមានសមាសភាពរបស់សមាជិកបីនាក់នៃប្រឹក្សារដ្ឋបាល មានទីតាំងនៅក្នុងទីក្រុងឡាអេ។ សមាជិកនេះត្រូវធ្វើការផ្លាស់ប្តូរជារៀងរាល់ឆ្នាំ នៅថ្ងៃទីមួយនៃខែមករា ដោយធ្វើការជំនួសសមាជិកមួយរូប តាមលំដាប់អក្សរបារាំង (ដោយអនុលោមតាមមាត្រា XI នៃវិធាននីតិវិធីរបស់ក្រុមប្រឹក្សារដ្ឋបាល)។

[39] បញ្ជីឈ្មោះសមាជិកអាជ្ញាកណ្តាលនាពេលបច្ចុប្បន្ន ដែលចេញផ្សាយដោយតុលាការអចិន្ត្រៃយ៍ជាអាជ្ញាកណ្តាល(PCA)

### ១.៣.២.អគ្គលេខាធិការ

អគ្គលេខាធិការ គឺជាប្រធានការិយាល័យអន្តរជាតិរបស់តុលាការអចិន្ត្រៃយ៍អាជ្ញាកណ្តាល។ អគ្គលេខាធិការបច្ចុប្បន្នគឺលោក Hugo HansSiblesz។ មុនពេលតែងតាំងតំណែងជាអគ្គលេខាធិការអចិន្ត្រៃយ៍នៃតុលាការអចិន្ត្រៃយ៍អាជ្ញាកណ្តាល លោក Siblesz ធ្លាប់បានបម្រើការងារជាឯកអគ្គរាជទូតនៃព្រះរាជាណាចក្រហូល្លង់ ប្រចាំប្រទេសបារាំង ប្រទេសម៉ូណាកូ និងប្រទេសអង់ដូរ៉ា ចាប់ពីឆ្នាំ ២០០៦ រហូតដល់ឆ្នាំ ២០១២។

លោក Siblesz បានចូលបម្រើការងារនៅក្រសួងកិច្ចការបរទេសនៃប្រទេសហូឡង់ក្នុងឆ្នាំ ១៩៧៣ ដោយធ្វើជាអគ្គនាយកទទួលបន្ទុកកិច្ចការនយោបាយ និងជានាយកនៃនាយកដ្ឋានកុងស៊ុលក្នុងចំណោមតួនាទីផ្សេងទៀតនៅក្នុងអាជីពរបស់គាត់។

### ១.៣.៣. ការិយាល័យអន្តរជាតិ

នៅក្នុងការិយាល័យអន្តរជាតិមានក្រុមអ្នកមានបទពិសោធន៍ផ្នែកច្បាប់ និងបុគ្គលិករដ្ឋបាលនៃជាតិសាសន៍នានា ដែលត្រូវបានដឹកនាំដោយអគ្គលេខាធិការ។ ការិយាល័យនេះផ្តល់នូវសេវាចុះបញ្ជីនិងការគាំទ្ររដ្ឋបាលដល់សាលាក្តីព្រមទាំងគណៈកម្មការនានា។ ការិយាល័យនេះបានផ្តល់សេវាអន្តរជាតិដូចជាការស្រាវជ្រាវផ្នែកច្បាប់ ការគ្រប់គ្រងហិរញ្ញវត្ថុ ការគាំទ្របរិក្ខារ និងបច្ចេកទេសសម្រាប់ការប្រជុំ និងសវនាការ ការរៀបចំការធ្វើដំណើរ។ វាក៏ផ្តល់នូវការគាំទ្ររដ្ឋបាលដល់សាលាក្តី ឬគណៈកម្មការ នៅពេលដែលតុលាការ ដំណើរការដោះស្រាយរឿងក្តីនៅក្រៅប្រទេសហូឡង់ផងដែរ។

ការិយាល័យអន្តរជាតិអាចផ្តល់នូវពត៌មាននិងដំបូន្មានដល់ភាគី ដើម្បីរកវិធីដោះស្រាយជម្លោះ ចំពោះរដ្ឋជាភាគី និងរដ្ឋដែលមិនមែនជាភាគីនៃសន្ធិសញ្ញានេះផងដែរ។

## កថាខណ្ឌទី ២ ៖ តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ (PCIJ)

### ២.១. សញ្ញាណនៃការបង្កើត

នៅដើមឆ្នាំ ១៩២០ ក្រុមប្រឹក្សានៃសង្គមប្រជាជាតិ បានតែងតាំងគណៈកម្មាធិការមួយដើម្បីរៀបចំរបាយការណ៍ស្តីពីការបង្កើតតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ។ គណៈកម្មាធិការនេះមានទីតាំងនៅទីក្រុងឡាអេ ក្រោមការដឹកនាំរបស់ជនជាតិបែលហ្សិក។ នាខែសីហា ឆ្នាំ ១៩២០ គណៈកម្មាធិការនេះបានដាក់ជូននូវរបាយការណ៍ស្តីពីការពង្រាងលក្ខន្តិកៈតុលាការ ហើយត្រូវបានដាក់ចូលក្នុងរបៀបវារៈនៃសន្និបាតលើកទីមួយរបស់សង្គមប្រជាជាតិ ដែលបានប្រព្រឹត្តទៅនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នាខែវិច្ឆិកា ឆ្នាំ១៩២០។ បន្ទាប់ពីបានសិក្សាយ៉ាងល្អិតល្អន់រួចមកពង្រាងលក្ខន្តិកៈតុលាការត្រូវបានអនុម័តជាឯកច្ឆ័ននៅខែធ្នូ ឆ្នាំ១៩២០។ សេចក្តីសម្រេចចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ១៩២០ បានបង្គាប់ឱ្យក្រុមប្រឹក្សាសន្តិសុខ ផ្តល់ជូនសមាជិកសង្គមប្រជាជាតិនូវពិធីសារស្តីពីការអនុម័តលក្ខន្តិកៈ ក្រោយពីការឱ្យសច្ចាប័នលើពិធីសារនេះដោយសម្លេងភាគច្រើននៃ

សមាជិក។ ពិធីសារនេះត្រូវបានបើកចំហរដល់ការចុះហត្ថលេខាចាប់ពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩២០មក។ នៅក្នុងឱកាសមហាសន្និបាតបន្ទាប់ នាខែកញ្ញា ឆ្នាំ១៩២១ រដ្ឋសមាជិកសង្គមប្រជាជាតិភាគច្រើនបានចុះហត្ថលេខា និងឱ្យសច្ចាប័នលើពិធីសារនេះ។ ដូចនេះលក្ខន្តិកៈនៃតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ ក៏ចូលជាធរមានចាប់ពីពេលនោះមក។

ក្នុងចន្លោះពីឆ្នាំ ១៩២២ រហូតដល់ឆ្នាំ ១៩៤០ តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិបានដោះស្រាយរឿងក្តីវិវាទរវាងរដ្ឋនិងរដ្ឋចំនួន ២៩ ករណី និងបានផ្តល់មតិប្រឹក្សាចំនួន២៧។ ក្នុងពេលជាមួយគ្នានោះដែរ សន្ធិសញ្ញា អនុសញ្ញា និង សេចក្តីប្រកាសជាច្រើន បានប្រគល់យុត្តាធិការនៃការដោះស្រាយជម្លោះមកអោយតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ។

### ២.២. សមាសភាពចៅក្រម

ដំបូងឡើយ តុលាការនេះមានចៅក្រមទាំងអស់ ១១ រូប និងចៅក្រមរង ៤ រូបទៀត ដែលស្នើឡើងដោយសម្ព័ន្ធប្រជាជាតិ ដាក់ទៅអគ្គលេខាធិការនៃសម្ព័ន្ធប្រជាជាតិ ដែលត្រូវដាក់ជូនបន្តរទៅក្រុមប្រឹក្សា និងមហាសន្និបាតសម្រាប់ការបោះឆ្នោតជ្រើសរើស។ រដ្ឋជាសមាជិកត្រូវបានអនុញ្ញាតឲ្យឧទ្ទេសនាមចៅក្រមដែលមានសក្តានុពលចំនួន ៤ រូប ដោយច្រើនបំផុតគឺ ២ រូប មកពីប្រទេសរបស់ខ្លួន។ ចៅក្រមត្រូវបានបោះឆ្នោតដោយសម្លេងឆ្នោតភាគច្រើនដាច់ខាត ដែលប្រារព្ធឡើងដោយឯករាជ្យនៅក្នុងក្រុមប្រឹក្សានិងមហាសន្និបាត។ ចៅក្រមម្នាក់ៗមានអាណត្តិ ៩ ឆ្នាំដូចៗគ្នា។ ចៅក្រមមានឯករាជ្យភាព និងផ្តាច់ខ្លួនឯងពីសញ្ជាតិរបស់ពួកគេសម្រាប់គោលបំណងនៃសវនាការរឿងក្តី។

ក្រុមចៅក្រមដែលបានជាប់ឆ្នោតជាលើកដំបូងគឺនៅថ្ងៃទី ១៤ ខែកញ្ញាឆ្នាំ ១៩២១ ដោយចៅក្រមរង ៤ រូបត្រូវបានបោះឆ្នោតនៅថ្ងៃទី ១៦។ ចៅក្រមរងគឺគ្រាន់តែទុកជំនួសសម្រាប់ចៅក្រមអវត្តមាន និងមិនត្រូវបានផ្តល់សិទ្ធិឱ្យបោះឆ្នោតនៅក្នុងការផ្លាស់ប្តូរនីតិវិធីតុលាការ ឬការរួមចំណែកនៅក្នុងពេលផ្សេងទៀតទេ។ ពួកគេត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពជាការប្រឹក្សានៅក្នុងរឿងក្តីអន្តរជាតិ តែពួកគេមិនត្រូវបានអនុញ្ញាតអោយដើរតួរជាចៅក្រមក្នុងរឿងក្តីទេ។

### ២.៣. នីតិវិធី

បន្ទាប់ពីទទួលបានបណ្តឹង ដែលអាចនាំទៅដល់ការវិនិច្ឆ័យ ចៅក្រមនឹងផ្លាស់ប្តូរទស្សនៈរបស់ពួកគេក្រៅផ្លូវការទៅលើអង្គច្បាប់ដែលបានលេចឡើងនៅក្នុងរឿងក្តី ហើយការកំណត់ពេលវេលាមួយសម្រាប់ការវិនិច្ឆ័យនឹងត្រូវបានកំណត់។ បន្ទាប់មក ចៅក្រមម្នាក់ៗនឹងសរសេរសេចក្តីសង្ខេបមិនបញ្ចេញឈ្មោះមួយដែលបង្ហាញពីគំនិតរបស់ពួកគេ។ សេចក្តីសង្ខេបទាំងនេះនឹងត្រូវបញ្ជូនទៅដល់តុលាការក្នុងរយៈពេល ២ ឬ ៣ ថ្ងៃមុនពេលដែលប្រធានតុលាការរៀបចំសេចក្តីព្រាង

នៃការវិនិច្ឆ័យសេចក្តីសង្ខេប ដែលបានដាក់ជូនដោយចៅក្រមម្នាក់ៗនោះ។ បន្ទាប់មកតុលាការនឹងយល់ព្រមលើការសម្រេចចិត្ត ក្នុងចំណុចរួមមួយនៃដំណោះស្រាយជម្លោះ ដែលពួកគេចង់បាន។ នៅពេលដែលនីតិវិធីនេះបានធ្វើរួច គណៈកម្មាធិការមួយដែលមានសមាជិក ៥ រូប រួមមានប្រធានតុលាការ អ្នកចុះបញ្ជី និងចៅក្រមពីរនាក់ដែលបានបោះឆ្នោតដោយសម្ងាត់ ធ្វើការព្រាងសេចក្តីសន្និដ្ឋានចុងក្រោយមួយ បន្ទាប់មកត្រូវដាក់អោយបោះឆ្នោតដោយតុលាការទាំងមូល។ នៅពេលដែលការវិនិច្ឆ័យចុងក្រោយត្រូវបានកំណត់ វានឹងត្រូវបានផ្តល់ទៅអោយរដ្ឋជាភាគីវិវាទ និងសារព័ត៌មាន។ រាល់ការវិនិច្ឆ័យ ត្រូវបង្ហាញពីហេតុផលលើការសម្រេចចិត្ត ហើយនិងការយល់ស្របពីចៅក្រមទាំងអស់។ ប្រសិនបើមានការខ្វែងគំនិតយោបល់ពីចៅក្រមណាម្នាក់ គឺគាត់ត្រូវបានអនុញ្ញាតឲ្យផ្តល់ការវិនិច្ឆ័យផ្ទាល់ខ្លួនរបស់គាត់ រួមជាមួយនឹងការវិនិច្ឆ័យទាំងអស់ ហើយអាននៅក្នុងតុលាការដោយបើកចំហរ មុនតំណាងនៃភាគីជម្លោះ។ សាលក្រមអាចនឹងត្រូវបានកែសម្រួលលុះត្រាតែរកឃើញនូវអង្គហេតុខ្លះ ដែលមិនត្រូវបានដឹងនៅពេលដែលចៅក្រមដំណើរការរឿងក្តី ប៉ុន្តែប្រសិនបើអង្គហេតុត្រូវបានគេស្គាល់ ប៉ុន្តែមិនបានលើកយកមកពិភាក្សាដោយសារតែការធ្វេសប្រហែស នោះសាលក្រមនឹងមិនអាចកែសម្រួលបានទេ។

## កថាខណ្ឌទី៣ ៖ តុលាការយុត្តិធម៌អន្តរជាតិ (ICJ)

តុលាការយុត្តិធមិអន្តរជាតិ មានទីស្នាក់ការនៅទីក្រុងឡាអេនៃប្រទេសហូឡង់។ តុលាការនេះត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៤៥ ដោយធម្មនុញ្ញនៃសហប្រជាជាតិ។ តុលាការនេះចាប់ផ្តើមដំណើរការក្នុងឆ្នាំ ១៩៤៦ ជាអ្នកស្នងបន្តពីតុលាការអចិន្ត្រៃយ៍យុត្តិធមិអន្តរជាតិ។

តុលាការនេះមានទីតាំងនៅវិមានសន្តិភាពក្នុងទីក្រុងឡាអេ ប្រទេសហូឡង់ ដោយធ្វើការចែករំលែកអាគារជាមួយនឹងវិទ្យាស្ថានឧត្តមសិក្សាច្បាប់អន្តរជាតិទីក្រុងឡាអេ ដែលជាមជ្ឈមណ្ឌលសិក្សាឯកជននៃច្បាប់អន្តរជាតិមួយ។ ចៅក្រមមួយចំនួននៃតុលាការនេះគឺជា អតីតសិស្ស ឬជាសមាជិកអតីតសាស្ត្រាចារ្យនៃវិទ្យាស្ថាននេះ។ គោលបំណងរបស់តុលាការយុត្តិធមិអន្តរជាតិ គឺវិនិច្ឆ័យជម្លោះរវាងរដ្ឋនឹងរដ្ឋ។ តុលាការនេះធ្លាប់បានកាត់សេចក្តីពាក់ព័ន្ធនឹងបទឧក្រិដ្ឋសង្គ្រាម, ការជ្រៀតជ្រែកដោយខុសច្បាប់របស់រដ្ឋ និងសីលធម៌រវាងប្រទេសដ៏ទៃ នឹងបន្តយល់ព្រមលើករណីដទៃផ្សេងៗទៀត។

### ៣.១. សញ្ញាណនៃការបង្កើត

ដោយសារតែការផ្ទុះឡើងនូវសង្គ្រាម នាខែកញ្ញា ឆ្នាំ ១៩៣៩ បានធ្វើអោយមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើដំណើរការនៃតុលាការអចិន្ត្រៃយ៍យុត្តិធមិអន្តរជាតិ ដែលបានប្រព្រឹត្តទៅអស់ពេលដ៏យូរមកហើយនោះ។ បន្ទាប់ពីដំណើរការជាសាធារណៈលើកចុងក្រោយ នៅថ្ងៃទី ៤ ខែកញ្ញា ឆ្នាំ ១៩៣៩ មក តុលាការអចិន្ត្រៃយ៍យុត្តិធមិអន្តរជាតិមិនបានពាក់ព័ន្ធជាមួយនឹងការដោះស្រាយបញ្ហាទៀតឡើយ ហើយក៏គ្មានការបោះឆ្នោតជ្រើសរើសចៅក្រមទៀតដែរ។ នៅក្នុងឆ្នាំ ១៩៤០ តុលាការនេះបានផ្លាស់ទីតាំងទៅកាន់ទីក្រុងហ្សឺណែវ ឯចៅក្រមម្នាក់នៅតែមានវត្តមាននៅទីក្រុង

ឡាអេ ជាមួយនឹងមន្ត្រីចុះបញ្ជីមួយចំនួន ដែលមានសញ្ជាតិហូឡង់។ បើទោះបីជាស្ថិតនៅក្នុងសភាពស្មុគស្មាញដោយសារសង្គ្រាមក៏ដោយ ក៏ការគិតអំពីអនាគតរបស់តុលាការនៅតែត្រូវបានធ្វើឡើង។

នៅក្នុងឆ្នាំ ១៩៤២ អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ហើយនិងរដ្ឋមន្ត្រីការបរទេសនៃចក្រភពអង់គ្លេសបានអះអាងពីការយល់ស្រប ក្នុងការបង្កើតឡើងវិញនូវស្ថាប័នតុលាការអន្តរជាតិបន្ទាប់ពីសង្គ្រាមត្រូវបានបញ្ចប់ ហើយគណៈកម្មការច្បាប់របស់សហរដ្ឋអាមេរិចបានផ្តល់អនុសាសន៍អោយបន្តយុត្តាធិការនៃតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ។ នៅដើមឆ្នាំ ១៩៤៣ រដ្ឋាភិបាលនៃចក្រភពអង់គ្លេសបានផ្តើមគំនិតបញ្ជូនអ្នកជំនាញមួយចំនួនទៅទីក្រុងឡុងដ៏ ដើម្បីចងក្រងជាគណៈកម្មាធិការអន្តរសម្ព័ន្ធក្រៅផ្លូវការមួយ សម្រាប់ត្រួតពិនិត្យបញ្ហា។ គណៈកម្មាធិការនេះស្ថិតនៅក្រោមការដឹកនាំរបស់លោក William Malkin ជនជាតិអង់គ្លេស ដែលមានការប្រជុំចំនួន ១៩ ដងដោយមានការចូលរួមពីអ្នកជំនាញផ្នែកច្បាប់ពីប្រទេសចំនួន១១។ នៅក្នុងរបាយការណ៍របស់ខ្លួនដែលបោះផ្សាយនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៤ គណៈកម្មាធិការនេះបានផ្តល់អនុសាសន៍ថា៖

- លក្ខន្តិកៈនៃតុលាការអន្តរជាតិថ្មី គួរតែយកតាមលក្ខន្តិកៈនៃតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិជាមូលដ្ឋាន
- យុត្តាធិការនៃការប្រឹក្សាយោបល់ គួរតែត្រូវបានរក្សាទុកនៅក្នុងតុលាការថ្មីនេះ
- ការទទួលយកនូវដែនសមត្ថកិច្ចនៃតុលាការថ្មី មិនគួរត្រូវបានបង្ខិតបង្ខំឡើយ
- តុលាការមិនគួរមានដែនសមត្ថកិច្ចពាក់ព័ន្ធនឹងបញ្ហានយោបាយទេ។

ទន្ទឹមនឹងនេះដែរ នៅថ្ងៃទី ៣០ ខែតុលារ ឆ្នាំ១៩៤៣ បន្ទាប់ពីមានសន្និសីទរួមគ្នារវាងប្រទេសចិន សហភាពសូវៀត ចក្រភពអង់គ្លេស ហើយនិងសហរដ្ឋអាមេរិច សេចក្តីថ្លែងការរួមមួយត្រូវបានគេទទួលស្គាល់ជាចាំបាច់គឺ "ការបង្កើតនៅកាលបរិច្ឆេទអនុវត្តដំបូងបំផុតនៃអង្គការអន្តរជាតិដោយផ្អែកលើគោលការណ៍សមភាពនៃអធិបតេយ្យភាពរបស់រដ្ឋ ដែលស្រលាញ់សន្តិភាពនិងបើកចំហរដល់សមាជិកភាពទាំងអស់ មិនថារដ្ឋធំ ឬរដ្ឋតូចទេ គឺដើម្បីស្តារសន្តិភាព ហើយនិងសន្តិសុខអន្តរជាតិ"។

ចៅក្រមទាំងអស់នៃតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ បានសុំលាលែងពីតំណែងនៅថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៤៦ ហើយការបោះឆ្នោតជ្រើសរើសសមាជិកចៅក្រមដំបូងនៃតុលាការយុត្តិធម៌អន្តរជាតិ បានប្រព្រឹត្តទៅនៅក្នុងថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៤៦ នៅក្នុងសម័យកាលដំបូងនៃមហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ។ នៅខែមេសា ឆ្នាំ១៩៤៦ តុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ ត្រូវបានរំលាយជាផ្លូវការ ហើយតុលាការយុត្តិធម៌អន្តរជាតិបានបើកការប្រជុំជាលើកដំបូង ដោយធ្វើការបោះឆ្នោតជ្រើសរើសប្រធានចៅក្រមដំបូង គឺលោក José Gustavo Guerrero ជនជាតិអេសាលវាឌ័រ (El Salvador) ដែលជាប្រធានចៅក្រមចុងក្រោយនៃតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ។ តុលាការនេះបានតែងតាំងសមាជិកក្នុងបញ្ជីរបស់ខ្លួន ដែល

មួយចំនួនធំគឺជាអតីតមន្ត្រីផ្លូវការ នៃតុលាការអចិន្ត្រៃយ៍យុត្តិធម៌អន្តរជាតិ ហើយបានប្រារព្ធសម្ពោធសវនាការជាសាធារណៈ នៅថ្ងៃទី១៨ នាខែមេសាដដែលនោះ។ រឿងក្តីដំបូងបានដាក់ស្នើរមកនៅខែឧសភា ឆ្នាំ១៩៤៧ គឺជាងមួយឆ្នាំក្រោយពីការបើកដំណើរការ។ រឿងក្តីនោះបានលើកឡើងអំពីឧប្បត្តិហេតុ នៅព្រែកជីក Corfu ដែលប្តឹងដោយចក្រភពអង់គ្លេសប្រឆាំងនឹងប្រទេសអាល់បានី។

## ៣.២. សមាសភាពចៅក្រម

### ៣.២.១. ចៅក្រមនៃតុលាការ

តុលាការយុត្តិធម៌អន្តរជាតិមានសមាសភាពចៅក្រមចំនួន ១៥ រូប ដែលត្រូវមានសញ្ជាតិខុសៗគ្នា។[40] សមាជិកទាំងអស់ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតរបស់មហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខ តាមសម្លេងភាគច្រើនដាច់ខាតសំរាប់អាណត្តិ ៩ ឆ្នាំ តែសមាជិកមួយភាគបីត្រូវដូរក្នុងរយៈពេលបីឆ្នាំម្តង ស្មើនឹងចំនួនចៅក្រម ៥ រូប។ ដំណើរការបោះឆ្នោតនេះត្រូវបានចែងចាប់ពីមាត្រា ៤-១៩ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ។

- ប្រសិនបើមានសមាជិកចៅក្រមណាម្នាក់បានស្លាប់ គេនឹងបង្កើតអោយមាននូវការបោះឆ្នោតពិសេសមួយ ដើម្បីបំពេញអសនចៅក្រមនោះ។
- ចៅក្រមនៃតុលាការយុត្តិធម៌អន្តរជាតិ មិនត្រូវបានដកហូតចេញពីមុខងារឡើយ និងមានអភ័យឯកសិទ្ធិខាងការទូត តាមមាត្រា ១៩ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ។
- ការជ្រើសរើសសមាជិកចៅក្រមគឺផ្អែកលើលក្ខណៈសមស្របនិងមិនពឹងផ្អែកលើសញ្ជាតិទេ។
- សមាជិកចៅក្រមនៃតុលាការយុត្តិធម៌អន្តរជាតិ មិនអាចមានពីររូបមកពីប្រទេសតែមួយឡើយ។

បើយោងតាមមាត្រា ៩ នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរាជាតិ សមាជិករបស់តុលាការនេះត្រូវបានគេសន្មត់ថាតំណាងឱ្យទំរង់ចម្បង នៃអរិយធម៌និងប្រព័ន្ធច្បាប់សំខាន់ៗរបស់ពិភពលោក។ ចាប់តាំងពីការបង្កើតរបស់ខ្លួនមក សមាជិកអចិន្ត្រៃយ៍បួន ក្នុងចំណោមសមាជិកទាំងប្រាំនៃក្រុមប្រឹក្សាសន្តិសុខ (បារាំង រុស្ស៊ី ចិន អង់គ្លេស និងសហរដ្ឋអាមេរិក) តែងតែមានចៅក្រមមួយរូបនៅក្នុងតុលាការ។ ករណីលើកលែងនោះគឺប្រទេសចិន (សាធារណរដ្ឋចិនរហូតដល់ឆ្នាំ ១៩៧១ និងសាធារណរដ្ឋប្រជាមានិតចិនពីឆ្នាំ ១៩៧១ តមក) ដែលពុំមានចៅក្រមនៅក្នុងតុលាការពីឆ្នាំ ១៩៦៧ រហូតដល់ឆ្នាំ ១៩៨៥ ពីព្រោះតែប្រទេសនេះមិនដាក់បេក្ខភាព។

លក្ខន្តិកៈនៃតុលាការយុត្តិធម៌អន្តរជាតិបានបង្ហាញថា ចៅក្រមទាំងអស់គួរតែត្រូវបានជាប់ឆ្នោតដោយមិនគិតពីសញ្ជាតិរបស់ពួកគេ ក្នុងចំណោមមនុស្សដែលមានសីលធម៌ខ្ពស់បំផុតដែល

[40] មាត្រា ៣ នៃលក្ខន្តិកៈ របស់តុលាការយុត្តិធម៌អន្តរជាតិ

មានទាំងលក្ខណៈសម្បត្តិគ្រប់គ្រាន់ សម្រាប់ការិយាល័យតុលាការជាន់ខ្ពស់បំផុតនៅក្នុងរដ្ឋរបស់ពួកគេ ឬត្រូវបានគេស្គាល់ថាជាមេធាវីមួយរូប ដែលមានសមត្ថភាពគ្រប់គ្រាន់នៅក្នុងនីតិអន្តរជាតិ។ ចៅក្រមនៃតុលាការយុត្តិធម៌អន្តរជាតិគឺមិនអាចទៅកាន់មុខតំណែងផ្សេងទៀត ឬដើរតួជាអ្នកប្រឹក្សាបានឡើយ។ ចៅក្រមមួយរូបអាចត្រូវបានបណ្តេញចេញ លុះត្រាតែមានការបោះឆ្នោតយល់ព្រមជាឯកច្ឆន្ទរបស់សមាជិកដទៃទៀតនៃតុលាការនេះ។

### ៣.២.២. ចៅក្រមបណ្តោះអាសន្ន ( *Ad hoc* judges )

យោងតាមមាត្រា ៣១ នៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ បានបញ្ជាក់ថា បើទោះបីជាចៅក្រមណាម្នាក់មានសញ្ជាតិដូចទៅនឹងគូភាគីណាមួយក៏ដោយ ក៏ចៅក្រមនោះមិនត្រូវបានគេហាមឃាត់នៅក្នុងដំណើរការសម្រេចរឿងក្តីឡើយ។ ប៉ុន្តែគូរភាគីម្ខាងទៀតដែលគ្មានចៅក្រមក្នុងសញ្ជាតិរបស់ខ្លួននោះ អាចស្នើសុំចាត់តាំងបុគ្គលណាម្នាក់ផ្សេងទៀត អោយធ្វើជាចៅក្រមនៅក្នុងរឿងក្តីជំនួសបាន។ ប្រសិនបើគ្មានភាគីណាមួយ មានចៅក្រមសញ្ជាតិដូចខ្លួនទេ គេអាចធ្វើការជ្រើសរើសបុគ្គលណាម្នាក់អោយក្លាយជាចៅក្រមបាន។ ជាទូទៅ ចៅក្រម *Ad hoc* មិនចាំបាច់មានសញ្ជាតិដូចទៅនឹងរដ្ឋដែលជ្រើសរើសក៏បាន ជារួមគឺរដ្ឋជាភាគីជម្លោះអាចជ្រើសរើសចៅក្រម *Ad hoc* ម្នាក់តាមចិត្ត ប្រសិនបើគ្មានសមាជិកចៅក្រមណាម្នាក់មានសញ្ជាតិដូចខ្លួនទេនោះ។ គូភាគីនៃរឿងក្តីត្រូវជូនដំណឹងអោយបានលឿនបំផុតតាមដែលអាចធ្វើទៅបាន ក្នុងចេតនា នៃការជ្រើសរើសចៅក្រម *Ad hoc*។ ចៅក្រម *Ad hoc* មានសិទ្ធិស្មើគ្នាទៅនឹងចៅក្រមផ្សេងទៀតដែរ ក្នុងពេលដែលគេចូលរួមនៅក្នុងរឿងក្តីមួយ។[41]

### ៣.២.៣. ឋិសមិតភាព

ចំពោះឥស្សរៈជនដែលត្រូវបានជ្រើសរើសធ្វើជាចៅក្រមហើយ នៅពេលកំពុងបំពេញមុខងារ ពួកគេពុំអាចទៅធ្វើការងារផ្សេងទៀត ដូចជាការងារនយោបាយ ឬធ្វើការឲ្យរដ្ឋាភិបាលណាមួយបានទេ ហើយក៏មិនអាចកាន់កាប់កន្លែងណាមួយដែលមានលក្ខណៈជាវិជ្ជាជីវៈដែរ។ មួយវិញទៀត ចៅក្រមនៅក្នុងមុខងារ ត្រូវបានហាមឃាត់មិនឲ្យធ្វើជាភ្នាក់ងារ ក្រុមប្រឹក្សា ឬមេធាវីក្នុងរឿងក្តីណាមួយឡើយ។ ក្នុងករណីមានការពាក់ព័ន្ធរឿងរ៉ាវទាំងអស់នោះ តុលាការអន្តរជាតិនឹងធ្វើការប្រជុំសម្រេច ព្រោះថាចៅក្រមដែលជាប់ឆ្នោតមានលក្ខណៈឯករាជ្យ ដោយមិនចំណុះឲ្យរដ្ឋរបស់ខ្លួនឡើយ។

[41] មាត្រា ៧ នៃវិធានផ្ទៃក្នុងរបស់តុលាការយុត្តិធម៌អន្តរជាតិ

## ៣.៣. ដែនសមត្ថកិច្ចនៅក្នុងករណីវិវាទ

តុលាការត្រូវសម្រេចចិត្តទទួលយករឿងវិវាទដែលបានដាក់មកដោយសេរី តាមរយៈរដ្ឋនៅក្នុងការជ្រើសរើសដោយអធិបតេយ្យរបស់ពួកគេ។ ប្រទេសដែលជាសមាជិករបស់អង្គការសហប្រជាជាតិ សុទ្ធតែត្រូវបានចាត់ទុកជាសមាជិកនៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ។ ចំណែកឯបណ្តាប្រទេស ដែលមិនមែនជាសមាជិករបស់អង្គការសហប្រជាជាតិ ក៏អាចចូលរួមក្នុងលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិបានដែរ ប្រសិនបើមានការស្នើឡើងរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ និងត្រូវបានមហាសន្និបាតទទួលយល់ព្រម។

គួរកត់សម្គាល់ផងដែរថា រហូតមកដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣ មានរដ្ឋចំនួន ១៩៣ ជាភាគីនៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តជាតិ។[42]

សមាជិកចៅក្រម នៃតុលាការយុត្តិធម៌អន្តរជាតិ មិនអាចធ្វើជាតំណាងរដ្ឋាភិបាលរបស់ខ្លួនបានឡើយ ពីព្រោះចៅក្រមម្នាក់ៗត្រូវមានភាពឯករាជ្យ ដោយមិនអាចអនុវត្តនូវមុខងារនយោបាយ ឬរដ្ឋបាល ឬពាក់ព័ន្ធទៅនឹងការងារអាជីពផ្សេងទៀតឡើយ។[43]

## ៣.៤. នីតិវិធីនៃបណ្តឹង

នីតិវិធីនៃបណ្តឹងរបស់តុលាការយុត្តិធម៌អន្តរជាតិ ត្រូវបានកំណត់នៅក្នុងលក្ខន្តិកៈ(ចាប់ពីមាត្រា ៣៩ រហូតដល់មាត្រា ៦៤) និងបទបញ្ញាតិនានារបស់តុលាការ។

បណ្តឹងត្រូវបានបែងចែកជាពីរប្រភេទគឺ បណ្តឹងដែលកើតចេញពីកិច្ចព្រមព្រៀងពិសេស និងបណ្តឹងដែលកើតចេញតាមការដាក់ពាក្យស្នើរសុំ។[44]

- បណ្តឹងដែលកើតចេញពីកិច្ចព្រមព្រៀងពិសេសៈ គឺភាគីជម្លោះទាំងពីរយល់ព្រមជ្រើសរើសយកយុត្តាធិការតុលាការយុត្តិធម៌អន្តរជាតិមកដោះស្រាយ ហើយភាគីណាមួយ រឺភាគីទាំងពីរ ដាក់លិខិតបញ្ជាក់ពីកិច្ចព្រមព្រៀងពិសេស ដោយត្រូវបង្ហាញពីកម្មវត្ថុនៃជម្លោះ និងគូភាគីនៃរឿងក្តីនោះ។
- បណ្តឹងដែលកើតចេញតាមការដាក់ពាក្យស្នើរសុំៈ គឺភាគីរដ្ឋដើមចោទ ដាក់ពាក្យប្តឹងរដ្ឋជាភាគីចុងចោទ។ ការដាក់ពាក្យសុំប្តឹងក្នុងគោលបំណងធ្វើទំនាក់ទំនងទៅនឹងរដ្ឋចុងចោទ។

[42]របាយការណ៍ប្រចាំឆ្នាំរបស់តុលាការយុត្តិធម៌អន្តរជាតិ ពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០១២ដល់ថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ២០១៣ ទំព័រទី១០

[43]មាត្រា ១៦ នៃលក្ខន្តិកៈ របស់តុលាការយុត្តិធម៌អន្តរជាតិ

[44]មាត្រា ៤០ នៃលក្ខន្តិកៈ របស់តុលាការយុត្តិធម៌អន្តរជាតិ

នៅក្នុងពាក្យបណ្ដឹងនោះត្រូវសរសេរពីឈ្មោះភាគីដែលប្ដឹង និងកម្មវត្ថុនៃជម្លោះ។ រដ្ឋដើមចោទត្រូវបង្ហាញពីមូលដ្ឋានគ្រឹះដូចជា សន្ធិសញ្ញា ឬសេចក្ដីប្រកាសទទួលស្គាល់សមត្ថកិច្ចរបស់តុលាការយុត្តិធម៌អន្តរជាតិ មានសមត្ថកិច្ចដោះស្រាយរឿងក្ដីនោះ។

នីតិវិធីត្រូវចែកចេញជាពីរគឺ នីតិវិធីជាលាយលក្ខអក្សរ និងនីតិវិធីផ្ទាល់មាត់។[45]

### ៣.៤.១. នីតិវិធីជាលាយលក្ខអក្សរ

ដំណាក់កាលជាលាយលក្ខអក្សរ គឺជាដំណាក់កាលដំបូង ដោយភាគីនីមួយៗដាក់ជូនទៅតុលាការនូវសេចក្ដីថ្លែងសំអាង រួមមានការរៀបរាប់ពិស្ដារពីអង្គហេតុ និងអង្គច្បាប់ដែលភាគីម្ខាងទាញយកមកសំអាង ព្រមទាំងឆ្លើយតបទៅនឹងចំណោទសួររបស់ភាគីម្ខាងទៀត។ ភាគីម្ខាងៗមានសិទ្ធិជ្រើសរើសដោយសេរីនូវទម្រង់បែបបទនៃការជូនសេចក្ដីសំអាង ឯកសារពាក់ព័ន្ធទាំងឡាយអាចត្រូវបានយកមកបន្ថែម ប៉ុន្តែប្រសិនបើការផ្លាស់ប្ដូរនោះមានរយៈពេលយូរពេក ត្រូវតែដកស្រង់យកតែចំនុចណាដែលល្អប៉ុណ្ណោះ។ តុលាការអាចស្នើសុំពីភាគីនូវឯកសារផ្សេងៗ ក្នុងពេលបណ្ដឹងជាលាយលក្ខអក្សរ។

### ៣.៤.២. នីតិវិធីដោយផ្ទាល់មាត់

ជាគោលការណ៍ ដំណាក់កាលដោយផ្ទាល់មាត់ ត្រូវធ្វើឡើងក្នុងរយៈពេល ២ ឬ ៣ ខែ ក្រោយពីការបញ្ចប់នីតិវិធីដោយលាយលក្ខអក្សរ។ កាលបរិច្ឆេទនេះ ត្រូវសំរេចដោយតុលាការដើម្បីផ្ដល់ភាពងាយស្រួលដល់ភាគីទាំងឡាយដែលចង់បានពេលវេលាដ៏សមរម្យមួយ។ រាល់សវនាការរបស់តុលាការយុត្តិធម៌អន្តរជាតិ ត្រូវធ្វើឡើងជាសាធារណៈ ប៉ុន្តែភាគីនៃរឿងក្ដីអាចស្នើរសុំតុលាការមិនបើកសវនាការជាសាធារណៈបាន។

### ៣.៤.៣. ការប្ដឹងទាស់លើកដំបូង

នីតិវិធីនៃការប្ដឹងទាស់លើកដំបូង គឺជាញឹកញាប់លើកឡើងដោយភាគីចុងចោទ។ ការប្ដឹងទាស់នេះ ធ្វើឡើងដើម្បីទប់ស្កាត់ពីតុលាការនៅក្នុងការចេញសាលក្រមសម្រេចរឿងក្ដី ហើយការជំទាស់ត្រូវផ្អែកលើលក្ខខណ្ឌណាមួយដូចជា:

- រដ្ឋត្រូវបានគេចោទប្រកាន់ ឬរដ្ឋចុងចោទបានអះអាងថា សន្ធិសញ្ញា ឬសេចក្ដីប្រកាសទទួលយកសមត្ថកិច្ចតុលាការនេះ ត្រូវទុកជាមោឃៈ ឬមិនអាចអនុវត្តបាន។
- រឿងក្ដីដែលកំពុងប្រកាសនេះ កើតឡើងនៅមុនពេលអនុវត្តសន្ធិសញ្ញាដែលដើមចោទ យកមកសំអាង។

[45]មាត្រា ៤៣ នៃលក្ខន្តិកៈ របស់តុលាការយុត្តិធម៌អន្តរជាតិ

### ៣.៤.៤. ការមិនចូលខ្លួនមកតុលាការ

លក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ក៏មានចែងផងដែរក្នុងករណីដែលរដ្ឋចុងចោទមិនបង្ហាញខ្លួនចំពោះមុខតុលាការ ឬហេតុផលផ្សេងៗទៀតតាមមាត្រា ៥៣ នៃលក្ខន្តិកៈ។ ការខកខានរបស់ភាគីមួយនៅក្នុងការបង្ហាញខ្លួន គឺមិនបង្អាក់ដល់ដំណើរការនៃនីតិវិធីបណ្តឹងនៃរឿងក្តីនោះឡើយ។

### ៣.៤.៥. វិធានការបណ្តោះអាសន្ន

នៅពេលដែលគេឃើញថា សិទ្ធិដែលបង្កើតជាកម្មវត្ថុ នៃការប្តឹងនេះបិតនៅក្នុងភាពជាបណ្តោះអាសន្នបន្ទាន់នោះ រដ្ឋដែលប្តឹងអាចស្នើរសុំ អោយតុលាការបង្ហាញវិធានការបណ្តោះអាសន្នដើម្បីការពារបាន។ ក្នុងពេលសមស្រប តុលាការអាចកោះហៅភាគីនីមួយៗអោយបញ្ឈប់នូវរាល់សកម្មភាពដែលទាក់ទងនឹងសេចក្តីសម្រេចរបស់តុលាការ ដែលអាចលើកឡើងតាមការស្នើរសុំ។ តុលាការអាចអាចបដិសេធចំពោះការសុំវិធានការបណ្តោះអាសន្ននេះបាន។ នៅក្នុងដំណាក់កាលនៃបណ្តឹងនេះ រដ្ឋដែលត្រូវបានគេចោទប្រកាន់អាចជំទាស់ទៅនឹងសមត្ថកិច្ចរបស់តុលាការ ឬអាចមិនបង្ហាញខ្លួន ហើយក្នុងករណីនេះតុលាការនឹងប្រើវិធានការបណ្តោះអាសន្ន លុះត្រាតែភស្តុតាងបង្ហាញថាតុលាការគ្មានសមត្ថកិច្ចពិតប្រាកដ។

## ៣.៥. វិធីសាស្ត្រដោះស្រាយរឿងក្តី

វិធីសាស្ត្រ ៣ យ៉ាងត្រូវបានតុលាការយកមកអនុវត្តន៍ប្រើសន្និដ្ឋានទៅលើរឿងក្តី។ វិធីទាំងនោះរួមមានៈ

- ដំណាក់កាលរវាងគូភាគីនៃរឿងក្តីៈ នៅក្នុងដំណាក់កាលនេះ គូភាគីអាចជូនដំណឹងទៅតុលាការថាខ្លួនបានឈានទៅដល់ការស្រុះស្រួលគ្នាវិញហើយ ដូចនេះតុលាការត្រូវចេញដីកាមួយដើម្បីតំកល់រឿងក្តីទុកមិនចាត់ការ។
- ការបញ្ឈប់រឿងក្តីៈ រដ្ឋដើមចោទ អាចជូនដំណឹងទៅដល់តុលាការ មិនធ្វើការប្តឹងតទៅទៀត ឬភាគីទាំងពីរព្រមព្រៀងគ្នាដកពាក្យបណ្តឹងវិញ។ ហើយក្នុងករណីនេះតុលាការចេញដីកាតំកល់ទុករឿងក្តីមិនចាត់ការ។
- តុលាការចេញសាលក្រមដើម្បីបញ្ចប់រឿងក្តី។ ការសន្និដ្ឋានបញ្ចប់រឿងក្តីដោយចេញសាលក្រមនេះ គឺជាវិធីសាមញ្ញមួយក្នុងការនាំយករឿងក្តីទៅដល់ទីបញ្ចប់។

### ៣.៥.១ សេចក្តីសម្រេច

បន្ទាប់ពីភាគីបានបំពេញសព្វគ្រប់នូវសេចក្តីរាយការណ៍ អំពីរឿងក្តីរបស់ខ្លួនមក ភារកិច្ចបន្តគឺជាតួនាទីរបស់តុលាការ ក្នុងការរៀបចំសាលក្រម។ ដោយហេតុថា តុលាកាយុត្តិធម៌អន្តរជាតិ មានសមាសភាពចៅក្រមមកពីបណ្តាប្រទេសផ្សេងៗគ្នា ដូចនេះការពិភាក្សារបស់តុលាការ ត្រូវរៀបចំតាមវិធីសាស្ត្រមួយ ដែលអាចអោយចៅក្រមម្នាក់ៗ មានឱកាសស្មើគ្នាក្នុងការចូលរួមធ្វើសេចក្តីសម្រេច។

សាលក្រមត្រូវបានបែងចែកជាបីផ្នែកធំៗ តាមប្រព័ន្ធច្បាប់របស់ប្រទេស ដែលប្រកាន់យក Civil Law:

- ផ្នែកទី១ សេចក្តីផ្តើមៈ ក្នុងនោះមានចែងអំពីឈ្មោះចៅក្រមដែលបានចូលរួម និងតំណាងរបស់ភាគី ព្រមទាំងសង្ខេបអង្គហេតុ និងចែងពីការសន្និដ្ឋានរបស់ភាគីនីមួយៗ។
- ផ្នែកទី២ ភស្តុតាងដែលតុលាការយកមកសំអាង ក្នុងការចេញសាលក្រម
- ផ្នែកទី៣ ការសម្រេចសេចក្តីរបស់តុលាការ

ការវិនិច្ឆ័យរបស់តុលាការអន្តរជាតិ គឺបិទផ្លូវតវ៉ា ដោយមិនអនុញ្ញាតអោយមានបណ្តឹងបន្តរឡើយ។[46] គោលការណ៍នេះ ត្រូវបានអនុវត្តទៅលើគ្រប់សេចក្តីសម្រេចរបស់តុលាការ ទោះបីជាសាលក្រមចេញដោយសវនាការពេញអង្គ(Full beach) ឬដោយសវនាការអង្គតូច(Chamber)។ តាមការចុះហត្ថលេខាលើធម្មនុញ្ញអង្គការសហប្រជាជាតិ រដ្ឋជាសមាជិកទាំងឡាយបានទទួលរាប់រងអនុវត្តរាល់សេចក្តីសម្រេចរបស់តុលាការដែលខ្លួនជាភាគីនោះ។ ប្រសិនបើគូភាគីណាមួយ មិនប្រតិបត្តិតាមកាតព្វ អនុវត្តតាមសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិទេ ភាគីម្ខាងទៀតអាចពឹងលើក្រុមប្រឹក្សាសន្តិសុខបាន ហើយក្រុមប្រឹក្សាសន្តិសុខអាចចាត់វិធានការទាំងឡាយ ដើម្បីអោយភាគីនោះអនុវត្តនូវសេចក្តីសម្រេចរបស់តុលាការ។[47]

### ៣.៦. ការបកស្រាយសាលក្រម

ដោយហេតុថាតុលាការយុត្តិធម៌អន្តរជាតិជាអ្នកមានសមត្ថកិច្ចក្នុងការចេញសាលក្រម ដូចនេះតុលាការនេះក៏ជាអ្នកមានសមត្ថកិច្ចក្នុងការបកស្រាយសាលក្រមដែរ។ តាមការស្នើសុំរបស់ភាគីនៃរឿងក្តី តុលាការអាចធ្វើការបកស្រាយសាលក្រមណាដែលមានការខ្វែងគំនិតគ្នារវាងភាគី ទៅលើអត្ថន័យ និងព្រំដែននៃអ្វីដែលតុលាការបានសម្រេច។

---

[46]មាត្រា ៦០ នៃលក្ខន្តិកៈ របស់តុលាការយុត្តិធម៌អន្តរជាតិ

[47]មាត្រា ៩៤ ជំពូកទី ១៤ នៃធម្មនុញ្ញសហប្រជាជាតិ

# ជំពូក៣ ៖ ករណីសិក្សាស្តីពីដំណោះស្រាយវិវាទអន្តរជាតិ

## ផ្នែកទី២ ៖ ករណីសិក្សាស្តីពីដំណោះស្រាយវិវាទអន្តរជាតិ តាមប្រព័ន្ធតុលាការ

### កថាខណ្ឌ១ ៖ វិវាទព្រំដែនរវាង បូគីណា ហ្វាសសូរ និង នីហ្សេ ( Burkina Faso & Niger )ដែលដោះស្រាយដោយតុលាការយុត្តិធម៌អន្តរជាតិ

#### ១.១. ប្រវត្តិនៃវិវាទ

ដើមចមដំបូងនៃវិវាទ រវាងប្រទេស បូគីណា ហ្វាសសូរ និងប្រទេសនីហ្សេរ គឺបានកើតចេញពីការកំណត់ព្រំដែនដ៏ចម្រូងចម្រាស កំឡុងពេលដែលប្រទេសទាំងពីរនេះស្ថិតនៅក្រោមអាណានិគមនិយមបារាំង។ ការពុះចែកចំពាក់កណ្តាលនៃបន្ទាត់ព្រំដែនរវាងរដ្ឋទាំងពីរ ត្រូវបានធ្វើឡើងដោយអាណាព្យាបាលបារាំងនៅក្នុងឆ្នាំ ១៩២៧ គឺកំឡុងពេលដែលប្រទេសទាំងពីរស្ថិតនៅក្រោមអាណានិគមនិយមបារាំង។ តែទោះបីជាយ៉ាងណាក៏ដោយ ប្រទេសទាំងពីរហាក់ដូចជាមិនអាចឈានដល់ការព្រមព្រៀង ក្នុងការទទួលយកចំពោះការកំណត់នេះឡើយ។ នៅក្នុងឆ្នាំ ១៩៨៧ កិច្ចព្រមព្រៀងរវាង ប្រទេសបូគីណា ហ្វាសសូរ និង នីហ្សេរ បានបង្ហាញនូវខដាក់លក្ខខណ្ឌថា ប្រសិនបើការកំណត់ដោយបារាំងនេះ មានចំណុចខ្វះខាតក្នុងការបង្ហាញនូវភស្តុតាងដើម្បីកំណត់ពីព្រំដែនច្បាស់លាស់នៅលើផ្ទៃដីនោះ រដ្ឋទាំងពីរបានយល់ព្រមថា ការកម្រិតព្រំដែនគឺត្រូវយកតាមខ្សែបន្ទាត់ដែលបានគូសឡើងនៅក្នុងឆ្នាំ ១៩៦០ តាមផែនទីដែលមានមាត្រដ្ឋាន ១/២០០០០០ ដែលធ្វើឡើងដោយវិទ្យាស្ថានភូមិសាស្ត្រជាតិ(GNI)។ ទោះបីជាបែបនេះក៏ដោយ តុលាការអន្តរជាតិបានរង់ចាំការកំណត់ព្រំដែនរវាងប្រទេស ប្រទេសបូគីណា ហ្វាសសូរ និងនីហ្សេរដោយយកតាមការកំណត់ខ្សែបន្ទាត់ដោយបារាំងនៅក្នុងឆ្នាំ១៩២៧ និងបំពេញបន្ថែមដោយការបកស្រាយតាមផែនទីដែលមានមាត្រដ្ឋាន ១/២០០០០០ ធ្វើឡើងដោយវិទ្យាស្ថានភូមិសាស្ត្រជាតិ។ សូមបញ្ជាក់ថា ព្រំដែនដែលមានជម្លោះ គឺមានប្រវែងប្រមាណ ៦៥០ គីឡូម៉ែត។

#### ១.២. គូភាគីក្នុងរឿងក្តី

##### ១.២.១. ប្រទេសបូគីណា ហ្វាសសូរ ( Bukina Faso )

ប្រទេសបូគីណា ហ្វាសសូរ ហៅកាត់ថា ប្រទេស បូគីណា គឺជាប្រទេសមួយដែលពុំមានព្រំប្រទល់ជាប់នឹងឆ្នេរសមុទ្រទេ។ ប្រទេស បូគីណា មានទីតាំងស្ថិតនៅទ្វីបអាហ្វ្រិកខាងលិច ជាមួយនឹងផ្ទៃដី ២៧៤ ២០០ គីឡូម៉ែតការ៉េ។ ប្រទេសនេះមានព្រំប្រទល់ជាប់ប្រទេស ៦ ផ្សេងគ្នា គឺខាងជើង ជាប់នឹងប្រទេសម៉ាលី ខាងកើតជាប់ជាមួយនឹងប្រទេសនីហ្សេរ ខាងត្បូងជាប់នឹងប្រទេស ទូហ្គោ និងប្រទេសហ្គាណា ភាគអាគ្នេយ៍ជាប់នឹងប្រទេសបីនីន និងភាគនិរតីជាប់នឹងប្រទេសកូឌីវ័រ។ នៅ ក្នុង

ឆ្នាំ២០១០ ប្រទេស បូគីណា មានប្រជាជនប្រហែល១៥ ៧៥០ ០០០នាក់។ ប្រទេសនេះរួចផុតពីអាណានិគមនិយមបារាំងនៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ១៩៦០។ របបនយោបាយរបស់ប្រទេសនេះគឺសាធារណៈរដ្ឋពាក់កណ្តាលប្រធានាធិបតី។ បច្ចុប្បន្នប្រទេសនេះ ដឹកនាំដោយប្រធានាធិបតី Blaise Compaoré និងនាយករដ្ឋមន្ត្រីឈ្មោះLuc-Adolphe Tiao។ រដ្ឋធានីនៃប្រទេសនេះគឺOuagadougou។

**១.២.២. ប្រទេស នីហ្សេរ** ( Niger )

ប្រទេសនីហ្សេរ គឺជាប្រទេសមួយដែលពុំមានព្រំប្រទល់ជាប់នឹងឆ្នេរសមុទ្រ ដូចគ្នាទៅនឹងប្រទេស បូគីណាដែរ។ ប្រទេសនីហ្សេរ មានទីតាំងស្ថិតនៅទ្វីបអាហ្វ្រិកខាងលិច ជាមួយនឹងផ្ទៃដី ១ ២៧០ ០០០ គីឡូម៉ែតការ៉េ ដែលធ្វើឲ្យប្រទេសនេះ ក្លាយទៅជាប្រទេសមួយដែលមានផ្ទៃដីធំជាងគេបំផុតនៅក្នុងទ្វីបអាហ្វ្រិកភាគខាងលិច។ ៨០ ភាគរយ នៃផ្ទៃដីរបស់ប្រទេសនីហ្សេរ គ្របដណ្តប់ទៅដោយវាលខ្សាច់សាហារ៉ា។ ប្រទេសនេះមានព្រំប្រទល់ជាប់ប្រទេស ៧ ផ្សេងគ្នា គឺខាងជើងជាប់នឹងប្រទេសលីប៊ី និងប្រទេសអាល់ហ្សេរី ខាងត្បូងជាប់នឹងប្រទេស នីហ្សេរីយ៉ា និងប្រទេសបឺនីនខាងកើតជាប់ជាមួយនឹងប្រទេសឆាត និងខាងលិចជាប់ជាមួយប្រទេសបូគីណា និងប្រទេសម៉ាលី។ ប្រជាជនភាគច្រើនគឺជាជនជាតិឥស្លាម ដែលមានប្រមាណជាង ១៥ លាននាក់។ រដ្ឋធានីនៃប្រទេសនេះគឺ Niamey។

ប្រទេសនេះរួចផុតពីអាណានិគមនិយមបារាំងនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ១៩៦០។ របបនយោបាយរបស់ប្រទេសនេះគឺ សាធារណៈរដ្ឋពាក់កណ្តាលប្រធានាធិបតី។ បច្ចុប្បន្នប្រទេសនេះដឹកនាំដោយប្រធានាធិបតី Mahamadou Issoufou និងនាយករដ្ឋមន្ត្រីឈ្មោះ Brigi Rafini។

## ១.៣. សេចក្តីប្រកាសរួមរបស់គូភាគី

សេចក្តីប្រកាសរបស់គូភាគី ទៅកាន់តុលាការអន្តរជាតិ និងរដ្ឋជាសមាជិកអង្គការសហប្រជាជាតិ គឺលើកឡើងអំពីជម្លោះទៅយុត្តាធិការតុលាការ ដោយបញ្ចូលទៅក្នុងកិច្ចព្រមព្រៀងពិសេស ដោយអនុលោមទៅតាមមាត្រា៣៦ វាក្យខណ្ឌ១ នៃបទបញ្ញត្តិរបស់តុលាការយុត្តិធម៌អន្តរជាតិ។ កិច្ចព្រមព្រៀងពិសេស គឺជាកិច្ចព្រមព្រៀងទ្វេភាគីតាមទំរង់ ដែលអាចត្រូវបានចុះហត្ថលេខានៅចំពោះមុខតុលាការយុត្តិធម៌អន្តរជាតិ។ កិច្ចព្រមព្រៀងពិសេសត្រូវបង្ហាញអំពីកម្មវត្ថុនៃជម្លោះ ហើយនិងគូភាគីនៅក្នុងជម្លោះ ដោយផ្អែកទៅលើការយល់ព្រមជាក់ស្តែង។

## ១.៤. ការទាមទាររបស់ភាគីក្នុងរឿងក្តី

**១.៤.១. ការទាមទាររបស់ប្រទេសបូគីណា ហ្វាសសូរ** ( Burkina Faso )

យោងទៅតាមការពិចារណា នៅក្នុងការលើកឡើងការប្រឆាំង និងការពិភាក្សាវែកញែកដោយផ្ទាល់ ប្រទេសបូគីណា ហ្វាសូរ មានកិត្តិយសក្នុងការស្នើសុំឲ្យតុលាការយុត្តិធម៌អន្តរជាតិ ធ្វើ

ការសម្រេចនិងអះអាងថា ព្រំដែនរវាង ប្រទេសបួគីណា ហ្វាសសូរ និងនីហ្សេរត្រូវយកតាមចំណុចដែលបានរៀបរាប់ដូចខាងក្រោម៖

១. ពីចំណុចកម្ពស់តំបន់ N'Gouma ទៅតំបន់ភូមិសាស្ត្រ Tong-Tong ព្រំដែនត្រូវយកតាមការកំណត់ដូចតទៅខ្សែបន្ទាត់ត្រង់ជាបន្តបន្ទាប់ត្រូវស្របទៅតាមចំណុច

ភ្នំ N'Gouma (Lat. 14° 54' 46.0" N; Long. 0° 14' 36.4" E), តំបន់ Kabia Ford (Lat. 14° 53' 09.8" N; Long. 0° 13' 06.3" E), ភ្នំ Arwaskoye (Lat. 14° 50' 44.7" N; Long. 0° 10' 35.8" E), ភ្នំ Bellé Banguia (Lat. 14° 45' 05.2" N; Long. 0° 14' 09.6" E), តំបន់ Takabougou (Lat. 14° 37' 54.5" N; Long. 0° 10' 16.1" E), Mount Douma Fendé (Lat. 14° 32' 00.6" N; Long. 0° 09' 42.1" E) and the Tong-Tong astronomic marker (Lat. 14° 24' 53.2" N; Long. 0° 12' 51.7" E);

២. ចាប់ពីតំបន់ភូមិសាស្ត្រ Tong-Tong ទៅចំណុចចាប់ផ្តើមនៃតំបន់បត់បែន Botou ព្រំដែនត្រូវយកតាមការកំណត់ដូចតទៅ:

→ ខ្សែបន្ទាត់ត្រង់តាមតំបន់ភូមិសាស្ត្រ Tao កំណត់តាម (Lat. 14° 03' 04.7" N; Long. 0° 22' 51.8" E)

→ ចាប់ពីចំណុចនោះ ខ្សែបន្ទាត់ត្រង់ដែលអូសរហូតទៅដល់ចំនុច ដែលព្រំដែនជួបប្រសព្វជាមួយទន្លេ Sirba នៅតំបន់ Bossébangou (Lat. 13° 21' 06.5" N; Long. 1° 17' 11.0" E)

→ ចាប់ពីចំណុចនោះ បន្ទាត់ព្រំដែនត្រូវយកតាមច្រាំងខាងស្តាំនៃទន្លេ Sirba ចាប់ពីខាងកើតទៅខាងលិច រហូតដល់ចំណុចខាងស្តាំនៃច្រាំងទន្លេ ជាមួយនឹងកូអរដោនេ 13° 19' 53.5" N; Long. 1° 07' 20.4" E

→ ចាប់ពីចំណុចនោះ បន្ទាត់ព្រំដែនត្រូវយកតាមខ្សែបន្ទាត់នៅលើផែនទីខ្នាត ១/២០០ ០០០ របស់បារាំង ដែលធ្វើឡើងក្នុងឆ្នាំ១៩៦០ រហូតដលចំនុចកូអរដោនេ Lat. 13° 22' 30.0" N; Long. 0° 59' 40.0" E

→ ចាប់ពីចំណុចនោះ បន្ទាត់ព្រំដែនរត់ត្រង់នៅប៉ែកខាងត្បូងតាមខ្សែបន្ទាត់ត្រង់ រួចបញ្ចប់នៅចំណុចប្រសព្វខាងស្តាំនៃច្រាំងទន្លេ និងតំបន់ Say ត្រង់ខ្សែស្រប (Lat. 13° 06' 10.7" N; Long. 0° 59' 40.0")

→ ចាប់ពីចំណុចនោះ បន្ទាត់ព្រំដែនរត់ត្រង់ឡើងដល់ចំនុចចាប់ផ្តើមនៃតំបន់បត់បែន Botou (Lat. 12° 36' 19.2" N; Long. 1° 52' 06.9" E)

៣. ចាប់ពីចំណុចចាប់ផ្តើមនៃតំបន់បត់បែន Botou ទៅដល់ទន្លេ Mekrou បន្ទាត់ព្រំដែនត្រូវយកតាមចំណុចដូចតទៅ:

→ ខ្សែបន្ទាត់ត្រង់ដែលភ្ជាប់តំបន់ភូមិសាស្រ្តដូចតទៅ: ភ្នំ Jackal (Lat. 12° 41' 33.1" N; Long. 1° 55' 43.9" E), Laguil (Lat. 12° 41' 31.9" N; Long. 1° 57' 1.3" E) and Nonbokoli (Lat. 12° 44' 12.9" N; Long. 1° 58' 47.0" E)

→ ចាប់ពីចំណុចក្រោយ បន្ទាត់ព្រំដែនត្រូវយកតាមខ្សែបន្ទាត់កណ្តាល នៃតំបន់ Dantiabonga *marigot* ឆ្លងទៅភាគខាងត្បូងនៃតំបន់ Dantiandou បន្ទាប់មកយកតាមខ្សែបន្ទាត់នៃចំណោត Yoga Djoaga រហូតដល់ចំនុចប្រសព្វនៃតំបន់ Dyamongou និងទន្លេ Dantiabonga (Lat. 12° 43' 15.1" N; Long. 2° 05' 14.9" E)

→ ចាប់ពីចំណុចនោះ បន្ទាត់ព្រំដែនត្រូវយកតាមខ្សែបន្ទាត់កណ្តាល នៃទន្លេ Dyamongou រហូតដល់ចំណុចប្រសព្វនៃតំបន់ Dyamongou marigot ហើយនិងតំបន់ Boulel Fouanou (Lat. 12° 43' 44.0" N; Long. 2° 06' 23.9")

→ ចាប់ពីចំណុចនោះ បន្ទាត់ព្រំដែនត្រូវរត់តាមខ្សែបន្ទាត់ ដែលតភ្ជាប់ចំណុចដូចខាងក្រោម:

តំបន់ Boulel (Lat. 12° 42' 15.1" N; Long. 2° 06' 53.3" E), តំបន់ Boulel ខាងកើត (Teylinga) (Lat. 12° 41' 09.5" N; Long. 2° 09' 43.2" E), តំបន់ Dyapionga ខាងជើង (Lat. 12° 39' 42.3" N; Long. 2° 09' 37.3" E), តំបន់ Dyapionga ខាងត្បូង (Lat. 12° 38' 55.4" N; Long. 2° 09' 08.1" E), តំបន់ Kanleyenou (Lat. 12° 37' 21.7" N; Long. 2° 11' 57.1" E), តំបន់ Niobo Farou (Caiman Pool) (Lat. 12° 35' 19.6" N; Long. 2° 13' 23.9" E), កំពូលខាងកើតបំផុតនៃភ្នំ Tambouadyoaga (Lat. 12° 31' 19.7" N; Long. 2° 13' 48.0" E), តំបន់ Banindyididouana (Lat. 12° 27' 52.7" N; Long. 2° 16' 27.2" E) ហើយនិង ចំណុចហូរប្រសព្វនៃទន្លេ Banindyidi Fouanou និងទន្លេ Tapoa(Lat. 12° 25' 30.5" N; Long. 2° 16' 40.6" E)

→ ចាប់ពីចំណុចក្រោយ នៃចំនុចទាំងនោះ បន្ទាត់ព្រំដែនត្រូវកំណត់តាមខ្សែកណ្តាល នៃទន្លេ Tapoa ទៅដល់ចំណុចណាដែលកាត់ជាមួយនឹងព្រំដែនមុននៃតំបន់ Fada និង តំបន់ Say (Lat. 12° 21' 04.88" N; Long. 2° 04' 12.77" E)

→ ចាប់ពីចំណុចក្រោយ ព្រំដែនត្រូវរត់តាមខ្សែត្រង់ ដោយស្មើទៅនឹងខ្សែបន្ទាត់មុន Fada និង តំបន់ Say រហូតដល់ចំណុចដែលវាប្រសព្វជាមួយនឹងទន្លេ Mekrou (Lat. 11° 54' 07.83" N; Long. 2° 24' 15.25" E)។

ដោយអនុលោមទៅតាមមាត្រ ៧ កថាខណ្ឌទី៤ នៃកិច្ចព្រមព្រៀងពិសេស ប្រទេសបួគីណា អាចស្នើសុំតុលាការឲ្យតែងតាំងអ្នកជំនាញបីនាក់ ដើម្បីជួយគូភាគីទាំងពីរ ប្រសិនបើមានតំរូវការចាំបាច់ក្នុងការកំណត់ព្រំដែន។

### ១.៤.២. ការទាមទាររបស់ប្រទេស នីហ្សេរ (Niger)

ប្រទេសនីហ្សេរ បានស្នើរសុំទៅសុំឲ្យតុលាការយុត្តិធម៌អន្តរជាតិ ធ្វើការសម្រេចនិងអះអាងថាព្រំដែនរវាងប្រទេសប្រទេសបួគីណា ហ្វាសសូរ និងនីហ្សេរត្រូវកំណត់ដូចខាងក្រោម:

→ ចាប់ផ្តើពីតំបន់ភូមិសាស្ត្រ Tong-Tong (កូអរដោនេ: 14° 25' 04" N, 00° 12' 47" E)

→ ចាប់ពីចំនុចនោះ បន្ទាត់ព្រំដែនត្រូវរត់តាមខ្សែត្រង់ រហូតដល់តំបន់ Vibourié(កូអរដោនេ: 14° 21' 44" N, 0° 16' 25" E)

→ ចាប់ពីចំនុចនោះ បន្ទាត់ព្រំដែនត្រូវរត់តាមខ្សែត្រង់ រហូតដល់តំបន់ភូមិសាស្ត្រ Tao (កូអរដោនេ: 14° 03' 02.2" N, 00° 22' 52.1" E)

→ ចាប់ពីចំនុចនោះ ព្រំដែនត្រូវយកតាមខ្សែបន្ទាត់ឆ្នាំ១៩៦០ រហូតដល់ចំនុចដែលមានកូអរដោនេ (14° 01' 55" N, 00° 24' 11" E)

→ ចាប់ពីចំនុចនោះ វារត់តាមខ្សែត្រង់រហូតដល់ចំនុចព្រំដែនថ្មី Téra-Dori (កូអរដោនេ14° 00' 04.2" N, 00° 24' 16.3" E) (ទៅភាគខាងលិចនៃ Petelkolé)

→ ចាប់ពីចំនុចនោះ វារត់តាមខ្សែត្រង់រហូតដល់ចំនុច ដែលមានកូអរដោនេ13° 59' 03" N, 00° 25' 12" E ហើយឈានដល់ចំនុចបន្ទាត់ GNI (នៅក្នុងចំនុចដែលមានកូអរដោនេ 13° 58' 38.9" N, 00° 26' 03.5" E), ដែលស្របរហូតដល់ចំនុចបំបែកនៅក្នុងខ្សែបន្ទាត់ ដែលកាត់ភាគខាងជើងនៃតំបន់ Ihouchaltane នៅក្នុងចំនុចដែលមានកូអរដោនេ (13° 55' 54" N, 00° 28' 21" E)

→ ចាប់ពីចំនុចនេះ ព្រំដែនតំបន់ Ihouchaltane កាត់តាមចំនុចដែលមានកូអរដោនេ (13° 54' 42" N, 00° 26' 53.3" E, then 13° 53' 30" N, 00° 28' 07" E) ដែលស្របរហូតដល់ព្រំដែនចាស់។

→ ចាប់ពីចំនុចនោះ វាផ្គុំជាមួយខ្សែបន្ទាត់ GNI (នៅក្នុងចំនុចដែលមានកូអរដោនេ (13° 53' 24" N, 00° 29' 58" E) (កូអរដោនេ 13° 29' 08" N, 01° 01' 00" E)។

នៅកន្លែងដែលមានចន្លោះនៅក្នុងខ្សែទឹក នៃខ្សែបន្ទាត់ GNI វាត្រូវបំពេញដោយខ្សែត្រង់ ឬក៏កន្លែងដែលមានខ្សែទឹក ត្រូវកំណត់តាមខ្សែដេករបស់វា។

### ១.៥. ដំណើរការរឿងក្តី

នៅថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០១០ ប្រទេស ប៊ូគីណា ហ្វាសូវ និង ប្រទេស នីហ្សេរ បានដាក់រឿងក្តីជម្លោះព្រំដែនរបស់ខ្លួនចូលទៅក្នុងតុលាការ។ តាមរយៈលិខិតចូលរួម ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០ និងចុះទៅក្នុងបញ្ជីនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១០ រដ្ឋទាំងពីរបានប្រកាសជូនដំណឹងមកតុលាការ ស្តីពីកិច្ចព្រមព្រៀងពិសេស ដែលបានចុះហត្ថលេខានៅរដ្ឋ Niamey នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០០៩ និងចូលជាធរមាននៅថ្ងៃទី២០ ខែវិច្ឆិការ ឆ្នាំ២០០៩។ យោងទៅតាមលក្ខខណ្ឌនៃមាត្រា ១ នៃកិច្ចព្រមព្រៀងពិសេសនេះ រដ្ឋជាភាគីបានយល់ព្រមដាក់ជម្លោះព្រំដែនរបស់ពួកគេ ទៅតុលាការអន្តរជាតិដើម្បីឲ្យជួយដោះស្រាយ។

### ១.៦. សមាសភាពចៅក្រមកាត់ក្តី

| | |
|---|---|
| ១. Hisashi Owada | ប្រធាននៃអង្គជំនុំជម្រះ |
| ២. Peter Tomka | អនុប្រធាននៃអង្គជំនុំជម្រះ |
| ៣. Abdul G. Koroma | ចៅក្រមកាត់ក្តី |
| ៤. Bruno Simma | ចៅក្រមកាត់ក្តី |
| ៥. Ronny Abraham | ចៅក្រមកាត់ក្តី |
| ៦. Sir Kenneth Keith | ចៅក្រមកាត់ក្តី |
| ៧. Ernardo Sepúlveda-Amor | ចៅក្រមកាត់ក្តី |
| ៨. BENNOUNA | ចៅក្រមកាត់ក្តី |
| ៩. Leonid Skotnikov | ចៅក្រមកាត់ក្តី |
| ១០. CANÇADO TRINDADE | ចៅក្រមកាត់ក្តី |
| ១១. Abdulqawi Ahmed Yusuf | ចៅក្រមកាត់ក្តី |
| ១២. Christopher Greenwood | ចៅក្រមកាត់ក្តី |
| ១៣. Xue Hanqin | ចៅក្រមកាត់ក្តី |
| ១៤. DONOGHUE | ចៅក្រមកាត់ក្តី |
| ១៥. COUVREUR | ក្រឡាបញ្ជីកត់ត្រា |

### ១.៧. សេចក្តីសម្រេចរបស់តុលាការ[48]

១. សម្រេចដាក់ខ្សែបន្ទាត់ព្រំដែន រវាងប្រទេសទាំងពីរនៅក្នុងតំបន់ភូមិសាស្ត្រ Tong-Tong (ក្នុងចំនុច 14° 25' 04" នៃរយៈទទឹងខាងជើង និង 00° 12' 47" នៃរយៈបណ្តោយខាងកើត) ទៅចំនុ

[48] សេចក្តីសម្រេចរបស់តុលាការអន្តរជាតិ ទាក់ទងនឹងវិវាទព្រំដែនរវាងប្រទេស បូគីណា ហ្វាសូវនិង ប្រទេសនីហ្សេរ ចុះថ្ងៃទី ១៦ ខែមេសា ឆ្នាំ២០១៣

ចចាប់ផ្តើមនៃតំបន់បត់បែន Bouto (ក្នុងចំនុច12° 36' 18" នៃរយៈទទឹងខាងជើង និង 01° 52' 07" នៃរយៈបណ្តោយខាងកើត)

២. ដាក់បញ្ចូលរបាយការណ៍នៃកិច្ចព្រមព្រៀងរបស់គូភាគីទាំងពីរ ចូលទៅក្នុងលទ្ធផលនៃកិច្ចការបច្ចេកទេសដោះស្រាយវិវាទព្រំដែន រវាងប្រទេស ប្រទេសបូគីណា ហ្វាសសូរ និងនីហ្សេរ ដោយគោរពទៅតាមទីតាំងភូមិសាស្ត្រដូចតទៅ:

ក. ទីតាំងភូមិសាស្ត្រ ពីរយៈកំពស់ N'Gouma ទៅតំបន់ភូមិសាស្ត្រ Tong-Tong

ខ. ទីតាំងភូមិសាស្ត្រ ចំនុចចាប់ផ្តើមនៃតំបន់បត់បែនBouto ទៅទន្លេ Mekrou

មាត្រា ៧ នៃកិច្ចព្រមព្រៀងពិសេសនេះ ត្រូវបានផ្តល់ដោយ សេចក្តីសម្រេចរបស់តុលាការដែលមានចែងដូចតទៅ:

១. គូភាគីនៃជម្លោះ ទទួលយកសេចក្តីសម្រេចរបស់តុលាការ ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងពិសេសនេះ ជាសេចក្តីសម្រេចចុងក្រោយ និងចងភ្ជាប់ភាគីទាំងពីរ។

២. ចាប់តាំងពីថ្ងៃដែលសេចក្តីសម្រេចចូលជាធរមាន គូភាគីមានរយៈពេល ១៨ ខែ នៅក្នុងការចាប់ផ្តើមកំណត់សីមាព្រំដែន។

៣. ក្នុងករណីដែលមានការពិបាកក្នុងការអនុវត្តសេចក្តីសម្រេច ភាគីណាមួយអាចមានសិទ្ធិប្តឹងទៅតុលាការ អនុលោមតាមមាត្រា ៦០ នៃច្បាប់របស់តុលាការនេះ។

៤. គូភាគី អាចស្នើរសុំទៅតុលាការឱ្យតែងតាំងអ្នកជំនាញបីនាក់ក្នុងការសម្រេចនេះ ដើម្បីឲ្យជួយការងារកម្រិតព្រំដែន។

ជាចុងក្រោយ នៅក្នុងមាត្រា ១០ រក្សាទុកនូវកិច្ចសន្យាពិសេសដូចតទៅ:

ដោយយោងទៅតាមមការសម្រេចរបស់តុលាការ គូភាគីត្រូវទទួលយកទៅអនុវត្ត ដើម្បីរក្សាសន្តិភាព សន្តិសុខ និងភាពស្ងប់ស្ងាត់ក្នុងមជ្ឈដ្ឋានប្រជាជាតិនៃប្រទេសទាំងពីរ ដែលជាប្រទេសមានព្រំប្រទល់ជាមួយគ្នា ហើយទប់ស្កាត់សកម្មភាពទាំងឡាយ ដែលមានគោលបំណងទន្រ្ទានចូលទៅក្នុងដែនដីជម្លោះ ហើយនិងរៀបចំឱ្យមានការប្រជុំជាប្រចាំ ចំពោះការងាររដ្ឋបាល និងសេវាសន្តិសុខ។

ជាមួយនឹងការគោរពទៅនឹងការបង្កើតប្រព័ន្ធសេដ្ឋកិច្ចខុសគ្នា ភាគីត្រូវទទួលយកការចាប់ផ្តើមពិគ្រោះយោបល់មុននឹងទទួលយកការសម្រេចនេះទៅអនុវត្ត។

កិច្ចព្រមព្រៀងពិសេសនេះ ត្រូវបានផ្តល់ជូនតាមរយៈការផ្លាស់ប្តូរលិខិតតូបករណ៍ ដែលត្រូវបានប្រារព្ធឡើងនៅថ្ងៃទី ២៩ ខែតុលា និងថ្ងៃទី ០២ ខែវិច្ឆិការ ឆ្នាំ២០០៩ ដែលជាសក្ខីភាពបញ្ជាក់ពីការយល់ព្រមរវាងរដ្ឋជាភាគីទាំងពីរ ទៅលើការកំណត់ដែនសីមាតំបន់ព្រំដែន។

តាមការបង្គាប់បញ្ជា ចុះថ្ងៃទី១៤ ខែ ធ្នូរ ឆ្នាំ២០១០ តុលាការបានចាត់ទុក ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១១ និងថ្ងៃទី២០ ខែមករា ឆ្នាំ២០១២ ជាពេលវេលាកំណត់ដាច់ដោយឡែកពីគ្នា ក្នុងការរំលឹក និងការប្រឆាំងតប ដោយភាគីនីមួយៗ។ លិខិតសំអាងទាំងនោះត្រូវបានបំពេញដោយត្រឹមត្រូវក្នុងរយៈពេលកំណត់។

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការស្រាវជ្រាវអស់មួយរយៈពេលមកយើងសង្កេតឃើញថា យន្តការនៃការដោះស្រាយជម្លោះអន្តរជាតិត្រូវបានចាត់ទុកជានីតិវិធីពិសេសមួយ ដែលប្រទេសជាច្រើននៅលើពិភពលោកតែងយកមកអនុវត្តនាពេលបច្ចុប្បន្ន។ ជាងនេះទៅទៀត ច្បាប់អន្តរជាតិបានអនុញ្ញាតឲ្យរដ្ឋនីមួយៗស្វែងរកដំណោះស្រាយជម្លោះអន្តរជាតិរបស់ពួកគេដោយសន្តិវិធី។ ក្នុងការដោះស្រាយជម្លោះអន្តរជាតិ យើងអាចនិយាយបានថា គឺស្ថិតនៅទីតាំងមួយឈរលើការពិចារណា ដែលរដ្ឋភាគីជម្លោះអាចបើកចំហានូវការប្រឈមមុខដាក់គ្នា ដែលជាកត្តាជះឥទ្ធិពលដល់ការសម្រេចចិត្តមួយក្នុងការប្រើប្រាស់នីតិវិធីសម្រាប់ដោះស្រាយជម្លោះ។ ដើម្បីដោះស្រាយបញ្ហាជម្លោះទាំងនេះ ចាំបាច់ត្រូវពិចារណាលើបញ្ញត្តិច្បាប់អន្តរជាតិដែលមានជាធរមាន ក៏ដូចជាទំនៀមទំលាប់អន្តរជាតិ ដែលសុទ្ធតែជាវិធានចាំបាច់ក្នុងការដោះស្រាយជម្លោះ។

ការដោះស្រាយជម្លោះអន្តរជាតិមួយ គួរតែធ្វើការដោះស្រាយដោយសន្តិវិធី ជាជាងការប្រើប្រាស់កម្លាំងប្រដាប់អាវុធដូចប្រវត្តិសាស្ត្រកន្លងមក។ ដោយឡែកនៅក្នុងច្បាប់អន្តរជាតិ ក៏បានតម្រូវឲ្យមានការដោះស្រាយជម្លោះអន្តរជាតិដោយសន្តិវិធី ដូចមានចែងនៅក្នុងធម្មនុញ្ញនៃសហប្រជាជាតិមាត្រា៣៣។ ទោះបីជាយ៉ាងណាក៏ដោយ ប្រវត្តិនៃការដោះស្រាយជម្លោះអន្តរជាតិ បានកំណត់កាលបរិច្ឆេទត្រឹមសន្ធិសញ្ញាចាយ(Jay Treaty) នៅក្នុងឆ្នាំ ១៧៩៤ រវាង សហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស។ សន្ធិសញ្ញា មិត្តភាព សន្តិភាព ពាណិជ្ជកម្ម នាវាចរណ៍ បង្កើតឡើងដោយគណៈកម្មការចម្រុះបីរូប ដែលមានសមាសភាពចេញពីសហរដ្ឋអាមេរិក និងចក្រភពអង់គ្លេស។ គណៈកម្មការនេះនឹងធ្វើការដោះស្រាយទៅលើសំណួរជាច្រើន ដែលភាគីទាំងពីរមិនទាន់បានព្រមព្រៀងគ្នាតាមរយៈការចរចា។

បន្ថែមពីនេះទៅទៀត ការដោះស្រាយជម្លោះអន្តរជាតិនាពេលបច្ចុប្បន្ន ត្រូវបានគេដោះស្រាយតាមគោលនយោបាយពីរប្រភេទ ដូចជាការដោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការ និងការដោះស្រាយជម្លោះអន្តរជាតិក្នុងប្រព័ន្ធតុលាការ។ យន្តការដោះស្រាយជម្លោះទាំងពីរនេះ ត្រូវបានចែងយ៉ាងច្បាស់លាស់ ក្នុងច្បាប់អន្តរជាតិ។ ការដោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការត្រូវបានប្រទេសជាច្រើនប្រើប្រាស់សម្រាប់ដោះស្រាយជម្លោះអន្តរជាតិដូចជា នៅអំឡុងសង្គ្រាមហ្វក់ឡែន(Falkland) នាឆ្នាំ ១៩៨២ រវាងចក្រភពអង់គ្លេស និង អាហ្សង់ទីន។

ការដោះស្រាយជម្លោះអន្តរជាតិក្នុងប្រព័ន្ធតុលាការ គឺជានីតិវិធីបន្តពីការដោះស្រាយជម្លោះអន្តរជាតិក្រៅប្រព័ន្ធតុលាការ។ ឧទាហរណ៍ជាក់ស្តែងដូចជា ការដាក់បញ្ចូលរឿងក្ដីជម្លោះរបស់ប្រទេស បូគីណា ហ្វាសសូនិង ប្រទេស នីហ្សេរ ទៅក្នុងដែនយុត្តាធិការដោះស្រាយរបស់តុលាការយុត្តិធម៌អន្តរជាតិ ដែលបានបង្ហាញពីភ្លើងខៀវក្នុងការបង្ហាញឆន្ទៈទទួលយកការដោះស្រាយដោយ

សន្តិភាព។ វាបានបង្ហាញឲ្យឃើញរឹតតែច្បាស់ពីសារៈសំខាន់នៃអំណាចតុលាការ នៅក្នុងការដោះស្រាយជម្លោះព្រំដែន ដែលបន្ថែមទៅលើបញ្ហីជម្លោះព្រំដែននាពេលអតីតកាល ដោយបានដាក់បញ្ចូល និងធ្វើការដោះស្រាយដោយតុលាការយុត្តិធម៌អន្តរជាតិ។ ចំណាប់អារម្មណ៍មួយវិញទៀតនោះ គឺត្រង់ថាប្រទេសទាំងពីរបានដាក់បញ្ចូលរឿងក្តីជម្លោះព្រំដែនទៅតុលាការយុត្តិធម៌អន្តរជាតិមុន បើទោះបីជាស្ថិតនៅក្នុងរឿងក្តីខុសគ្នាក៏ដោយ។

ការដាក់បញ្ចូលរឿងក្តីជម្លោះរបស់ប្រទេសបូគីណា ហ្វាសសូរនិង ប្រទេស នីហ្សេរ អាចជាសារដ៏ពិសេសមួយ សំរាប់ការដោះស្រាយជម្លោះព្រំដែននៅក្នុងទ្វីបអាហ្វ្រិកនាពេលអនាគត។ បើទោះបីជាវាមិនបានបង្ហាញយ៉ាងជាក់ច្បាស់ ប៉ុន្តែវាអាចធ្វើឲ្យរដ្ឋទាំងពីរមានការអត់ធ្មត់ ក្នុងការដោះស្រាយជម្លោះរបស់ពួកគេ ដោយកម្មវិធីគ្រប់គ្រងព្រំដែនរបស់សហគមអាហ្វ្រិក(AUBP) ដែលបានជំរុញឲ្យរដ្ឋទាំងអស់ក្នុងទ្វីបអាហ្វ្រិក អាចកំណត់ព្រំដែនអន្តរជាតិរបស់ពួកគេយ៉ាងច្បាស់នៅក្នុងឆ្នាំ២០១២។ ការដោះស្រាយយ៉ាងលឿននៃជម្លោះរបស់ប្រទេស បូគីណា ហ្វាសសូរនិង ប្រទេស នីហ្សេរ អាចជំរុញឲ្យប្រទេសផ្សេងទៀត ដែលបានទទួលរងនូវការសោកស្តាយ ចំពោះរយៈកាលដ៏យូរលង់នៃការកំណត់ព្រំដែនពីមុន ឲ្យដាក់សំណើរដើម្បីទទួលបាននូវការដោះស្រាយយ៉ាងឆាប់រហ័សនិងសមស្របជាងនេះ។

